ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Oct-2014, 16:09
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>
# <u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ(វគ្គពីរ)</u>

## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២-០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin Karopkin)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ៊័ង

លោក ហ្វីលីព រ៉ូជឺ *(Mr. Phillips Roger)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក ស្រ៊ា រតនៈ

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d’ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក ចូសេហ្វ អេនឌ្រូ ប៊យលី

*(Mr. Joseph Andrew BOYLE)*

លោក សាលីម ណាកចាវ៉ានី

*(Mr.Salim Nakhjavani)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោកស្រី ទី ស្រីនណា

លោក ឡោ ជុនធី

លោកស្រី ម៉ុច សុវណ្ណារី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

លោក យីគាំង លូ *(Mr. Yiqiang LIU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ជា លាង | ខ្មែរ |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក នួន ជា | ខ្មែរ |
| លោក ខៀវ សំផន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០៣:០០]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

ថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលបានបង្កើតឡើងតាមច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋ-កម្មដែលបានប្រព្រឹត្តក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ បើកសវនាការជាសាធារណៈលើអង្គសេចក្តីលើសំណុំរឿង០០២/០២ ដែលមានជនជាប់ចោទចំនួនពីររូបដូចខាងក្រោម៖

១) នួន ជា ភេទ ប្រុស ឈ្មោះកំណើត ឡៅ គឹមលន កើតនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩២៦ នៅភូមិវត្តគ ឃុំវត្តគ ស្រុកសង្កែ ខេត្តបាត់ដំបង។ មានទីលំនៅមុនពេលចាប់ឃុំខ្លួននៅភូមិផ្សារព្រហ្ម ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន។ ជនជាប់ចោទមានមេធាវីការពារក្តីចំនួនពីររូបគឺ លោក សុន អរុណ និង លោក វ៉ិចទ័រ កូប៉េ។

២) លោក ខៀវ សំផន ភេទប្រុស កើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅឃុំរំចេក ស្រុករំដួល ខេត្តស្វាយរៀង។ មានទីលំនៅមុនពេលចាប់ឃុំខ្លួននៅភូមិកូនខ្ទង់ សង្កាត់អូរតាវៅ ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន។ ជនជាប់ចោទមានមេធាវីការពារក្តីចំនួនបីរូបគឺ លោក គង់ សំអុន, លោក អាកទួរ វែកកែន និងលោកស្រី អង់តា ហ្គីសសេ។

ដោយផ្អែកលើដីកាដំណោះស្រាយ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលបានប្រព្រឹត្តនៅលើទឹកដីប្រទេសកម្ពុជា និងនៅក្នុងអំឡុងពេលនៃការចូលលុកលុយទឹកដីវៀតណាមក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះតាមរយៈសហឧក្រិដ្ឋកម្មរួម ការរៀបចំផែនការ ការញុះញង់ ការជួយនិងជំរុញ ការបញ្ជាឲ្យប្រព្រឹត្ត ឬត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។

ឧក្រិដ្ឋទាំងនេះ និងទម្រង់នៃការទទួលខុសត្រូវមានចែង និងផ្តន្ទាទោសដោយមាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ថ្មី និងមាត្រា៣៩ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ

កម្ពុជា ដែលពីពេលនេះតទៅហៅកាត់ថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[០៩:០៦:១៥]

សមាសភាពនៃអង្គជំនុំជម្រះសាលាដំបូងរួមមានៈ ១) រូបយើង និល ណុន ជាប្រធាន, ២) ចៅក្រម ហ្សង់ម៉ាក ឡាវែន៍, ៣) ចៅក្រម យ៉ា សុខន, ៤) លោកស្រីចៅក្រម ក្លូឌា ហ្វេនស៍, ៥) លោកចៅក្រម យូរ ឧត្តរា និងមានចៅក្រមបម្រុងចំនួនពីររូបៈ ១) លោកចៅក្រម ធូ មណី, ២) លោកចៅក្រម ម៉ាទីន ខារ៉ុបគីន។

បណ្តុំដើមបណ្តឹងរដ្ឋប្បវេណីតែមួយដែលមានចំនួន ៣.៨៦៦ នាក់ តំណាងដោយសហមេធាវីនាំមុខ ចំនួនពីររូបគឺលោក ពេជ អង្គ ជាសហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ជាសហមេធាវីអន្តរជាតិ នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ។

មានបណ្តឹងជំទាស់ចំនួនពីរស្នើសុំដកចៅក្រមនៃអង្គជំនុំជម្រះនេះ ដែលត្រូវបានដាក់នៅចំពោះមុខក្រុមប្រឹក្សាពិសេសដែលបង្កើតឡើងដោយគណៈកម្មាធិការរដ្ឋបាលនៃ អ.វ.ត.ក ហើយដែលមិនទាន់ត្រូវបានសម្រេចនៅឡើយ។ អនុលោមតាមវិធាន៣៤(៥) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យចៅក្រមដែលត្រូវបានប្តឹងជំទាស់បន្តឲ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយរង់ចាំសេចក្តីសម្រេចលើបណ្តឹងជំទាស់ ហើយដើម្បីជាប្រយោជន៍យុត្តិធម៌ជំរុញដំណើរការនីតិវិធីឲ្យបានឆាប់រហ័សនៅក្នុងសំណុំរឿង០០២/០២ ចៅក្រមនៃអង្គជំនុំជម្រះ បានសម្រេចបន្តនីតិវិធីដូចដែលបានគ្រោងទុក។ ដោយឡែកកាលពីម្សិលមិញ អង្គជំនុំជម្រះបានទទួលការជូនដំណឹងក្រៅផ្លូវការមួយពីសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងកិច្ចសម្ភាសន៍នានារបស់សាក្សីនៅក្នុងសំណុំរឿងផ្សេងទៀតនៅចំពោះមុខអ.វ.ត.ក។ កំណត់ហេតុនៃកិច្ចសម្ភាសន៍នេះ ទំនងជាមានចំនួនរាប់រយទំព័រ ហើយមានការពាក់ព័ន្ធទៅ នឹងសាក្សីមួយចំនួនដែលនឹងត្រូវកោះហៅមកផ្តល់សក្ខីកម្មដំបូងៗ។ អង្គជំនុំជម្រះនិងភាគី នឹងត្រូវការពេលវេលាក្នុងការពិចារណាលើកំណត់ហេតុនៃកិច្ចសម្ភាសន៍ទាំងនោះ។

[០៩:០៨:៤៤]

ដោយសារហេតុផលនេះ អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគី និង សាធារណជនឲ្យបានជ្រាបថា អង្គជំនុំជម្រះសម្រេចពន្យារពេលស្តាប់សក្ខីកម្មសាក្សីដំបូងនៅក្នុងសំណុំរឿង ០០២/០២ រហូតដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤។ អង្គជំនុំជម្រះសម្រេចថា នឹងរៀបចំកិច្ចប្រជុំ រៀបចំសវនាការមួយនៅ

ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ នៅវេលាម៉ោងប្រាំបួនព្រឹក អនុលោមតាមវិធាន ៧៩(៧) នៃវិធានផ្ទៃក្នុង។ គោលបំណងនៃកិច្ចប្រជុំរៀបចំសវនាការនេះ គឺអនុញ្ញាតឲ្យភាគីនានា និង អង្គជំនុំជម្រះពិភាក្សាដោយសម្ងាត់ទៅលើផលវិបាកផ្លូវច្បាប់និងផលវិបាកនៅក្នុងការអនុវត្តជាក់ស្តែង ពាក់ព័ន្ធទៅនឹងការបញ្ចេញកំណត់ហេតុនៃការសម្ភាសថ្មីៗនេះ។ ប្រធានបទផ្សេងពីនេះ នឹងមិនត្រូវបានអនុញ្ញាតឲ្យយកមកពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំសវនាការនាពេលខាងមុខនេះទេ។

ខ្ញុំសូមប្រកាសបើកសវនាការចាប់ពីពេលនេះតទៅ។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាព វត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។

[០៩:១០:០៨]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់ថ្ងៃសវនាការថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។

អង្គជំនុំជម្រះមិនអញ្ញាតឲ្យលោកស្រីមតិយោបល់អ្វីទេនៅក្នុងអំឡុងពេលនេះ។ ហើយអង្គជំនុំជម្រះប្រព្រឹត្តតាមនីតិវិធី និងរបៀបវារៈដែលបានគ្រោងទុក ហើយបើលោកស្រីមានបំណងថានិយាយអ្វីនោះចាំដល់ពេលវេលាដែលអង្គជំនុំជម្រះនឹងផ្តល់ជូនលោកស្រីនៅពេលវេលាបន្តិចទៀតនេះ។

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងថា ដោយអនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ថ្ងៃនេះយើងនឹងស្តាប់សេចក្តីសន្និដ្ឋានដោយសង្ខេបអំពីការចោទប្រកាន់របស់សហព្រះរាជអាជ្ញា និងចម្លើយតបដោយសង្ខេបរបស់ជនជាប់ចោទ និង/ឬ មេធាវីការពារក្តីជនជាប់ចោទ។ ដូចដែលបានជម្រាបជូនខាងលើ សវនាការលើអង្គសេចក្តីនឹងចាប់ផ្តើមនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤ ហើយសាក្សីទី១ នឹងផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់។ ដើម្បីជាប្រយោជន៍ដល់សាធារណជន អង្គជំនុំជម្រះសាលាដំបូងសូមរំឭកឡើងវិញថា នៅថ្ងៃទី២២ ខែកញ្ញា ឆ្នា២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបំបែកនីតិវិធីដោយអនុលោមតាមវិធាន ៨៩ ស្ទួនពីរ ដោយកំណត់វិសាលភាពនៃការចោទ

ប្រកាន់លើអង្គហេតុដូចមានចែងនៅក្នុងដីកាដំណោះស្រាយក្នុងការជំនុំជម្រះដំណាក់កាលដំបូងៗនៅក្នុងសំណុំរឿង០០២ ត្រឹមការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១និងទី២ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជននោះ។

នាពេលបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ ដោយដាក់បញ្ចូលការសម្លាប់អតីតមន្ត្រីអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ ការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿងបានចូលជាស្ថាពរនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ហើយនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាពនៃសំណុំរឿង០០២/០២ ដោយអង្គជម្រះតុលាការកំពូលបានតម្កល់សេចក្ដីសម្រេចនេះនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤។

[០៩:១៣:១៤]

សាលក្រមក្នុងសំណុំរឿង០០២/០១ ត្រូវបានប្រកាសនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤។ ភាគីទាំងអស់លើកលែងតែភាគីសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ។ អង្គជំនុំជម្រះសាលាដំបូងនឹងមិនអានការវិភាគអង្គហេតុ ដូចដែលបានចែងនៅក្នុងដីកាបញ្ជូនរឿងឲ្យជំនុំជម្រះនោះទេ។ នៅពេលនេះដោយអនុលោមតាមវិធាន ៨៩(១)ស្ទួន នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យក្រឡាបញ្ជីលោកស្រី សែ កុលវុឌ្ឍី ឡើងអានបទចោទប្រកាន់នានាដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង០០២/០២។

សូមអញ្ជើញលោកស្រី សែ កុលវុឌ្ឍី!

**ក្រឡាបញ្ជី៖**

ដោយផ្អែកលើដីកាដំណោះស្រាយដែលបានកែប្រែសាលដីកាដោយអង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/3/15 និងឯកសារលេខ D427/4/15 សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្ដីទាក់ទងនឹងអញ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ។ ឯកសារលេខ E122 ជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទល្មើសដូចខាងក្រោម៖

តាមរយៈអំពើសកម្ម និង អកម្មនៅទីក្រុងភ្នំពេញ នៅលើទឹកដីនៃប្រទេសកម្ពុជាក្នុងរវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ បានប្រព្រឹត្ត ដោយបានចូលរួមនៅក្នុងសហ

ឧក្រិដ្ឋកម្មរួម រៀបចំផែនការ ញុះញង់ឲ្យប្រព្រឹត្ត បញ្ជាឲ្យមានការប្រព្រឹត្តនូវឧក្រិដ្ឋកម្មដូចខាងក្រោម៖ បានជួយនិងជំរុញដល់ចារី ឬត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើនូវ៖

១) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរួមមាន៖ ក) ការធ្វើមនុស្សឃាត, ខ) ការសម្លាប់រង្គាល, គ) ការធ្វើឲ្យទៅជាទាសករ, ឃ) ការនិរទេស, ង) ការដាក់ក្នុងមន្ទីរឃុំឃាំង, ច) ការធ្វើទារុណកម្ម, ឆ) ការរំលោភលើផ្លូវភេទ, ជ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា, ឈ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

[០៩:១៥:៤៦]

បទល្មើសដែលមានចែង និង ផ្តន្ទាទោសដោយមាត្រា៥ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក។

២) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការសម្លាប់សមាជិកក្រុមចាម និងវៀតណាម។

បទល្មើសដែលមានចែង និង ផ្តន្ទាទោសដោយមាត្រា៤ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក។

៣) ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ រួមមាន៖ ក) ការធ្វើមនុស្សឃាតដោយចេតនា, ខ) ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌, គ) ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព, ឃ) ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់, ង) ការនិរទេស និង ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

បទល្មើសដែលមានចែង និង ផ្តន្ទាទោស ដោយមាត្រា៦ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក។

យោងតាមសេចក្តីសម្រេចលើកទី២ លើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ឯកសារ E284 និងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង០០២/០២។ ឯកសារ E301/9/1 នៅក្នុងសវនាការដំបូងនៃសំណុំរឿង០០២/០២ ដែលមានជនជាប់ចោទឈ្មោះ នួន ជា និង ខៀវ សំផន។ អង្គជំនុំជម្រះនឹងពិនិត្យលើភស្តុតាងដែលទាក់ទងនឹងអង្គហេតុដូចខាងក្រោម៖

ក) ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា, ខ) រចនាសម្ព័ន្ធរដ្ឋបាល រចនាសម្ព័ន្ធទំនាក់ទំនង រចនាសម្ព័ន្ធ

យោធា, គ) ជម្លោះប្រដាប់អាវុធ, ឃ) តួនាទីនិងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ, ង) គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ ស្តីពីបញ្ហាទាំងប៉ុន្មានដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ច) អង្គហេតុដែលបានចោទប្រកាន់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ដែលកម្រិតត្រឹមការប្រព្រឹត្តទៅលើជនជាតិចាម សហករណ៍និងការដ្ឋានរួមមាន សហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។ មន្ទីរសន្តិសុខរួមមាន៖ មន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល។

[០៩:១៨:៤១]

ការប្រព្រឹត្តលើក្រុមមនុស្សជាក់លាក់នានារួមមាន៖ ការប្រព្រឹត្តលើពុទ្ធសាសនិក ដែលកម្រិតត្រឹមសហករណ៍ត្រាំកក់ ការប្រព្រឹត្តលើជនជាតិចាមដោយមិនរួមបញ្ចូលមន្ទីរសន្តិសុខស្រុកក្រូចឆ្មារ និងការប្រព្រឹត្តលើជនជាតិវៀតណាម ដោយមិនរួមបញ្ចូលឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជាលើទឹកដីវៀតណាមនោះទេ និងការដាក់បទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍នៅទូទាំងប្រទេសកម្ពុជា។

បទល្មើសប្រល័យពូជសាសន៍ ដោយការធ្វើមនុស្សឃាតលើក្រុមជនជាតិចាម និង ជនជាតិវៀតណាម។

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរួមមាន៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ សាសនា និងពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការរំលោភផ្លូវភេទ។ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ដែលចំណុចទាំងអស់នេះ ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ដែលកម្រិតត្រឹមការប្រព្រឹត្តលើជនជាតិចាម សហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។ មន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និង មន្ទីរសន្តិសុខភ្នំក្រោល។ ការប្រព្រឹត្តលើពុទ្ធសាសនិក ការប្រព្រឹត្តលើជនជាតិចាម និង ជនជាតិវៀតណាម។ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ រួមមាន៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាប

ដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឲ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀងទាត់ ការនិរទេសជនស៊ីវិលដោយខុសច្បាប់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។ ដែលចំណុចទាំងអស់នេះ ទាក់ទងនឹងមន្ទីរសន្តិសុខស-២១ និង មន្ទីរសន្តិសុខអូរកន្សែង។

សូមអរគុណលោកប្រធាន។

[០៩:២១:០៥]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកស្រី សែ កុលវុឌ្ឍី។ ហើយមុននឹងចាប់ផ្ដើមសេចក្ដីជាមួយនឹង -- សន្និដ្ឋានដោយសង្ខេបអំពីការចោទប្រកាន់របស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកដល់ជនជាប់ចោទថា អនុលោមតាមវិធាន២១(១)(ឃ)នៃវិធានផ្ទៃក្នុង ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ អនុលោមតាមវិធាន៩០ នៃវិធានផ្ទៃក្នុង ប្រសិនបើជនជនជាប់ចោទសម្រេចមិន អនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប ចៅក្រម សហព្រះរាជអាជ្ញា ភាគីទាំងអស់ និងមេធាវី មានសិទ្ធិសួរជនជាប់ចោទ។ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ តាមរយៈអ៊ីម៉ែលផ្ញើជូនមកមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង នួន ជា និង ខៀវ សំផន បានបង្ហាញថា ខ្លួននឹងមិនឆ្លើយតបនឹងសំណួរដោយអនុលោមតាមវិធាន ៩០ នៃវិធានផ្ទៃក្នុង បន្ទាប់ពីមានសេចក្តីសន្និដ្ឋានបើក។ សំណួរសួរថា តើលោកជនជាប់ចោទ នួន ជា តើលោករក្សាជំហរនេះដដែលដែរឬទេ ក្នុងការរក្សាសិទ្ធនៅស្ងៀមមិនឆ្លើយតប?

លោក នួន ជា សំណួរសួរថា តើលោករក្សាសិទ្ធិការនៅស្ងៀមមិនឆ្លើយតបដដែល ឬក៏ប្រើសិទ្ធិឆ្លើយតបតែប៉ុណ្ណឹងទេ។ ចំណែកឯសេចក្តីថ្លែងបើក អង្គជំនុំជម្រះនឹងផ្តល់ឱកាសឲ្យ ជូនទៅលោកនូវពេលវេលាជាមួយនឹងមេធាវីរបស់លោកនៅពេលបន្តិចទៀតនេះ។

[០៩:២៣:២៤]

**លោក នួន ជា៖**

ខ្ញុំនៅស្ងៀម។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោក នួន ជា។ ចុះលោក ខៀវ សំផនវិញយ៉ាងម៉េចដែរ? កាលពីតាមរយៈអ៊ីម៉ែលគឺថា ទទួលដោយមន្ត្រីច្បាប់ជាន់ខ្ពស់ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ថាលោករក្សាសិទ្ធិនៅស្ងៀម

មិនឆ្លើយតប។ ហើយរហូតដល់ពេលនេះ តើលោកតែរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល ឬក៏លោកមានការកែប្រែ ផ្លាស់ប្តូរចិត្តវិញ?

[០៩:២៤:០៥]

**លោក ខៀវ សំផន៖**

ខ្ញុំបាទសូមអនុញ្ញាតធ្វើសេចក្តីថ្លែងការណ៍មួយបាទ។

**ប្រធានអង្គជំនុំ៖**

សំណួរសួរថា តើលោកនៅរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបដូចដែលឆ្លើយតបមកមន្ត្រីច្បាប់ជាន់ខ្ពស់តាមអ៊ីម៉ែលដែរឬទេ? លោកឆ្លើយតែសំណួរទៅបានហើយ ថាតើលោករក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏ប្រើសិទ្ធិឆ្លើយតប ដើម្បីឱ្យអង្គជំនុំជម្រះនឹងរៀបចំនូវកិច្ចដំណើរការនីតិវិធីនាពេលខាងមុខ។ ចំណែកឯសេចក្តីថ្លែងបើករបស់លោក អង្គជំនុំជម្រះនឹងផ្តល់ឱកាសជូនទៅលោក ព្រមជាមួយនឹងមេធាវីរបស់លោកនៅពេលបន្តិចទៀតនេះ។

**លោក ខៀវ សំផន៖**

បើដូច្នេះ ខ្ញុំនឹងជម្រាបឆ្លើយតបនៅពេលដែលខ្ញុំធ្វើការថ្លែងការណ៍ហើយ។ អរគុណបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណ។

បាទ ជាបន្តទៅនេះ អង្គជម្រះសូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានបើកដោយសង្ខេប។

**លោកស្រី ជា លាង៖**

ចាស។ ជាដំបូងសូមគោរពប្រធានអង្គជំនុំជម្រះសាលាដំបូង លោក លោកស្រីជាចៅក្រម ភាគីទាំងអស់ អង្គសវនាការទាំងមូលក៏ដូចជាសាធារណជនទាំងអស់។

កាលពីពីរខែមុន យើងបានជួបជុំគ្នានៅក្នុងបន្ទប់សវនាការនេះ ដើម្បីស្តាប់នូវសាលក្រមដែលជាប្រវត្តិសាស្ត្ររបស់លោក លោកស្រី ដែលជាចៅក្រមនៅក្នុងដំណាក់កាលសវនាការទី១ ប្រឆាំងនឹងលោក នួន ជា និងលោក ខៀវ សំផន។ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ យុត្តិធម៌ដែលគេបានរង់ចាំនោះអស់រយៈពេលដ៏យូរមកហើយ ចុងបញ្ចប់ត្រូវបានផ្តល់ដល់ជនរងគ្រោះនៃរបបខ្មែរក្រហម។ ប៉ុន្តែកិច្ចការរបស់តុលាការនេះមិនទាន់បញ្ចប់នៅឡើយទេ។ ជនជាប់ចោទត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្ម

ប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅដំណាក់កាលដំបូង និងពួកគេឡើងកាន់អំណាច។ ពេលនោះ ប្រជាជនរាប់លាននាក់ត្រូវបានជម្លៀសដោយបង្ខំ ចេញពីទីក្រុងភ្នំពេញទៅនៅជនបទ។ ប៉ុន្តែបទឧក្រិដ្ឋដ៏ធំធែងដែលមានជនរងគ្រោះទទួលផលប៉ះពាល់ដោយសាររបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលជនជាប់ចោទត្រូវទទួលខុសត្រូវនោះ នៅមិនទាន់បានកាត់ក្តីបញ្ចប់នៅឡើយដែរ។

[០៩:២៧:៣១]

នៅក្នុងសវនាការនេះ យើងនឹងពិនិត្យទៅលើអ្វីដែលបានកើតឡើងចំពោះប្រជាជនកម្ពុជា ក្រោយពីការជម្លៀសដោយបង្ខំ ប្រជាជននៅតាមសហករណ៍ និង តាមការដ្ឋាននានា ដែលនៅទីនោះពួកគេត្រូវបានធ្វើឲ្យទៅជាទាសករ និងដាក់ឲ្យនៅក្រោមលក្ខខណ្ឌអមនុស្សធម៌ ដែលបង្កឲ្យមានការបាត់បង់ជីវិតរាប់មិនអស់ បណ្តាលមកពីការអត់ឃ្លាន ការធ្វើការបាក់កម្លាំង និង ជំងឺ។ នៅក្នុងសវនាការនេះ ជនជាប់ចោទនឹងត្រូវកាត់ទោសពីបទប្រល័យពូជសាសន៍ និង ការធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាម វៀតណាម ការធ្វើទុក្ខបុកម្នេញទៅលើព្រះសង្ឃ ព្រមទាំងការដាក់ឲ្យស្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ រងនូវការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការរំលោភសេពសន្ថវៈ។ ពេលនេះ ជនជាប់ចោទនឹងត្រូវកាត់សេចក្តីទៅលើឧក្រិដ្ឋកម្មដ៏ធំបំផុតដែលពួកគេត្រូវបានចោទប្រកាន់៖ ការសម្លាប់រង្គាល និង ការធ្វើមនុស្សឃាតចំពោះជនជាតិខ្មែររាប់ម៉ឺននាក់នៅតាមមន្ទីរអប់រំកែប្រែ និង មន្ទីរសន្តិសុខនានា។ នៅក្នុងគុកទាំងនេះ អ្នកដែលខ្មែរក្រហមចាត់ទុកថាជាខ្មាំងត្រូវបានឃុំឃាំងដោយខុសច្បាប់ សួរចម្លើយ និង ធ្វើទារុណកម្មយ៉ាងឃោរឃៅ និងយកទៅសម្លាប់ចោលដោយគ្មានមេត្តា។ ក្រោយពីការសួរចម្លើយរួច និងក្រោយពីអ្នកទាំងនោះផ្តល់នូវបញ្ជីឈ្មោះដែលបានចោទថាជាខ្មាំង ដែលត្រូវតាមរក។

នៅក្នុងចំណោមឧក្រិដ្ឋកម្មទាំងអស់នេះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពុំមានឧក្រិដ្ឋកម្មណាមួយដែលធំជាងការខិតខំឥតឈប់ឈរ និងជាប្រព័ន្ធរបស់មេដឹកនាំជាន់ខ្ពស់នៃខ្មែរក្រហម ដើម្បីកំណត់មុខសញ្ញា និង កម្ទេចខ្មាំងទាំងអស់ ដែលពួកគេខ្លាចថានឹងមានថ្ងៃណាមួយអាចប្រឆាំងនឹងពួកគេវិញ។ អ្នកដែលពួកគេកំណត់មុខសញ្ញាដើម្បីកម្ទេចមានដូចជា៖ អ្នកទាំងឡាយដែលមកពីគ្រួសារដែលមិនត្រូវបានគេចាត់ទុកថាវណ្ណៈកសិករនិងកម្មករ, អ្នកទាំងឡាយដែលពាក់ព័ន្ធជាមួយនឹងរដ្ឋាភិបាលមុន, អ្នកទាំងឡាយដែលគេចាត់ទុកថាជាជនសង្ស័យដោយសារពួកគេមកពីទីក្រុង, អ្នកទាំងឡាយដែលមិនគោរពនិងហ៊ានសួរនាំអំពីគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា និងអ្នកទាំងឡាយដែលព្យាយាមរត់គេចពីរបបខ្មែរក្រហម។ អំពើរឃោរឃៅមកលើប្រជាជនកម្ពុជា មិនចេះចប់ មិនចេះហើយ និងមាន

ទ្រង់ទ្រាយកាន់តែធំទៅៗមិនធ្លាប់មានពីមុន ដែលបានបណ្តាលឲ្យទឹកដីកម្ពុជាពោរពេញទៅដោយរណ្តៅសាកសព និងការបាត់បង់ជីវិត បាត់បង់បងប្អូន សាច់ញាតិ។ នេះគឺជាកេរដំណែលដ៏សាហាវពិតៗដែលបន្សល់ទុកដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលកំពុងអង្គុយនៅចំពោះមុខយើងទាំងអស់គ្នានៅថ្ងៃនេះ។ ដូច្នេះយើង សម្រាប់អ្នករាល់គ្នា ដែលបានសួរថាតើហេតុអ្វីបានជាពួកយើងត្រូវការសវនាការមួយទៀតនៅពេលដែលជនជាប់ចោទដែលមានវ័យចាស់ជរាបានទទួលការផ្តន្ទាទោសអស់មួយជីវិតទៅហើយនោះ? ចម្លើយគឺសាមញ្ញ។ គឺពួកយើងធ្វើនេះដោយសារប្រជាជនកម្ពុជារាប់លាននាក់ ដែលបានស្លាប់ដោយសាររបបមួយនេះ ក្នុងអំឡុងពេល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានតែភក់ជ្រាំ មានតែសេចក្តីវិនាសនិងទុក្ខព្រួយ មានតែការឈឺចាប់និងសេចក្តីស្លាប់។

[០៩:៣១:០៥]

លោក លោកស្រី ចៅក្រម ជាទីគោរព! ភារកិច្ចរបស់តុលាការនេះមិនទាន់បញ្ចប់នៅឡើយទេ ដរាបណាយុត្តិធម៌មិនទាន់ត្រូវបានផ្តល់ជូនជនរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងអស់នេះ។ នៅព្រឹកខ្ញុំនឹងពិភាក្សាទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងស្រុកត្រាំកក់ និងនៅសហករណ៍នានាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងនៅមន្ទីរសន្តិសុខនានាត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃក្នុងសវនាការមួយនេះដែរ។ ហើយបន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិនឹងបង្ហាញដល់អស់លោក លោកស្រី នូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ សហការីរបស់ខ្ញុំនឹងបន្តធ្វើការបង្ហាញពីភាពផ្ទុយគ្នា ដែលបានលើកឡើងពីតួនាទីរបស់ជនជាប់ចោទ និងការទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះបទល្មើសនីមួយៗដែលបានប្រព្រឹត្តដោយ នួន ជា និង ខៀវ សំផន ដែលនឹងត្រូវជំនុំជម្រះនៅក្នុងសវនាការមួយនេះ។

បទល្មើសនៅក្នុងស្រុកត្រាំកក់ និង នៅស្រុកក្រាំងតាចាន់។ ដំណាក់កាលដំបូងនៃសវនាការនេះនឹងផ្តោតទៅលើបទល្មើសដែលប្រព្រឹត្តឡើងនៅក្នុងសហករណ៍នានានៅក្នុងស្រុកត្រាំកក់ ស្ថិតក្នុងតំបន់១៣ ភូមិភាគនិរតី និងស្រុកក្រាំងតាចាន់ ដែលជាមន្ទីរអប់រំកែប្រែ ឬមន្ទីរសន្តិសុខក្រាំងតាចាន់។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ត្រាំកក់មានឈ្មោះថា “ស្រុក១០៥”។ នៅក្នុងសក្ខីកម្មដែលលោក លោកស្រីចៅក្រមបានឮ នួន ជា ក្នុងសវនាការមួយនេះ គាត់បានហៅស្រុកត្រាំកក់ថា កាលពីដំបូងឡើយជាមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានស្នូលទាំងពីររបស់បក្សកុម្មុយនីស្តកម្ពុជា។ ក្នុងរយៈកាលរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា, ខៀវ សំផន និងមេដឹកនាំបក្សដទៃទៀត បានធ្វើទស្សនកិច្ចនៅតំបន់នោះដើម្បីជួបជាមួយមេដឹកនាំភូមិភាគនិរតី គឺ តាម៉ុក ដើម្បីបង្ហាញជូនដល់ថ្នាក់លើអំពីសហករណ៍គំរូនៅឃុំ

លាយបូរណ៍។ ថ្នាក់ដឹកនាំបក្សបានទទួលរបាយការណ៍ជាប្រចាំអំពីការចាប់និងកម្ទេចខ្មាំង ការលើទំនប់ ជីប្រឡាយ ការបង្កបង្កើនផលស្រូវ និងជីវភាពរស់នៅរបស់ប្រជាជននៅត្រាំកក់ និងស្រុកដទៃទៀត ដែលស្ថិតនៅក្នុងភូមិភាគនិរតី។

[០៩:៣៣:៣០]

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៧ គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានជូនទង់ក្រហមកិត្តិយសដល់ស្រុកត្រាំកក់ ជាការទទួលស្គាល់ថា ស្រុកនេះជាស្រុកគំរូមួយក្នុងចំណោមស្រុកគំរូទាំងបីនៅទូទាំងប្រទេសកម្ពុជាប្រជាធិបតេយ្យ ក្នុងផ្នែកនៃការការពារប្រទេស ធ្វើបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម ក្នុងការបំពេញភារកិច្ចរបស់បក្ស ដើម្បីបាននូវស្រូវ ៣តោនក្នុងមួយហិកតា និងក្នុងការតស៊ូវណ្ណៈយ៉ាងក្តៀវក្លា សស្រាក់សស្រាំ នៅក្នុងស្រុកនេះទាំងមូល។

នៅក្នុងសវនាការនេះដែរ សហព្រះរាជអាជ្ញានឹងបង្ហាញជាភស្តុតាងនូវអ្វីដែលបានកើតឡើងនៅក្នុងស្រុកគំរូរបស់បក្សកុម្មុយនីស្តកម្ពុជានេះ ក្នុងអំឡុងពេលពីខែមេសា ឆ្នាំ១៩៧៥ ដល់ ខែមករា ឆ្នាំ១៩៧៩។ សាក្សីដែលបានស្នើមកផ្តល់សក្ខីកម្មនៅក្នុងសវនាការនេះដែរ រួមមានអតីតលេខាស្រុកត្រាំកក់ពីរនាក់ មេឃុំម្នាក់ កម្មាភិបាលដែលធ្វើការនៅមន្ទីរស្រុកនិងពេទ្យស្រុក អតីតអ្នកយាមគុក និងកម្មា-ភិបាលនៃមន្ទីរសន្តិសុខក្រាំងតាចាន់ ព្រមទាំងជនរងគ្រោះដែលនៅរស់រានមានជីវិត -- ដែលរស់នៅក្នុងស្រុកនោះ មានប្រជាជនចាស់ ប្រជាជនថ្មី និងអ្នកជាប់ឃុំឃាំងដែលនៅរស់រានមានជីវិត។ ជនជាប់ចោទត្រូវបានចោទពីបទល្មើសជាច្រើនពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទិននឹងស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ ការធ្វើឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើពុទ្ធសាសនិក និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងការនិរទេសជនជាតិវៀតណាម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើមន្ត្រីរបបលន់នល់និងប្រជាជនថ្មី អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការវាយប្រហារមកលើភាពថ្លៃថ្នូររបស់មនុស្ស។ ការជំនុំជម្រះលើទីតាំងបទល្មើសនេះតែមួយ នឹងអនុញ្ញាតឲ្យយើងពិនិត្យមើលលើទិដ្ឋភាពជីវិតទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយបទល្មើសដែលប្រជាជនកម្ពុជាត្រូវដាក់ឲ្យទទួលរងជារៀងរាល់ថ្ងៃ ដូចដែលធ្លាប់បានឆ្លងកាត់នៅក្នុងស្រុកមួយ ដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាគាំទ្រជាស្រុកគំរូមួយនៅក្នុងប្រទេសទាំងមូល។

[០៩:៣៦:១៩]

សហព្រះរាជអាជ្ញានឹងបង្ហាញនូវភស្តុតាងថានៅក្នុងស្រុកគំរូរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រជាជនគ្មានសិទ្ធិក្នុងការជ្រើសរើសទីកន្លែងរស់នៅ ធ្វើការ ឬរៀបអាពាហ៍ពិពាហ៍ដោយសេរីបានទេ។ ពួកគេត្រូវបានធ្វើឲ្យទៅជាទាសករនៅក្នុងសហករណ៍ ដែលគ្មានអ្វីហូបគ្រប់គ្រាន់ ហើយមនុស្សជាច្រើនបានស្លាប់ដោយសារអត់អាហារនិងជីវជាតិ។ អ្នកដែលតវ៉ាអំពីលក្ខខណ្ឌការងារនៅក្នុងសហករណ៍ ឬព្យាយាមលួចរត់ ត្រូវបានចាត់ទុកថាជាខ្មាំង រួចត្រូវបញ្ជូនទៅមន្ទីរអប់រំ ឬមន្ទីរសន្តិសុខ។ យើងសូមឲ្យលោក លោកស្រីដែលជាចៅក្រម ស្តាប់សក្ខីកម្មរបស់អនុប្រធានមន្ទីរពេទ្យស្រុកដែលបានរៀបរាប់អំពីការជួបប្រជុំជាមួយកម្មាធិការស្រុក ហើយពេលនោះគេសួរគាត់អំពីមូលហេតុដែលប្រជាជនជាច្រើនឈឺដេកពេទ្យ។ នៅពេលដែលគាត់ប្រាប់ទៅអ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជាអំពីស្រុកគំរូនេះថា ពីព្រោះប្រជាជនគ្មានអ្វីហូបគ្រប់គ្រាន់ និង ខ្វះជីវជាតិ។ ពេលនោះគេចោទគាត់ថាវាយប្រហារសហករណ៍។ ចំណែកឯសំណើរបស់គាត់សុំបង្កើនរបបអាហារក៏ត្រូវបានបដិសេធទៀត។

សហព្រះរាជអាជ្ញានឹងបង្ហាញថា នៅក្នុងស្រុកគំរូនេះ ព្រះសង្ឃមកពីទូទាំងខេត្តតាកែវបានមកប្រមូលផ្តុំគ្នានៅវត្តអង្គរកាស្រុក ត្រូវបានគេបង្ខំឲ្យសឹក និង ឲ្យចូលរួមធ្វើទាហាន ធ្វើជាកសិករ និងកម្មករ។ វត្តទាំងឡាយនៅក្នុងស្រុកត្រូវបានបិទ ហើយប្រជាជនត្រូវបានគេហាមមិនឲ្យគោរពព្រះពុទ្ធសាសនាឡើយ។ នៅក្នុងស្រុកគំរូរបស់បក្សកុម្មុយនីស្តកម្ពុជា អ្នកជម្លៀសមកពីទីក្រុងភ្នំពេញ និងទីក្រុងនានាត្រូវបានប្រមូលផ្តុំដាក់នៅវត្តចំប៉ាលើក។ ហើយអ្នកដែលត្រូវគេចាត់ទុកជាខ្មាំងរួមមាន មន្ត្រីជាន់ខ្ពស់និងទាហានលន់នល់ ត្រូវបានគេយកទៅសម្លាប់ចោល។ ដូចដែលលោក លោកស្រីចៅក្រម នឹងបានឃើញនៅក្នុងឯកសារបន្សល់ទុកពីស្រុកនោះស្រាប់ គឺថា ការធ្វើទុក្ខបុកម្នេញលើក្រុមគោលដៅដូចជាអតីតទាហានលន់នល់ ខ្មែរក្រោម និងប្រជាជនថ្មី បានបន្តពេញមួយរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ មានបញ្ជីឈ្មោះដែលកំណត់អត្តសញ្ញាណគ្រួសារខ្មែរក្រោម និងអត្តសញ្ញាណមន្ត្រីរដ្ឋការរបបលន់នល់ ដែលរស់នៅក្នុងស្រុកនីមួយៗ។ នេះគឺជាសេចក្តីរាយការណ៍មួយពីឃុំគួស ដែលរៀបរាប់ រៀបចំឡើងនៅខែមេសា ឆ្នាំ១៩៧៧ មានចំណងជើងថា “បញ្ជីឈ្មោះប្រជាជនកម្ពុជាក្រោមមកពីឃុំគួស”។ បញ្ជីឈ្មោះនេះមានខ្ទង់មួយមានចំណងថា “មុខងារ” ដែលបញ្ជាក់អ្នកដែលមានឋានៈតួនាទីនៅក្នុងជួរកងទ័ពលន់នល់។ ខ្ទង់បន្ទាប់មកទៀត មានបញ្ជាក់អ្នកដែលជាប្រជាជន១៧មេសាចេញពីភ្នំពេញ។ ក្រុមទាំងនេះត្រូវបានតាមដានយ៉ាងជិតដល់ ហើយត្រូវបានកំណត់ជាមុខសញ្ញាសម្រាប់ចាប់ខ្លួននិងសម្លាប់ចោលនៅពេលណាមានកំហុស ទោះបីជាកំហុសនេះតិចតួចក្តីបំផុត -- បំផុតក្តី។ មានសាក្សីម្នាក់មកពី

ស្រុកនេះបានរៀបរាប់ថា៖ “គ្រាន់តែហើបមាត់តែបន្តិច គេយកទៅបាត់ ឬយកទៅសម្លាប់ចោល”។ មានរបាយការណ៍ជាភាគរយរបស់ក្រុមស្រុកត្រាំកក់ដែលនៅសល់ពីមេឃុំ ឬសន្តិសុខស្រុកដែលទាក់ទិន នឹងប្រជាជនដែលត្រូវបានកំណត់ថាជាប់ខ្សែរបបសាធារណរដ្ឋខ្មែរ។

[០៩:៤០:០០]

តទៅនេះ និងជាឧទាហរណ៍មួយចំនួននៅក្នុងខែមេសា ឬឧសភា ឆ្នាំ១៩៧៧ ពោលគឺពីរខែមុន ពេលស្រុកត្រាំកក់ត្រូវបានជូនទង់ក្រហមកិត្តិយស ដោយគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ នៅក្នុងសេចក្តីរាយការណ៍នេះដែលផ្ញើជូនចំពោះមន្ទីរស្រុកពីឃុំជាងទង ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩៧៧ មេឃុំបានកំណត់មនុស្សពីរនាក់ដែលពាក់ព័ន្ធនឹងរបបលន់នល់ ដែលក្នុងនោះមានម្នាក់ជាទាហាន ស័ក្តិ១ និងម្នាក់ទៀតជាមន្ត្រីរដ្ឋការស៊ីវិលដែលបានធ្វើការនៅក្រសួងអភិវឌ្ឍន៍សហគមន៍។ ហើយសេចក្តី រាយការណ៍នោះសរសេរថា “ក្រោយពីបានទទួលការណែនាំជាបន្តបន្ទាប់ពីអង្គការក្នុងការប្រុងប្រយ័ត្ន ខ្មាំងនិងបោសសម្អាតពួកទាហានខ្មាំង ដែលមានបណ្តាស័ក្តិក្នុងនោះបានតាមដានពិនិត្យឃើញមានឈ្មោះ ដូចខាងក្រោម...”។ ឯកសារពីរ សាខាមូលដ្ឋានភូមិតាភេន ដែលបញ្ជូនចេញនៅក្នុងខែមេសា ឆ្នាំ ១៩៧៧ និយាយយោងដល់សេចក្តីណែនាំនានាដូចគ្នាដែរ។ សេចក្តីរាយការណ៍នោះសរសេរថា “ភូមិ តាភេន បានពិនិត្យនិងបោសសម្អាតខ្មាំង ដែលមានបណ្តាស័ក្តិក្រោយពីបានទទួលមតិណែនាំរបស់បក្ស និងឃើញថាមានអ្នកមានបណ្តាស័ក្តិប្រាំមួយនាក់ទៀត”។

នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ ឃុំពពេលបានផ្ញើសេចក្តីស្នើយោបល់មួយច្បាប់ទៅស្រុកដែល សរសេរថា “ចំពោះអ្នកមានបណ្តាស័ក្តិនៅក្នុងសង្គមចាស់ យើងខ្ញុំបញ្ជូនជាបន្តបន្ទាប់ ហើយពួកទាហាន និងគ្រូខ្លះដែលមានចេតនាបំផ្លាញ និងប្រឆាំងបដិវត្តន៍យើង សូមអង្គការឲ្យយោបល់។ ប្តេជ្ញាកម្ទេច ចារកម្មខ្មាំងឲ្យអស់ ដើម្បីធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមជូនបក្ស និងប្រជាជនដាច់ ខាត”។ យើងឃើញលទ្ធផលនៃយោបល់ដែលផ្តល់ទៅដល់ភូមិពពេលនៅក្នុងសេចក្តីរាយការណ៍បន្ទាប់ មក ដែលឃុំបានផ្ញើជូនស្រុកចំនួនបួនសប្តាហ៍កន្លងទៅ។ សេចក្តីរាយការណ៍នោះចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ នៅក្នុងឯកសារនោះឃុំពពេលរាយការណ៍ថា “គ្រួសារទាហានចំនួន ១០៦គ្រួសារដែលមាន ចំនួនមនុស្ស ៣៩៣នាក់ ត្រូវបានអង្គការកម្ទេចនិងសម្លាប់ ហើយដែលឃុំកំពុងពិនិត្យពុំទាន់ច្បាស់ថាជា ទាហាន ឬពុំមែនជាទាហាន”។

[០៩:៤២:៤៥]

ឯកសារត្រាំកក់រួមមាន កំណត់ហេតុរបស់លេខាស្រុក ដែលបញ្ជាឲ្យចាប់ខ្លួន ដែលបានរាយ-ការណ៍ដោយថ្នាក់ឃុំ ហើយកំណត់ហេតុពីលេខាតំបន់ បញ្ជាឲ្យសម្លាប់អ្នកទោសក្រោយពីសួរចម្លើយរួច។ នេះជារបាយការណ៍មួយពីក្រាំងតាចាន់ឲ្យសួរចម្លើយ។ អ៊ួង លី ដែលជាអតីតរដ្ឋការលន់នល់ និងគ្រូបង្រៀនពីអង្គតាសោម ដែលរៀនខាងបច្ចេកទេសម៉ាស៊ីនត្រជាក់នៅសហរដ្ឋអាមេរិក។ ចំណារដោយដៃជ្រុងខាងលើផ្នែកខាងឆ្វេង ជាចំណាររបស់លេខាតំបន់ទី១៣ ដែលជាអ្នកយល់ព្រមឲ្យមានការសម្លាប់មនុស្សទាំងនេះ។ តើលោក អ៊ួង លី មានអ្វីខ្លះ? ហេតុអ្វីបានជាគាត់ត្រូវគេសម្លាប់? បទល្មើសដែលគាត់មានគឺមានតែមួយគត់ ដែលគាត់មានអារម្មណ៍នឹកស្រុកអាមេរិក ធ្លាប់សប្បាយ ធ្លាប់ហូបឆ្ងាញ់ និងការនឹកដល់តួនាទីបុណ្យស័ក្តិជាអ្នកធំ ដែលធ្លាប់មាននៅក្នុងរដ្ឋាភិបាលលន់ នល់។

លោក លោកស្រីចៅក្រម គ្មានមន្ទិលសង្ស័យទេអំពីអង្គធាតុ និង ការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកម្ចាត់អតីតមន្ត្រីរដ្ឋការ និង ទាហាននៃរបបលន់នល់ នៅក្នុងភស្តុតាងដែលលោក លោកស្រីចៅក្រមនឹងពិនិត្យ ពិចារណានៅក្នុងស្រុកត្រាំកក់។ សហព្រះរាជអាជ្ញានឹងបង្ហាញថានៅក្នុងស្រុកគំរូនេះ មានជនជាតិវៀតណាមត្រូវបាននិរទេស និងដូរជាមួយខ្មែរក្រោមដែលរស់នៅវៀតណាម។ ខ្មែរក្រោមដែលបានបញ្ជូនមកត្រាំកក់ទាំងនោះ ត្រូវបានធ្វើឲ្យទៅជាទាសករ និងបង្ខំឲ្យធ្វើការនៅក្នុងសហករណ៍ និងការដ្ឋាននានានៅក្នុងស្រុក។

[០៩:៤៤:៣៣]

ក្រោយមក ពួកគេទាំងនោះដែលជាជនជាតិវៀតណាម ដែលទៅមិនទាន់អស់ ត្រូវបានប្រមូលយកទៅសម្លាប់ចោលរហូតទាល់តែគ្មាននៅសល់ជនជាតិវៀតណាមណាម្នាក់នៅក្នុងស្រុកត្រាំកក់។ ស្រដៀងគ្នានេះដែរ ខ្មែរក្រោមទាំងនោះត្រូវបានគេចាត់ទុកថាជាមុខសញ្ញា និងចោទប្រកាន់ថាជាខ្លួនជាខ្មែរ តែក្បាលជាយួន។ អតីតកម្មាភិបាលម្នាក់ដែលធ្វើការនៅក្នុងមន្ទីរស្រុកត្រាំកក់ក្នុងឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ សាក្សីដែលបានស្នើ 2-TWC-822 បានរៀបរាប់ជាលម្អិតរបៀបបោសសម្អាតរាល់ជនជាតិវៀតណាមទាំងអស់ដែលរស់នៅក្នុងស្រុក អនុលោមតាមផែនការរបស់ថ្នាក់លើ។ កម្មាភិបាលត្រូវជាសាច់ញាតិរបស់ តាម៉ុក ដែលគេចាត់តាំងឲ្យចាប់ជនជាតិវៀតណាម បានប្រាប់គាត់ថាគេយកទៅសម្លាប់រាប់ពាន់គ្រួសារ។ នៅក្នុងស្រុកគំរូរបស់បក្សកុម្មុយនីស្តកម្ពុជានេះ សេចក្តីរាយការណ៍ប្រចាំខែ ត្រូវបានរៀបចំសម្រាប់ថ្នាក់ដឹកនាំរបស់បក្ស ដែលសរុបចំនួនមនុស្សដែលបានចាប់ខ្លួន និង កម្ទេចក្នុងខែនីមួយៗនៅមន្ទីរអប់រំនៅក្រាំងតាចាន់ នៅក្នុងស្រុក១០៥។ នេះជាសេចក្តីរាយការណ៍ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ដែល

សរសេរថា "មានអ្នកទោសថ្មីចូលចំនួន ៧៥នាក់។ នៅខែនោះ អ្នកទោស ៩២នាក់ត្រូវបានបោសសម្អាត និងប្រាំមួយនាក់ស្លាប់ដោយជំងឺ។ ដូចនេះ នៅសល់អ្នកទោសសរុបចំនួន ៨៥នាក់ នៅដំណាច់ខែនោះ"។ នៅក្នុងស្រុកគំរូរបស់បក្សកុម្មុយនីស្តកម្ពុជានេះ ក្មេងតូចៗ ត្រូវបានចាប់ និងសម្លាប់ជាមួយឪពុកម្តាយរបស់ពួកគេ។ នេះគឺជាឯកសារមួយដែលសរសេរដោយលេខស្រុកត្រាំកក់ នៅខែសីហា ឆ្នាំ១៩៧៨។ ឯកសារនេះបន្សល់នូវអ្វីបានប្រព្រឹត្តមកលើកូនអ្នកទោសស្ត្រី ដែលក្មេងទាំងនោះតូចពេកមិនអាចធ្វើការបាន។ ខ្ញុំសូមស្រង់សំណេររបស់លេខាស្រុកនៃបក្សកុម្មុយនីស្តកម្ពុជាដូចខាងក្រោម៖ "បើកូនធំៗទៅនៅកងចល័ត ឬកងកុមាររួចទៅហើយ ឲ្យវាទៅនៅទីនោះចុះ។ យកតែម្តាយទេ តែបើកូននោះបេះមិនដាច់ពីម្តាយទេយកមកចុះ។ សាកសួរអស់រឿងរ៉ាវហើយ បោសសម្អាតទាំងអស់"។

[០៩:៤៧:១៥]

លោក លោកស្រីចៅក្រម សូមកុំច្រឡំអំពីខ្លឹមសារនៃឯកសារនេះ។ នៅពេលដែលខ្មែរក្រហមនិយាយថា"បោសសម្អាតទាំងអស់" គឺគេសំដៅទៅលើការសម្លាប់។ ក្នុងករណីមួយនេះ គឺជាការសម្លាប់កុមារតូចៗ ពោលគឺកូនក្មេងនិងទារក។ ទាំងអស់នេះ គឺជាជីវិតនៅក្នុងស្រុកគំរូរបស់បក្សកុម្មុយនីស្តកម្ពុជា។ បទល្មើសទាំងឡាយដែលប្រព្រឹត្តនៅក្រាំងតាចាន់ នឹងត្រូវបង្ហាញ មិនមែនបង្ហាញត្រឹមតែតាមរយៈឯកសារដែលនៅសេសសល់ពីត្រាំកក់តែប៉ុណ្ណោះទេ តែតាមរយៈសក្ខីកម្មរបស់អ្នកធ្លាប់ជាប់មន្ទីរឃុំឃាំងដែលនៅរស់រានមានជីវិត និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលធ្លាប់ធ្វើការនៅទីនោះផងដែរ ដែលបានសារភាពថាខ្លួនបានដាក់ខ្នោះអ្នកទោសនៅក្នុងលក្ខណៈអមនុស្សធម៌។

ការប្រើប្រាស់ទារុណកម្មក្នុងអំឡុងពេលសួរចម្លើយ និងសម្លាប់អ្នកទោសដែលគេកប់ក្នុងរណ្តៅរួមជុំវិញបរិវេណគុក។

ឯកសារមួយច្បាប់សរសេរដោយប្រធានគុកក្រាំងតាចាន់ ឈ្មោះ អាន់ និងដែលបញ្ជាក់ដោយអតីតលេខាស្រុកបានរាយការណ៍ជូនបក្សថា "ចាប់ពីយើងកម្ទេចពួកអាខ្មាំងមកដល់សព្វថ្ងៃនេះ អស់ចំនួន ១៥០០០នាក់"។ ទាំងនេះគឺជាអដ្ឋិធាតុមួយចំនួនដែលគេគាស់មកពីរណ្តៅសាកសពរួម នៅជុំវិញគុកក្រាំងតាចាន់។

លោក លោកស្រីចៅក្រម នឹងកំណត់នៅក្នុងសវនាការនេះថា ជនណាទទួលខុសត្រូវចំពោះបទល្មើសទាំងនេះ -- ហើយមុនពេលដែលយើងខ្ញុំនឹងចូលទៅប្រធានបទបន្តបន្ទាប់មកទៀត អនុញ្ញាតឲ្យខ្ញុំត្រឡប់ទៅមើលលើសក្ខីកម្មដ៏សំខាន់មួយដែលយើងបានស្តាប់រួចហើយលើបញ្ហានេះ។ នៅក្នុងសវនាការ

ទីមួយ អតីតលេខាស្រុកត្រាំកក់ ពេជ្រ ជឹម បានរៀបរាប់អំពីវគ្គរៀនសូត្រនយោបាយរយៈពេលមួយខែ ដែលរៀបចំឡើងមួយឆ្នាំម្តងនៅភ្នំពេញ សម្រាប់លេខាស្រុកនិងលេខាតំបន់ មកពីទូទាំងប្រទេសចូលរួម។ នៅក្នុងការប្រជុំនានាដែលគាត់បានចូលរួម អ្នកបង្រៀនមានតែម្នាក់គត់គឺ ជនជាប់ចោទ នួន ជា។ នៅពេលដែលអតីតលេខាស្រុកគំរូរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានសួរថា នួន ជា បានពិភាក្សាអំពីខ្មាំងផ្ទៃក្នុងនិងខ្មាំងផ្ទៃក្រៅ គាត់បានឆ្លើយថា "និយាយទាំងអស់។ បើមិននិយាយ មិនឮ អីហៅខ្មាំង អីហៅសត្រូវ"។

[០៩:៥០:00]

លោក លោកស្រី ចៅក្រម បទល្មើសដែលប្រព្រឹត្តនៅស្រុកត្រាំកក់ មិនមែនជាអំពើរបស់កម្មាភិបាលខ្មែរក្រហមនោះទេ។ បទល្មើសទាំងនេះ គឺជាអំពើររបស់សមាជិកបក្សដែលមានភក្តីភាពចំពោះបក្ស និងមានការហ្វឹកហ្វឺនរៀនសូត្រត្រឹមត្រូវដែលអនុវត្តនូវគោលនយោបាយ សេចក្តីណែនាំនិងបំណងប្រាថ្នារបស់ នួន ជា, ខៀវ សំផន និងមេដឹកនាំបក្សកុម្មុយនីស្តដទៃទៀត។ បន្ទាប់ពីស្រុកត្រាំកក់ ថ្ងៃទី២នៃសវនាការនេះ នឹងពិនិត្យទៅលើការដ្ឋានដែលមានកេរ្តិ៍ឈ្មោះអសោចបំផុតចំនួនបីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺទំនប់១មករា ដែលបានកសាងនៅលើទន្លេជីនិតក្នុងខេត្តកំពង់ធំ ដែលជាផ្នែកមួយនៃភូមិភាគបស្ចិម ឬឧត្តរចាស់។ ទំនប់ត្រពាំងថ្មនៅក្នុងខេត្តបន្ទាយមានជ័យដែលកសាងឡើងដោយតំបន់៥នៃភូមភាគពាយ័ព្យ និងព្រលានយន្តហោះកំពង់ឆ្នាំង ជាការដ្ឋានដែលគ្រប់គ្រងកងពលធំលេខ៥០២របស់កងទ័ពបដិវត្តន៍កម្ពុជា។

ដោយអនុលោមតាមផែនការសេដ្ឋកិច្ចរបស់ជនជាប់ចោទ និង មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត គម្រោងផែនការធារាសាស្ត្រទ្រង់ទ្រាយធំត្រូវបានផ្តួចផ្តើមឡើងនៅទូទាំងប្រទេសនៅក្នុងឆ្នាំ១៩៧៦។ វាជាផ្នែកមួយនៃទ្រឹស្តីមហាលោតផ្លោះ មហាអស្ចារ្យរបស់បក្សកុម្មុយនីស្តកម្ពុជា មេដឹកនាំបក្សបានអំពាវនាវឲ្យបញ្ចប់ការកសាង សាងសង់ទំនប់ទ្រង់ទ្រាយធំទាំងអស់នោះឲ្យបានឆាប់រហ័ស ដោយមិនគិតថាទំនប់ទាំងនោះត្រូវបានកសាងភាគច្រើនដោយកម្លាំងមនុស្សឡើយ។ ផែនការរបស់មជ្ឈិមបក្សចំពោះទំនប់១មករា គឺទាមទារឲ្យបញ្ចប់ការសាងសង់ទំនប់ដែលមានប្រវែង៦០គីឡូម៉ែត្រ ក្នុងរយៈពេលមិនលើសពីរមួយឆ្នាំ។ អាងស្តុកទឹកនៅទំនប់ត្រពាំងថ្ម គឺមានទំហំប្រហែលបឹងមួយយ៉ាងធំ។ អាងនេះរួមបញ្ចូលទាំងទំនប់ទប់ទឹកប្រហែល ១៣គីឡូម៉ែត្រដែលកសាងនៅតាមបណ្តោយផ្នែកខាងកើតនៃអាងស្តុកទឹកទំនប់ទប់ទឹកប្រវែង ៩គីឡូម៉ែត្រនៅផ្នែកខាងត្បូង ព្រមទាំងស្ពានចំនួនបី និងប្រឡាយវែងៗចំនួន

បីខ្សែ ដែលប្រឡាយនីមួយៗមានប្រវែង ៥០គីឡូម៉ែត្រ។ ទោះបីជាគម្រោងនេះមានទំហំធំធេងយ៉ាងណាក៏ដោយ ក៏ផែនការបក្សនៅតែអំពាវនាវឲ្យបញ្ចប់គម្រោងសាងសង់នេះក្នុងរយៈពេលត្រឹមតែបីខែប៉ុណ្ណោះ។ ដូចដែលលោក លោកស្រីបានស្ដាប់នូវសក្ខីកម្មរបស់អតីតប្រធានផ្នែកសេដ្ឋកិច្ចនៅតំបន់៥។

ជាលទ្ធផល ការណែនាំរបស់បក្ស ប្រជាជនរាប់ពាន់នាក់ត្រូវបានបញ្ជូលទៅកាន់ការដ្ឋានទាំងនេះ ហើយត្រូវបានគេប្រគល់ឲ្យនូវការងារដែលលំបាកលំបិននិងមិនសមហេតុផល ហើយពួកគេត្រូវបានបង្ខំឲ្យធ្វើការតាំងពីព្រឹកដល់យប់ ហើយមិនមានអាហារ ថ្នាំសង្កូវគ្រប់គ្រាន់។ ពលករជាង ២០.០០០នាក់ត្រូវបានចាត់តាំងឲ្យទៅកសាងទំនប់១មករា ហើយពលករជាង ៣០.០០០នាក់ត្រូវបានបញ្ជូនទៅទំនប់ត្រពាំងថ្ម។

[០៩:៥៣:៣១]

នៅក្នុងខ្សែវីដេអូឃោសនារបស់បក្សកម្ពុជាមួយនេះ ទីតាំងដែលត្រូវបានគេជឿថាការដ្ឋានទំនប់១មករា។ លោក លោកស្រីអាចមើលឃើញពីទំហំធំធេងនៃគម្រោងទាំងនេះ ព្រមទាំងទំហំការងារដែលត្រូវបំពេញដោយពលករដែលត្រូវគេបញ្ជូនទៅកសាងទំនប់ និង ជីកប្រឡាយ។ ពលករនៅតាមការដ្ឋានទាំងនេះត្រូវគេបែងចែកទំហំការងារប្រចាំថ្ងៃ ហើយគេរំពឹងថា ពួកគាត់អាចជីកនឹងរែកដីពីមួយទៅបីម៉ែត្រគូបជារៀងរាល់ថ្ងៃ។ លោក លោកស្រី ចៅក្រម អាចមើលឃើញនៅក្នុងខ្សែវីដេអូនេះថា ពួកគេភាគច្រើនធ្វើការដោយគ្មានស្បែកជើង។ ជនជាប់ចោទទាំងពីរស្គាល់ច្បាស់ពីទំនប់១មករា និង ទំនប់ត្រពាំងថ្ម។ ការកសាងទំនប់និងប្រឡាយ គឺជាប្រធានបទទូទៅដែលត្រូវបានពិភាក្សា។

នៅក្នុងរបាយការណ៍និងសារទូរលេខដែលបញ្ជូនទៅមជ្ឈិមបក្ស ខៀវ សំផន បានទៅធ្វើទស្សកិច្ចនៅការដ្ឋានទាំងពីរ ហើយបានលើកសរសើរពីការកសាងអាងស្តុកទឹកអាងត្រពាំងថ្ម។ នួន ជា ធ្វើដំណើរតាមបណ្ដាខេត្តជាប្រចាំ ហើយបានឃើញពីស្ថានភាពនៅទំនប់១មករា និងការដ្ឋានដទៃទៀត ដូចដែលលោក លោកស្រី ចៅក្រម ធ្លាប់បានស្ដាប់សក្ខីកម្មរបស់កងការពារគាត់នៅក្នុងសវនាការលើកទី១ របស់នួន ជា។ ការកសាងទំនប់ទាំងនេះត្រូវបានបរិយាយនៅក្នុងទស្សនាវដ្ដីទង់បដិវត្ត និង ទស្សនាវដ្ដីយុវជនយុវនារីបដិវត្ត ដោយមជ្ឈិមបក្ស។ នេះគឺជាទស្សនាវដ្ដីយុវជន-យុវនារីបដិវត្ត ចេញផ្សេងខែកក្កដា-សីហា ឆ្នាំ១៩៧៧។ នៅក្នុងទស្សនាវដ្ដីនេះ មានអត្ថបទរៀបរាប់យ៉ាងលម្អិតអំពីលក្ខណៈនៃទំនប់ត្រពាំងថ្ម ដោយបានកត់សម្គាល់ថា ការកសាងអាងស្តុកទឹកចាប់ផ្ដើមនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបានបញ្ចប់ជាស្ថាពរនៅពាក់កណ្ដាលខែឧសភា និងបានផ្ដល់នូវព័ត៌មាន អំពីអ្វីដែលពលកររាប់ម៉ឺននាក់បានឆ្លងកាត់

នៅការដ្ឋាននេះ។

មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក៏បានមកកាន់ការដ្ឋានទាំងអស់នេះដែរ ដើម្បីបង្ហាញដល់ប្រតិភូបរទេស អំពីសមិទ្ធផលសម្រេចបានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងរូបថតនេះ លោក-លោកស្រីនឹងឃើញ លោកស្រី អៀង ធីរិទ្ធ នាំក្រុមប្រតិភូស្ត្រីមកពីប្រទេសឡាវទៅកាន់ទំនប់១មករា។

[០៩:៥៦:១៨]

នៅក្នុងខែធ្នូ ឆ្នាំ១៩៧៧ ឧបនាយករដ្ឋមន្ត្រីចិនត្រូវបានដឹកនាំបក្សកុម្មុយនីស្តកម្ពុជា អញ្ជើញទៅបំពេញទស្សនកិច្ចនៅទំនប់ទាំងពីរ។ នៅទំនប់ត្រពាំងថ្ម រស់ ញឹម ដែលជាលេខាភូមិភាគពាយ័ព្យ បានប្រកាសថាទំបន់នេះ ទំនប់ត្រូវបានកសាងឡើងប្រើរយៈពេលតិចជាងពីរខែ ជាការឆ្លើយតបទៅនឹងសេចក្តីអំពាវនាវរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីកសាងអាងស្តុបទឹកដ៏ធំមួយ។ នៅទំនប់១មករា លេខាភូមិភាគមជ្ឈិម កែ ពក បានកត់សម្គាល់ថា ព្រះសង្ឃមានសង្ឃដីកាថា មានតែព្រះទេដែលអាចទប់ទឹកស្ទឹងជីនីតបាន។ ជាការឆ្លើយតប ប៉ុល ពត បានអះអាងថា មនុស្សខ្លួនឯងគឺជាព្រះ។ ប៉ុន្តែពលករនៅតាមការដ្ឋានទាំងនេះមិនត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជាព្រះទេ។ ពួកគាត់គឺជាទាសករដែលទទួលបានត្រឹមរបបអាហារបន្តិចបន្តួចត្រូវធ្វើពីព្រឹកព្រលឹមរហូតដល់យប់ជ្រៅសម្រាកផ្ទាល់ដី ហើយត្រូវតាមដាននិងឃ្លាំមើលដោយកងឈ្លបបក្សកុម្មុយនីស្តកម្ពុជា។ ពួកគាត់នៅសល់តែស្បែកដណ្តប់ឆ្អឹង ខ្វះជីវជាតិ និងមានហើមដៃហើមជើងផងដែរ។ អ្នកដែលឈឺធ្ងន់មិនអាចធ្វើការកើត ត្រូវបានគេចោទថាជាខ្មាំង ហើយត្រូវទទួលទណ្ឌកម្ម។ អ្នកដែលតវ៉ាពីស្ថានភាពការងារ ឬបញ្ហាខ្វះម្ហូបអាហារ ឬក៏អ្នកដែលព្យាយាមរត់គេច ត្រូវបានគេចាប់ខ្លួន ហើយយកទៅបាត់។ ទាំងនេះគឺជាតថភាពជាក់ស្តែងនៅក្នុងការដ្ឋានទាំងនេះ។ ហើយលោក លោកស្រីចៅក្រម និងបានស្តាប់ឮ ពីដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីដែលធ្លាប់ធ្វើការនៅទីនោះស្រាប់។

[០៩:៥៨:១៣]

ពីខាងលើទំនប់១មករា លោក លោកស្រី អាចមើលឃើញវត្តបារាយណ៍ជាន់ដែក។ ដូចគ្នានឹងវត្តអារាមដែលព្រះពុទ្ធសាសនាដទៃទៀតដែរ វត្តនេះត្រូវបានខ្មែរក្រហមប្រើប្រាស់ធ្វើជាមន្ទីរសន្តិសុខ។ ពលករជាច្រើននៅទំបន់១មករា ត្រូវបានចាប់ខ្លួន ហើយយកទៅនៅទីនោះ និងសម្លាប់ចោល។ ដូចដែលបង្ហាញយ៉ាងច្បាស់នៅក្នុងរូបថត កាលពីឆ្នាំ១៩៨៧ អំពីសាកសពដែលនៅសេសសល់និងជីករកឃើញនៅក្នុងវត្តបារាយណ៍ជាន់ដែក គឺមានមនុស្សរាប់ពាន់នាក់ដែលត្រូវបានស្លាប់នៅក្នុងការដ្ឋាននេះ។ លោក

លោកស្រី នឹងបានស្ដាប់នូវ -- ចៅក្រមនឹងបានស្ដាប់នូវសក្ខីកម្មប្រហាក់ប្រហែលគ្នាពាក់ព័ន្ធនឹងការចាប់ខ្លួន ការបាត់ខ្លួនពលករនៅទំនប់ត្រពាំងថ្ម។

ចំណែកឯការដ្ឋានព្រះលានយន្តហោះកំពង់ឆ្នាំង ស្ថិតក្រោមប្រតិបត្តិការរបស់កងពលធំលេខ៥០២ របស់កងទ័ពបក្សជិវត្តន៍កម្ពុជា។ ការដ្ឋាននេះគឺជាការដ្ឋានលត់ដំ ដែលត្រូវបានប្រើប្រាស់ដើម្បីពង្រឹងវិស័យកងទ័ព ដែលចេញពីបណ្ដាលកងពលនានា ដែលត្រូវបានបោសសម្អាត ឬអ្នកដែលគេចាត់ទុកថាជាជនសង្ស័យដោយសារតែប្រវត្តិរូប ឬទំនាក់ទំនងផ្ទាល់ខ្លួន។ ការដ្ឋាននេះ គឺជាគម្រោងការងារដែលត្រូវបានផ្ដួចផ្ដើមឡើង និងត្រួតពិនិត្យដោយគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្ដកម្ពុជា ហើយត្រូវបានយកទៅពិភាក្សាជាប្រចាំនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែល នួន ជា, ខៀវ សំផន បានចូលរួម។

[០៩:៥៩:៥៥]

ដូចមានបង្ហាញនៅក្នុងកំណត់ហេតុកិច្ចប្រជុំដែលនៅសេសសល់ មេដឹកនាំបក្សកុម្មុយនីស្ដកម្ពុជាតែងតែចុះទៅពិនិត្យមើលការដ្ឋាននេះជាញឹកញាប់ ក្នុងនោះរួមមានជនជាប់ចោទទាំងពីររូបផងដែរ។ អ្នកគ្រប់គ្រងការដ្ឋានមួយរូបដែលធ្វើការឲ្យមេបញ្ជាការរងកងពលធំលេខ៥០២ បានឃើញផ្ទាល់ភ្នែក ថា "ខៀវ សំផន បានមកកាន់ការដ្ឋាននេះ ហើយបានជួបជាមួយមេបញ្ជាការរងកងពលធំលេខ៥០២ និងប្រធានការដ្ឋានដទៃទៀត"។ ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង គ្របដណ្ដប់លើផ្ទៃដីទំហំ ៣០០ហិកតា ហើយជាការដ្ឋានធំបំផុតមួយ ក្នុងចំណោមការដ្ឋានធំបំផុតផ្សេងៗទៀតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ផ្លូវសម្រាប់យន្តហោះដែលអាចមើលឃើញនៅក្នុងរូង រូបថតពីលើអាកាសនេះ គឺមានប្រវែង ២,៤ គីឡូម៉ែត្រ មានមនុស្សប្រហែលពី ២ ទៅ ៣.៥០០០នាក់ ត្រូវបានគេបញ្ជូនទៅការដ្ឋានលត់ដំនេះ។ ពួកគេត្រូវបានបង្ខំឲ្យធ្វើការរយៈពេលវែងដោយមានរបបអាហារមិនគ្រប់គ្រាន់ ហើយត្រូវទទួលការគំរាមកំហែងថា ត្រូវសម្លាប់ ឬត្រូវបញ្ជូនទៅមន្ទីរសន្តិសុខ។ អ្នកខ្លះត្រូវបានគេបញ្ជូនទៅមន្ទីរស-២១។ ក្រុមកងទ័ពដែលគេបោសសម្អាតមួយក្រុមធំមកពីភូមិភាគបូព៌ា ត្រូវបានគេយកចេញពីការដ្ឋាន ហើយយកទៅសម្លាប់ទាំងអស់។ កម្មាភិបាលនារីជាច្រើននៅការដ្ឋាននេះបានធ្វើអត្តឃាត។

ផែនការរបស់មេដឹកនាំបក្សកុម្មុយនីស្ដកម្ពុជាចំពោះការដ្ឋានព្រលានយន្តហោះរួមមានមជ្ឈមណ្ឌលបញ្ជាការពីក្រោមដីយ៉ាងធំដែលត្រូវសង់នៅចង្កេះភ្នំតារាជ។ ពលករនៅការដ្ឋានបានប្រើប្រាស់គ្រឿងផ្ទុះដើម្បីបំផ្ទុះឲ្យមានជារូងក្នុងភ្នំកម្ពស់ខ្ពស់ ៦ម៉ែត្រ និងលាតសន្ធឹងចូលទៅក្នុងភ្នំចម្ងាយ ៤០០ម៉ែត្រ។ នៅ

តាមបណ្តោយរូងនេះ បន្ទប់ធំៗមួយចំនួនត្រូវបានគេធ្វើឱ្យបំបែកថ្មភ្នំ។ អ្នកសារព័ត៌មានមួយរូបរបស់សារព័ត៌មាន ខេមបូឌា ឌេលី ដែលបានធ្វើដំណើរចូលទៅក្នុងរូងនោះ បានរៀបរាប់អំពីការខ្សត់អុកស៊ីហ្សែន ខ្យល់អាកាសកខ្វក់និងភាពងងឹត។ ហើយខ្ញុំសូមដកស្រង់ពាក្យដែលគាត់សរសេរថា៖ "ពិតជាពិបាកក្នុងការជឿថា មនុស្សអាចបំពេញការងារធ្ងន់ធ្ងរបាននៅក្នុងបរិស្ថានបែបនេះ"។ សាក្សីបានផ្តល់សក្ខីកម្មថា មានអ្នកស្លាប់ ឬរងរបួសជារឿងរាល់ពេលនៅក្នុងការខិតខំប្រឹងប្រែងកសាងគម្រោងរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានលក្ខណៈរវើរវាយ និងប្រកបដោយគ្រោះថ្នាក់បែបនេះ។ ការដាក់ប្រជាជនកម្ពុជាឱ្យទៅជាទាសករនៅតាមការដ្ឋាន និង សហករណ៍របស់កម្ពុជាប្រជាធិបតេយ្យ ក៏នឹងត្រូវបានបង្ហាញតាមរយៈសារទូរលេខ ឬរបាយការណ៍មួយចំនួនដែលបានផ្ញើទៅមេដឹកនាំមជ្ឈិមបក្ស ដោយរៀបរាប់ពីប្រជាជនដែលព្យាយាមរត់គេច ឬភៀសខ្លួនចេញពីការដ្ឋានបែបនេះ ត្រូវបានតាមដាមរកចាប់ខ្លួន និងនាំយកទៅការដ្ឋានវិញ ឬក៏កម្ទេចចោល។

[១០:០៣:២៦]

នេះគឺគ្រាន់តែជាឧទាហរណ៍ដែលយកចេញពីរបាយការណ៍ប្រចាំខែ កក្កដា ឆ្នាំ១៩៧៨ របស់ភូមិភាគបស្ចិម។ រៀបរាប់អំពីកងទ័ពតំបន់ដែលឃើញខ្មាំងបីនាក់ព្យាយាមរត់ចេញពីទីតាំងព្រលានយន្តហោះកំពង់ឆ្នាំង ហើយក៏បាញ់ទៅលើពួកគេ។ ហើយកងទ័ពតំបន់បានរាយការណ៍ថា អ្នកដែលត្រូវបានចាប់ខ្លួនត្រូវបានបញ្ជូនទៅកន្លែងអប់រំ ហើយសួរចម្លើយវាបន្តទៀត។ របាយការណ៍នេះដដែលនេះបានរៀបរាប់អំពីការចាប់ខ្លួនមនុស្សម្នាក់ដែលរត់ចេញពីសហករណ៍មួយ។ របាយការណ៍របស់ភូមិភាគបស្ចិមកាលពីខែកន្លងមក គឺមានផ្នែកមួយដែលមានចំណងជើង "សកម្មភាពលួចរត់ចេញពីសហករណ៍"។

លោក លោកស្រីចៅក្រម យើងបានកំណត់ទៅលើករណីជាងមួយរយ ដែលក្នុងករណីទាំងនោះ មេដឹកនាំមជ្ឈិមបក្សនៅទីក្រុងភ្នំពេញបានទទួលរបាយការណ៍ពីការចាប់ខ្លួនអ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋតែមួយគត់ គឺព្យាយាមចាកចេញ។ គឺចាកចេញពីសហករណ៍ ឬការដ្ឋានដែលពួកគេត្រូវដាក់ឱ្យទៅជាទាសករ។ គឺធ្វើដំណើរទៅកាន់ព្រំដែនដែលនៅជិតខាង -- ជិតបំផុត ដើម្បីរត់គេចខ្លួនចូលប្រទេសថៃ ឬប្រទេសវៀតណាម។ ដូចដែលយើងធ្លាប់បានឮដដែលៗរួចមកហើយពីបណ្តាអ្នកដែលរស់រានមានជីវិតពីរបបនេះ គឺថាកម្ពុជាប្រជាធិបតេយ្យគឺជាគុកឥតជញ្ជាំង។

[១០:០៥:០៥]

អំពីមន្ទីសន្តិសុខ។ ឥឡូវនេះយើងនឹងបង្ហាញអំពីមន្ទីរសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ ដែល

ស្ថិតនៅក្នុងផ្នែកទី៤នៃសវនាការនេះ។ ខ្ញុំបានពិភាក្សារួចហើយ កន្លងមកយើង -- អំពីគុកក្រាំងតាចាន់, មន្ទីរអប់រំកែប្រែស្រុកត្រាំកក់។ នៅក្នុងសវនាការនេះ ជនជាប់ចោទក៏បាន និងធ្វើការជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងគុកអូរកន្សែងក្នុងខេត្តរតនគិរី នៅមន្ទីរសន្តិសុខភ្នំក្រោលក្នុងខេត្តមណ្ឌលគិរី និងនៅស-២១។ បើទោះបីជាមិនមានទំហំធំដូចស-២១ក៏ដោយ ប៉ុន្តែក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល ក៏គឺជាសារៈសំខាន់ចំពោះសំណុំរឿងនេះដែរ។ ដោយសារតែមានភស្តុតាងដែលភ្ជាប់បទឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅគុកទាំងនេះ ជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅទីក្រុងភ្នំពេញ។ អូរកន្សែង គឺជាពន្ធនាគារយោធា ជាមន្ទីរអប់រំកែប្រែរបស់កងពលធំលេខ៨០១ របស់កងទ័ពបដិវត្តន៍កម្ពុជា ដែលមានមូលដ្ឋាននៅក្នុងខេត្តរតនគិរី។ ភស្តុតាងដែលត្រូវបង្ហាញពាក់ព័ន្ធមន្ទីរសន្តិសុខនេះនឹងផ្តោតសំខាន់ទៅលើការសម្លាប់ជាទ្រង់ទ្រាយធំនូវបុរស ស្ត្រី និង កុមារ ជនជាតិចារាយមកពីវៀតណាមដែលត្រូវចាប់ខ្លួនដោយកងពលធំលេខ៨០១។ ការសម្លាប់នេះ ត្រូវបានរៀបរាប់ដោយប្រធាន និង អនុប្រធានគុកអូរកន្សែង ព្រមទាំងអ្នកជាប់ឃុំឃាំងដែលនៅរស់រានមានជីវិតពីគុកអូរកន្សែង។ មានការទាក់ទងដោយផ្ទាល់ជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅទីក្រុងភ្នំពេញ។ អ្នកដែលទទួលបានទូរលេខពីលេខាភូមិភាគឦសានដែលបានរាយការណ៍ពីការចាប់ខ្លួនអ្នកទោសចារាយទាំងអស់នោះ បានហៅអ្នកទាំងនោះថា "ជាកងទ័ពយួន។ សុំមតិអង្គការ តើត្រូវធ្វើដូចម្តេចជាមួយអ្នកទោសទាំងនោះ"។ បញ្ជីអ្នកទទួលទូរលេខនោះ រួមមាន នួន ជា និង ការិយាល័យដែល ខៀវ សំផន ធ្វើការ។ ប្រធានគុកអូរកន្សែងបានផ្តល់សក្ខីកម្មថា៖ "ការបញ្ជាឱ្យសម្លាប់អ្នកទោសជនជាតិចារាយ ត្រូវបានបញ្ជូនមកកងពលធំលេខ៨០១ ដោយមន្ទីរភូមិភាគឦសាន"។

[១០:០៧:៣១]

លោក លោកស្រី ចៅក្រម ជាទីគោរព! ខ្ញុំសូមអនុញ្ញាតបកស្រាយឱ្យបានច្បាស់។ ហេតុអ្វីបញ្ហានេះជាបញ្ហាសំខាន់? ជាទូទៅ បញ្ជាឱ្យសម្លាប់នៅអូរកន្សែងមិនមែនមកតាមរយៈមន្ទីរភូមិភាគទេ។ ប៉ុន្តែក្នុងករណីនេះ លេខាភូមិភាគបានស្នើសុំការណែនាំពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅទីក្រុងភ្នំពេញអំពីសកម្មភាពដែលត្រូវធ្វើចំពោះអ្នកទោសជនជាតិចារាយ ២០០នាក់ ដែលកងពលធំលេខ៨០១ ចាប់ខ្លួនបាន។ ហើយការណែនាំទទួលបានគឺឱ្យសម្លាប់ពួកគេ។

លោក លោកស្រី ចៅក្រម! ដោយសារតែនេះគឺជាការសម្លាប់ជនជាតិវៀតណាមដែលត្រូវបានចាប់ខ្លួនដោយកងទ័ពបដិវត្តន៍កម្ពុជាក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ ទើបបទប្រឆាំងជនជាប់ចោទ

ពាក់ព័ន្ធនឹងអូរកន្សែង មានរួមបញ្ចូលនូវការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។ ប្រធាននិងអនុប្រធានគុកអូរកន្សែងទទួលស្គាល់ថា មានការប្រើប្រាស់ទារុណកម្ម រួមទាំងការវាយដំដោយប្រើដំបង ឬ ខ្សែរំពាត់ -- ខ្សែរំពាត់ និង ការឆក់ខ្សែភ្លើង។ អ្នកទាំងពីរបានពិពណ៌នាអំពីការសម្លាប់អ្នកទោសនៅក្បែររណ្តៅបេ៥២ នៅទីតាំងជិតៗគុក ហើយពួកគេក៏បានពិពណ៌នាអំពីវិធីដែលកងទ័ព មកលើកងពលត្រូវបានចាប់ខ្លួននៅអូរកន្សែងផ្អែកតាមចម្លើយសារភាពនៅស-២១ ដែលបានផ្ញើមកពីទីក្រុងភ្នំពេញ និងបានឆ្លើយដាក់កម្មាភិបាលទាំងនោះថាជាផ្នែកមួយនៃខ្មាំង។ នេះគឺជាចម្លើយសារភាពមួយនៅស-២១ ដែលត្រូវបានបញ្ជូនមកលេខាកងពល៨០១ ឈ្មោះ វឿន។ ចំណារលើក្របទំព័រដែលបានសរសេរដោយ សុន សេន ហៅ ខៀវ ដែលជាប្រធានកងទ័ពបដិវត្តន៍កម្ពុជាបានស្នើសុំឱ្យ វឿន អានចម្លើយសារភាពនេះ និងស្រង់ឈ្មោះដែលទាក់ទងជាមួយនឹងកងពល៨០១។ ភស្តុតាងទាក់ទងនឹងមន្ទីរសន្តិសុខនេះ ក៏រួមមានរបាយការណ៍ ឬទូរលេខដែលលេខាកងពល៨០១ បានបញ្ជូនទៅ សុន សេន។ ក្នុងនោះ លេខារូបនោះបានប្តេជ្ញាគោរពតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការចាប់ខ្លួនអ្នកសង្ស័យថាខ្មាំង និង អ្នកណាប្រឆាំងនឹងមាគ៌ាបក្ស។

[១០:១០:០២]

លោក លោកស្រី ចៅក្រម! សហព្រះរាជអាជ្ញានឹងបង្ហាញថា ការដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត និងឧក្រិដ្ឋកម្មផ្សេងទៀតដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខអូរកន្សែង ត្រូវបានប្រព្រឹត្តឡើងជាមួយនឹងការដឹងឮ និងស្របតាមគោលនយោបាយ ការណែនាំរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅភ្នំពេញ។ ករណីនេះ ដូចគ្នានៅភ្នំក្រោលដែរ។ ភ្នំក្រោលគឺជាមន្ទីរសន្តិសុខរបស់តំបន់១០៥ ជាតំបន់ស្វ័យតមួយនៅក្នុងខេត្តមណ្ឌលគិរី ដែលធ្វើការរាយការណ៍ដោយផ្ទាល់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយ-នីស្តកម្ពុជា។

យើងបានស្តាប់សក្ខីកម្មពីអតីតកម្មាភិបាលពីររូបមកពីតំបន់នោះរួចហើយ។ សៅ សារុន អតីតលេខាតំបន់១០៥ បានពិពណ៌នាថា គាត់បានធ្វើដំណើរទៀងទាត់ទៅកាន់ទីក្រុងភ្នំពេញដើម្បីរាយការណ៍ជូនមេដឹកនាំមជ្ឈិមបក្ស រួមមាន ប៉ុល ពត, នួន ជា និង ខៀវ សំផន។ គាត់បានផ្តល់សក្ខីកម្មថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅភ្នំពេញជាអ្នកធ្វើសេចក្តីសម្រេចទាក់ទងនឹងខ្មាំងនយោបាយ ដែលចាប់ខ្លួនបាននៅតំបន់របស់គាត់។ ឧទាហរណ៍អ្នកដែលត្រូវបានចោទពីបទក្បត់បក្ស ឬសហការជាមួយនឹងយួន។ យើងក៏បានស្តាប់សក្ខីកម្មរបស់ ខាំ ផាន់ ក្នុងការជំនុំជម្រះលើកទី១។ ខាំ ផាន់ គឺជាកម្មាភិបាល

ម្នាក់ដែលធ្វើការនៅមន្ទីរទូរលេខរបស់តំបន់១០៥ និងជាកូនប្រុសរបស់លេខាតំបន់នេះមុន សៅ សារុន។ ខាំ ផាន់ បានពិពណ៌នាអំពីវិធីដែលទូរលេខទាក់ទងនឹងបញ្ហាសន្តិសុខ ត្រូវបានបញ្ជូនទៅ នួន ជា និងវិធីដែលទូរលេខទាំងនេះត្រូវបានទទួលមកពី នួន ជា ដែលបានកោះហៅកម្មាភិបាលឲ្យទៅក្រុងភ្នំពេញ។ សក្ខីកម្មរបស់សាក្សីទាំងនេះ ទាក់ទងនឹងអំណាចរបស់មេដឹកនាំមជ្ឈិមបក្សសម្រាប់មណ្ឌលគិរី តំបន់ ១០៥ ស៊ីសង្វាក់ជាមួយនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមបក្សចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ១៩៧៦ ស្តីពីសិទ្ធិកម្ទេចនៅក្នុងនិងក្រៅជួរ។ សេចក្តីសម្រេចនេះលើកឡើងថា “សម្រាប់តំបន់ឯករាជ្យដូចជាតំបន់១០៥ សេចក្តីសម្រេចកម្ទេចត្រូវធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍”។

[១០:១២:៣២]

លោក លោកស្រី ចៅក្រម! សហព្រះរាជអាជ្ញានឹងបង្ហាញថា គណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា អ្នកទទួលខុសត្រូវផ្ទាល់លើការសម្លាប់ទៅលើមន្ទីរសន្តិសុខភ្នំក្រោល។ ការទទួលខុសត្រូវនេះក៏បានឆ្លុះបញ្ចាំងឃើញនៅក្នុងទូរលេខដែលនៅសេសសល់ពីតំបន់មណ្ឌលគិរីផងដែរ។

ទូរលេខ ចុះនៅខែសីហា ឆ្នាំ១៩៧៧ ដែលមានលេខាតំបន់១០៥ ឈ្មោះឡាំង ឪពុករបស់សាក្សី ខាំ ផាន់ បានបញ្ជូនទៅមន្ទីរ៨៧០ បានរាយការណ៍អំពីការចាប់ខ្លួនមនុស្សបីនាក់ដែលបានរត់គេចមកពីស្ទឹងត្រែង ដែលគេជឿជាក់ថាខ្មាំង ដោយសារពួកគេកាន់ព្រះឆាយាល័ក្ខណ៍សម្តេច សីហនុ។ ទូរលេខនេះស្នើសុំសេចក្តីសម្រេចពីមជ្ឈិមបក្សថាតើ “ត្រូវបោសសម្អាតពួកគេនៅទីនេះ ឬបញ្ជូនពួកគេទៅកាន់ភូមិភាគឦសាន?”។ ទូរលេខមួយនេះដែលបានផ្ញើមកពីលេខាតំបន់ សៅ សារុន បានរាយការណ៍អំពីការចាប់ខ្លួនបុរសនិងស្ត្រីដែលធ្វើខុសសីលធម៌។ ទូរលេខនេះបានលើកឡើងថា “មិត្តនេះ កាលមុនមានជាប់ចម្លើយពួកអាក្បត់ អាជួន ក្នុងតំបន់។ ពេលនោះនៅតាមដានសកម្មភាពវាថែមទៀត តែឥឡូវនេះវាបានប៉ះពាល់សីលធម៌យ៉ាងនេះ បានចាប់ឃុំឃាំងទុកហើយ”។ ទូរលេខនេះបានស្នើសុំមតិយោបល់ថាតើត្រូវធ្វើអ្វីចំពោះអ្នកទោសដែលបានបញ្ជូនទៅ “អ៊ំនួន អ៊ំវ៉ាន់ អ៊ំវន មន្ទីរឯកសារ”។

នៅក្នុងការជំនុំជម្រះនេះ យើងនឹងស្តាប់ភស្តុតាងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងមន្ទីរសន្តិសុខតំបន់១០៥ ដែលបានកើតចេញពីលទ្ធផលនៃគោលនយោបាយ និងការណែនាំរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។

លោក លោកស្រី ចៅក្រម នឹងស្តាប់នូវសក្ខីកម្មរបស់អ្នកទោសដែលនៅរស់រានមានជីវិត និងដែលស្ថិតនៅក្នុងក្រុមមនុស្ស ៨០នាក់ ដែលត្រូវបានចាប់ឃុំខ្លួននៅមន្ទីរសន្តិសុខនៅតំបន់នេះ នៅចុងឆ្នាំ

១៩៧៧ ដោយសារតែពួកគេជាសាច់ញាតិ ឬធ្លាប់ជាកម្មាភិបាលធ្វើការនៅក្នុងមន្ទីរនេះ ហើយត្រូវបានចោទប្រកាន់ថាជាជនក្បត់ រួមទាំងពួកអាក្បត់ ដែលមានឃោងនៅក្នុងទូរលេខ ដែលលោក លោកស្រី ចៅក្រមទើបតែបានឃើញអម្បាញ់មិញនេះស្រាប់ហើយ។ អ្នកទោសទាំងនេះនឹងពិពណ៌នាអំពីវិធីអ្នកជាប់ឃុំឃាំងទាំងនេះជាច្រើននាក់ត្រូវបានយកចេញទៅបាត់ ហើយពុំដែលបានឃើញត្រឡប់មកវិញជារៀងរហូត។

[១០:១៥:១៦]

ជាការពិតណាស់ ការជំនុំជម្រះលើមន្ទីរសន្តិសុខ និង រួមបញ្ចូលទាំងស-២១ ដែលជាគុកថ្នាក់ខ្ពស់បំផុតមួយនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ស-២១ គឺជាមន្ទីរសន្តិសុខមួយស្ថិតនៅក្នុងក្រុងភ្នំពេញ ដែលបានរាយការណ៍ជូនមេដឹកនាំមជ្ឈិមបក្ស ព្រមទាំងជាមន្ទីរសន្តិសុខដែល នួន ជា មើលការខុសត្រូវដោយផ្ទាល់ក្នុងអំឡុងចុងឆ្នាំក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាមន្ទីរសន្តិសុខដែលមានមនុស្សជាង១២.០០០នាក់ត្រូវបានសម្លាប់នៅទីនោះក្នុងរយៈពេលបីឆ្នាំ។ ឧក្រិដ្ឋកម្មនានាបានប្រព្រឹត្តឡើងនៅស-២១ ត្រូវបានកត់ត្រានៅក្នុងឯកសារយ៉ាងម៉ត់ចត់ ដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលធ្លាប់ធ្វើការនៅទីនោះ។ ហើយឧក្រិដ្ឋកម្មទាំងនេះគ្មានអ្វីអាចជំទាស់តវ៉ាបាន។ ឧក្រិដ្ឋកម្មនេះបានបង្ហាញតាមរយៈប្រវត្តិរូបរបស់អ្នកទោស រូបថត និងបញ្ជី ត្រូវបានរៀបចំឡើងក្រោយពេលអ្នកទោសមកដល់ស-២១។ ឧក្រិដ្ឋកម្មទាំងនេះបានបង្ហាញតាមរយៈបញ្ជីសួរចម្លើយ របាយការណ៍ដែលបានរៀបរាប់ឡើងដោយបុគ្គលិកស-២១ ដែលពិពណ៌នាអំពីការប្រើប្រាស់ទារុណកម្ម និងចម្លើយសារភាពជាច្រើនទំព័រដែលបានកើតឡើងចេញពីការធ្វើទារុណកម្មជាច្រើនសប្តាហ៍ ឬច្រើនខែ។ ដែលចម្លើយសារភាពទាំងនេះជាច្រើនមានចំណារបញ្ជាក់អំពីវិធីដែលចម្លើយសារភាពទាំងនេះបញ្ជូនទៅ សុន សេន, នួន ជា និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀត។ ឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងនៅស-២១ ត្រូវបានបង្ហាញតាមរយៈបញ្ជីអ្នកទោសដែលត្រូវបានគេសម្លាប់ចោល។ អ្នកមានចំណារតបពីអង្គការថា "ឯកភាពក្នុងការសម្លាប់"។ បញ្ជីស-២១នេះ កត់ត្រាការសម្លាប់អ្នកទោសចំនួន ១៧៣នាក់ក្នុងមួយថ្ងៃពីភូមិភាគឧត្តរនាថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៧៧ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានបង្ហាញតាមរយៈសក្ខីកម្មលម្អិតដែលបានផ្តល់ដោយអ្នកជាប់ឃុំឃាំង អ្នកយាម និងអ្នកសួរសម្លើយមួយចំនួនតូច ដែលរស់នៅមានជីវិតនិងធ្លាប់ធ្វើការនៅទីនោះ។ នៅស-២១ នឹងបានផ្តល់ដោយប្រធានគុកខ្លួនឯង គឺលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច។

[១០:១៧:៤៨]

ឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានបង្ហាញតាមឆ្អឹងមនុស្សដែលនៅសេសសល់ ក្រោយការជីកកាយពីរណ្ដៅរួមនៅជើងឯក។ រណ្ដៅរួមទាំងនេះនៅសល់ស្លាកស្នាមរហូតមកដល់សព្វថ្ងៃ។ ជាពិសេសឯកសារមួយបង្ហាញនូវព័ត៌មានលម្អិតគួរឲ្យព្រឺក្បាល អំពីបទពិសោធន៍របស់ជនរងគ្រោះដែលធ្លាប់ត្រូវបានគេឃុំ និងសួរចម្លើយនៅមន្ទីរសន្តិសុខរបស់មជ្ឈិមបក្ស។ នេះជារបាយការណ៍មួយសរសេរឡើងដោយកម្មាភិបាលម្នាក់នៅស-២១ ដែលពិពណ៌នាអំពីការសួរចម្លើយលេខាតំបន់ម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជា ឈ្មោះ កែ គឹមហួត។ រយៈពេលបីថ្ងៃ របាយការណ៍នេះលើកឡើងថា នៅថ្ងៃដំបូងទារុណកម្មដោយប្រើកម្លាំងបាយ ខ្លះត្រូវបានប្រើប្រាស់ ហើយអ្នកទោសសន្លប់បាត់ស្មារតី។ ពីរថ្ងៃក្រោយមក គាត់ត្រូវបានវាយសំពងម្ដងទៀត ហើយសុខភាពរបស់គាត់បានចុះខ្សោយទៅៗ ប៉ុន្តែគាត់នៅបន្តឆ្លើយថាគាត់មិនមែនជាជនក្បត់នោះទេ។ រសៀលស្អែកឡើង អ្នកទោសរូបនេះត្រូវបានវាយដំម្ដងទៀត ហើយត្រូវបានឆក់ខ្សែភ្លើង និងឲ្យស៊ីអាចម៍ពីរបីស្លាបព្រាពេញៗ។ កែ គឹមហួត បានប្រាប់កម្មាភិបាលស-២១ "ឲ្យវាយដំខ្ញុំស្លាប់ម្ដងទៅ"។ នៅយប់នោះគាត់ត្រូវបានគេឆក់ខ្សែភ្លើងម្ដងទៀត ម្ដងនេះមានសភាពធ្ងន់ធ្ងរ។ អ្នកទោសរូបនេះរវើរវាយ និងបានឆ្លើយសារភាពបន្តិច ទោះបីជារងទារុណកម្មគួរឲ្យខ្លាចផ្សាក៏ដោយ ក៏ កែ គឹមហួត នៅតែប្រាប់អ្នកសួរចម្លើយថា នឹងបិទភ្នែកគាត់រង់ចាំសេចក្ដីស្លាប់។ អ្នកសួរចម្លើយនៅស-២១ បញ្ចប់របាយការណ៍ខ្លួនដោយសរសេរថា "មាគ៌ាអនុវត្តរបស់ខ្លួនគឺបន្តធ្វើទារុណកម្មដោយម្ចាស់ការពីព្រោះខ្មាំងកំពុងបាក់ស្មារតីនិងស្លាប់នៅទីបញ្ចប់"។ អ្នកសួរសម្លើយរូបនេះស្នើសុំមតិយោបល់និងការណែនាំពីអង្គការក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន។ គាត់បានសុំមតិយោបល់និងការណែនាំអំពីអង្គការក្នុងការអនុវត្តការងារនេះ។ ឯកសារមួយនេះបង្ហាញប្រាប់យើងទាំងអស់គ្នាជាក់ច្បាស់ផងដែរអំពីភាពគួរឲ្យតក់ស្លុតនៅស-២១។ នេះហើយជាវិធីដែលបក្សកុម្មុយនីស្តកម្ពុជាបានធ្វើមកលើមេដឹកនាំរបស់ខ្លួនម្នាក់ដែលបានចូលបដិវត្តន៍នៅក្នុងឆ្នាំ១៩៧៧។

[១០:២០:៣៣]

លោក លោកស្រី ចៅក្រម របាយការណ៍ទាំងឡាយដូចរបាយការណ៍មួយនេះ ដែលមានសង្ខេបអំពីការសួរចម្លើយនិងទារុណកម្មអ្នកទោសនៅស-២១ គឺជាផ្នែកមួយនៃឯកសារដែល ឌុច បានបញ្ជូនទៅថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះវាគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេថា នួន ជា បានទទួលស្គាល់ប្រាប់ ថេត សម្បត្តិ ថា គាត់បានដឹងថាអ្នកទោសដែលជាប់ឃុំឃាំងនៅស-២១ តាមទម្លាប់ធម្មតាត្រូវ

គេធ្វើទារុណកម្ម។ ដោយ នួន ជា បាននិយាយថា, ខ្ញុំសូមដកស្រង់៖ "ជាធម្មតាអ្នកទោសទាំងនោះបានសារភាពនៅពេលដែលខ្លួនត្រូវបានវាយដំយ៉ាងឃើចាប់និងរងការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ"។

ក្នុងរយៈពេលបន្តិចទៀតនាព្រឹកនេះ សហព្រះរាជអាជ្ញាអន្តរជាតិនឹងលើកឡើងអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មទាំងនេះ។

ការដាក់បទបញ្ញាលើការរៀបអាពាហ៍ពិពាហ៍។

ប្រធានបទចុងក្រោយនេះ ដែលខ្ញុំនឹងលើកឡើងនៅព្រឹកនេះ គឺឧក្រិដ្ឋកម្មនៃការរៀបការអាពាហ៍ពិពាហ៍ដោយបង្ខំ។ ទោះបីជាបុរសនិងស្ត្រីកម្ពុជា ត្រូវបានរងគ្រោះដោយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ផលវិបាកភាគច្រើនកើតឡើងលើស្ត្រីនៅក្នុងប្រទេសនេះ។ ចំពោះអ្នកដែលមានភ័ព្វវាសនាផ្សំផ្គុំជាមួយដៃគូចូលចិត្ត និងមានចិត្តអាណិតអាសូរ ហើយគោរពតាមបំណងប្រាថ្នារបស់ពួកគេនោះ អាពាហ៍ពិពាហ៍ដោយបង្ខំទំនងជាមិនកើតជាឧក្រិដ្ឋកម្មដ៏អាក្រក់បំផុត ដែលពួកគេបានឆ្លងកាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ ក៏ប៉ុន្តែ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ គឺជាការរំលោភជាមូលដ្ឋានលើសិទ្ធិសេរីភាពរបស់ពួកគេ។ ចំពោះអ្នកផ្សេងទៀតដែលលោក លោកស្រីជាចៅក្រមនឹងស្តាប់សក្ខីកម្មជាច្រើនពីពួកគេនៅក្នុងការជំនុំជម្រះនេះ។

[១០:២២:៤២]

ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺទម្រង់មួយនៃការធ្វើទារុណកម្មប្រចាំថ្ងៃ ពោលគឺការដាក់ឲ្យទៅជាទាសករជាមួយនឹងអ្នកដែលពួកគេពុំធ្លាប់ស្គាល់និងពុំដែលស្រឡាញ់។ ការដាក់ឲ្យទទួលរងនូវការបំពារបំពាននិងការរំលោភសេពសន្ថវៈ។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាឧទាហរណ៍មួយទៀតនៃរបបខ្មែរក្រហម ដែលបានប្រើប្រាស់អំណាចធ្វើជាម្ចាស់កម្មសិទ្ធិលើមនុស្ស។ ពោលគឺការចាត់ទុកប្រជាពលរដ្ឋកម្ពុជាដូចជាទ្រព្យសម្បត្តិ ដូចជាសត្វធាតុ ដើម្បីយកទៅបង្កាត់ពូជជាមួយនឹងដៃគូដែលម្ចាស់កម្មសិទ្ធិជាអ្នកជ្រើសរើស។

ផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីកម្ទេចរចនាសម្ព័ន្ធគ្រួសារចាស់ និងដាក់បុគ្គលម្នាក់ៗនៅក្រោមឆន្ទៈរបស់បក្ស សូម្បីតែក្នុងបញ្ហាបុគ្គល ដូចជាការរៀបអាពាហ៍ពិពាហ៍នេះជាដើម។ នោះត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងសេចក្តីណែនាំរបស់បក្ស ចុះឆ្នាំ១៩៧៥ ចំណងជើងថា "លោកទស្សនៈបដិវត្តន៍ និង មិនបដិវត្តន៍ចំពោះបញ្ហាកសាងគ្រួសារ"។ ឯកសារនេះចុះផ្សាយ -- បោះពុម្ពផ្សាយមួយនេះរបស់បក្សកុម្មុយនីស្តកម្ពុជា រួមមាន ការណែនាំជាក់លាក់ស្តីអំពីការជ្រើសរើសប្តីប្រពន្ធដោយបាន

លើកឡើងថា "ក្នុងបញ្ហាកសាងគ្រួសារនេះ បើអង្គការសមូហភាពជាអ្នកពិនិត្យឃើញយ៉ាងណា សម្រេចយ៉ាងណា ត្រូវគោរពដាច់ខាត កុំទោមនស្ស កុំថ្នាំងថ្នាក់ ព្រោះមានតែអង្គការមានតែសមូហភាពទេដែលអាចពិនិត្យមើលបានហ្មត់ចត់និងគ្រប់ជ្រុងជ្រោយបាន"។

សហព្រះរាជអាជ្ញានឹងបង្ហាញនៅក្នុងការជំនុំជម្រះនេះដែរ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានធ្វើឡើងនៅគ្រប់តំបន់ និងគ្រប់អង្គការចាត់តាំងនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងតាមក្រសួងនៅក្រុងភ្នំពេញ ក្រោមការមើលការខុសត្រូវរបស់ជនជាប់ចោទ។ សហព្រះរាជអាជ្ញានឹងស្នើសុំឲ្យអតីតកម្មាភិបាលម្នាក់មកពីក្រសួងពាណិជ្ជកម្មមកធ្វើជាសក្ខីកម្មសម្រាប់អង្គជំនុំជម្រះ ដែលក្រសួងនេះស្ថិតនៅក្រោមការមើលការខុសត្រូវរបស់ ខៀវ សំផន និងអតីតកម្មាភិបាលម្នាក់មកពីក្រសួងសង្គមកិច្ចដែល នួន ជា ជាអ្នកមើលការខុសត្រូវ។ អ្នកទាំងពីរនេះត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍នៅក្នុងក្រសួងរបស់ខ្លួនរៀងៗខ្លួន និងអាចពិពណ៌នាអំពីការដឹងឮ និងការចូលរួមរបស់មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងឧក្រិដ្ឋកម្មទាំងនេះ។

[១០:២៥:១២]

លោក លោកស្រី ចៅក្រម នឹងស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលធ្លាប់រស់នៅតាមតំបន់ផ្សេងៗនៅក្នុងប្រទេសនេះ ក៏ប៉ុន្តែអ្នកទាំងនេះមានបទពិសោធន៍ដូចជាប្រហែលដោយសារលទ្ធផលនៃកម្មវិធីដែលធ្វើឡើងដោយមជ្ឈិម។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវបានចេញបញ្ជារៀបចំ និងធ្វើឡើងដោយកម្មាភិបាលមូលដ្ឋានរបស់បក្សកុម្មុយនីស្តកម្ពុជា ពិធីក្នុងទ្រង់ទ្រាយធំដែលពេលខ្លះ រួមមាន ១០០គូ រៀបអាពាហ៍ពិពាហ៍ក្នុងពេលជាមួយគ្នា។ បុរសនិងនារីមិនដែលត្រូវបានគេបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍នោះទេ។ ពួកគេក៏ត្រូវបានកងឈ្លបនៃកងបក្សកុម្មុយនីស្តកម្ពុជាតាមដាននិងបង្ខំឲ្យរួមដំណេកជាមួយនឹងគ្នាផងដែរ។ ពោលគឺ ត្រូវបានបង្ខំដោយអាជ្ញាធរទាំងនេះ ឲ្យពួកគេរួមដំណេក ផ្ទុយនឹងឆន្ទៈរបស់ពួកគេ។

លោក លោកស្រី ចៅក្រម នឹងស្តាប់សក្ខីកម្មនៅក្នុងការជំនុំជម្រះនេះដែរ ពីស្ត្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានគេរំលោភសេពសន្ថវៈដោយសារគោលនយោបាយ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា។ ស្ត្រីទាំងនេះមានសេចក្តីក្លាហានមកជម្រាបតុលាការនេះអំពីបទពិសោធន៍ដ៏គួរឲ្យតក់ស្លុតរបស់ពួកគាត់ ដែលបានបន្សល់ទុកនូវស្លាកស្នាមជាច្រើននៅក្នុងជីវិតរបស់ពួកគាត់ ពីព្រោះតែគោលបំណងនៃគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់

បក្សកុម្មុយនីស្តកម្ពុជាពុំមែនត្រឹមតែដើម្បីគ្រប់គ្រងទាំងស្រុងលើបុគ្គលនោះទេ ប៉ុន្តែថែមទាំងដើម្បីបង្កើនចំនួនប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងនោះ ដូច្នេះជនជាប់ចោទទទួលខុសត្រូវនូវព្រហ្មទណ្ឌចំពោះការរំលោភសេពសន្ថវៈ ដែលបានកើតឡើងទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះផងដែរ។

[១០:២៧:១១]

លោក លោកស្រី ចៅក្រម! សហព្រះរាជអាជ្ញាសង្ឃឹមថានឹងអាចស្វែងរកយុត្តិធម៌ក្នុងការជំនុំជម្រះនេះសម្រាប់ជនរងគ្រោះនៃការរំលោភសេពសន្ថវៈសម្រាប់អ្នកដែលត្រូវបានដាក់ឱ្យទៅជាទាសករនៅក្នុងសហករណ៍ និងការដ្ឋានការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ និងសម្រាប់អ្នកដែលត្រូវបានកំណត់គោលដៅថាជាខ្មាំង ហើយត្រូវបានឃុំខ្លួន ធ្វើទារុណកម្ម និងសម្លាប់ចោលនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់នានាដែលជាផ្នែកមួយនៃការជំនុំជម្រះនេះ។

ហើយមុនបញ្ចប់សូមថ្លែងអំណរគុណចំពោះការសន្និដ្ឋានបញ្ចប់របស់ខ្ញុំ។ ហើយខ្ញុំនឹងប្រគល់វេទិកានេះទៅសហការីរបស់ខ្ញុំជាបន្តទៀត។ ចាស សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ តែមុននឹងសម្រាក អង្គជំនុំជម្រះសូមសួរទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តាមអង្គជំនុំជម្រះបានទទួលព័ត៌មានក្រៅផ្លូវការថា មានដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមទាមទារដាក់ញត្តិមកអង្គជំនុំជម្រះដោយផ្ទាល់ពាក់ព័ន្ធនឹងសំណងរដ្ឋប្បវេណី ហើយគាត់មិនព្រមដាក់ញត្តិនេះតាមរយៈរដ្ឋបាលទេ។ ដូចដែលនៅក្នុងអំឡុងពេលនៃ -- តើបញ្ហានេះមានកើតមានមែនដែរឬទេ? ក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រី ចៅក្រម ហើយនិងអង្គជំនុំជម្រះទាំងមូល។ តាមការពិត ខ្ញុំពីព្រឹកមិញ ពេលមកដល់ គឺខ្ញុំបានជួបដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននៅតាមផ្លូវពីមុខអង្គជំនុំជម្រះនៅផ្លូវជាតិលេខ៤ នេះ។ បាទ គឺមានវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីពិតប្រាកដមែន។ ហើយនៅពេលសម្រាកនេះ យើងខ្ញុំនឹងទៅជួបពួកគាត់ទៀត ដើម្បីពិគ្រោះជាមួយពួកគាត់ ឬក៏ទទួលញត្តិរបស់គាត់ពីអ្វីដែលគាត់ចង់បាន។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោង ដប់មួយ ខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ សម្រាកចុះ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៩ នាទី ដល់ម៉ោង ១០:៥៤ នាទី)*

[១០:៥៤:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ អង្គជំនុំជម្រះសូមប្រកាសជម្រាបជូនដំណឹងដល់បុគ្គលសាធារណជនដែលមានបំណងដាក់ញត្តិ ឬក៏បណ្តឹងផ្សេងៗមកអង្គជំនុំជម្រះឲ្យបានជ្រាបថា អង្គជំនុំជម្រះសាលាដំបូងមិនទទួលញត្តិអ្វីដោយផ្ទាល់ទេ។ រាល់ញត្តិ ឬពាក្យបណ្តឹងសូមដាក់តាមច្រកដែលសមស្រប ស្របតាមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

បាទ ជាកិច្ចបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីឡើងធ្វើសេចក្តីថ្លែងសន្និដ្ឋានបើកបន្តពីសហព្រះរាជអាជ្ញាជាតិ។ សូមអញ្ជើញបាទ!

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន លោកស្រីចៅក្រមជាទីគោរព! ដើមបណ្តឹងរដ្ឋប្បវេណី TCCP-98 គឺជាស្ត្រីមកពីក្រូចឆ្មារ បាននិយាយនៅក្នុងកិច្ចសម្ភាសន៍ថា៖ “នៅក្នុងឆ្នាំ៧៨ ក្រុមខ្មែរក្រហមមួយក្រុមមកពីភូមិភាគនិរតីបានចូលមកដល់កន្លែងខ្ញុំរស់នៅ។ ពួកគេស្វែងរកចាមដើម្បីអាចបោសសម្អាតអ្នកជនជាតិចាមចុងក្រោយក្នុងចំណោមយើង។ សមាជិកខ្ញុំមានប្រាំបីនាក់។ សមាជិកគ្រួសារខ្ញុំមានប្រាំបីនាក់ ត្រូវបានគេសម្លាប់ចោល។ ខ្ញុំនៅរស់ដោយសារតែខ្ញុំក្លែងខ្លួនជាពូជសាសន៍ផ្សេង”។ នៅក្នុងការជំនុំជម្រះ០០២/០២

គឺមានបទចោទពីរលើអំពើប្រល័យពូជសាសន៍លើជនជាតិចាម និង ជនជាតិវៀតណាមលើប្រទេសកម្ពុជា។ អំពើប្រល័យពូជសាសន៍ជាឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ។ ឧក្រិដ្ឋកម្មនេះពុំមានឋានុក្រមនោះទេ។ បានន័យថាវាមិនមានការចាត់ថ្នាក់ថាវាធ្ងន់ធ្ងរជាងឧក្រិដ្ឋកម្មណាមួយផ្សេងនោះទេ។ ដូច្នេះអំពើប្រល័យពូជសាសន៍ គឺជាអំពើមួយចំនួនដែលធ្វើឡើងក្នុងចេតនាបំផ្លាញមួយផ្នែក ឬទាំងស្រុង លើជនជាតិពន្ធុជាតិសាសន៍ សាសនា ឬក៏ជាតិសាសន៍ណាមួយ។ អំពើទាំងអស់នោះអាចសម្លាប់សមាជិកក្រុមបណ្តាលឲ្យមានព្យសនកម្មផ្នែកស្មារតី និង រាងកាយធ្ងន់ធ្ងរ បង្កលក្ខខណ្ឌដោយចេតនាទៅលើជីវិតដើម្បីឲ្យមានការបង្ក -- និងការរារាំងការបង្កកំណើត។ នៅក្នុងនិយមន័យនេះ ទាក់ទងនឹងមួយផ្នែក ឬទាំងស្រុងនោះវាតម្រូវឲ្យអំពើប្រល័យពូជសាសន៍ថា អំពើដែលធ្វើឡើងនេះ ធ្វើឡើងចំពោះជាតិពន្ធុ ពូជសាសន៍ និង ជនជាតិ មិនចាំបាច់ធ្វើលើក្រុមនយោបាយនោះទេ ត្រូវតែប្រព្រឹត្តឡើងលើក្រុមពួកសេដ្ឋកិច្ច។ ដូច្នេះមានន័យថា ប្រជាជនថ្មីដែលជាអ្នកប្រឆាំងនយោបាយមិនចាត់ចូលទៅក្នុងនិយមន័យនៃអំពើប្រល័យពូជសាសន៍នោះទេ។ បញ្ញាជនក៏មិនស្ថិតនៅក្នុងនិយមន័យនៃអំពើប្រល័យពូជសាសន៍នោះផងដែរ។ ដូច្នេះយើងត្រូវចងចាំថា នៅក្នុងរឿងក្តីនេះ ជនរងគ្រោះភាគច្រើន ឧក្រិដ្ឋកម្មភាគច្រើនដែលយកមកជំនុំជម្រះត្រូវបានប្រព្រឹត្តឡើង ធ្វើឡើងចំពោះក្រុមជនជាតិខ្មែរទាំងអស់នេះ ដោយសារតែបញ្ហាវណ្ណៈ សេដ្ឋកិច្ច ហើយត្រូវបានគេចាត់ថ្នាក់ថាជាបញ្ញាជន ហើយជាអ្នកប្រឆាំងទៅនឹងរបប។ អ្នកទាំងអស់នេះត្រូវបានបញ្ចូលនៅក្នុងបទចោទដែល ខៀវ សំផន និង នួន ជា ប្រឈមនឹងការជំនុំជម្រះនៅក្នុងរឿងក្តីនេះជាពិសេសគឺការសម្លាប់រង្គាល។ ក៏ប៉ុន្តែនៅក្នុងរឿងក្តីនេះ ភស្តុតាងបានបង្ហាញថាធាតុផ្សំនីមួយៗនៃអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងក្រុមទាំងពីរ គឺជនជាតិចាម និង វៀតណាម។

[១០:៥៩:៣៧]

យុត្តិសាស្ត្រនៅក្នុងច្បាប់អន្តរជាតិលើកឡើងថា “វាមិនចាំបាច់សម្លាប់គ្រប់បុគ្គលទាំងអស់ ឬមានចេតនាសម្លាប់បុគ្គលទាំងអស់នោះទេ វាចាំបាច់មានចេតនាបំផ្លាញក្រុមណាមួយផ្នែក ឬទាំងស្រុង គឺគ្រប់គ្រាន់”។ នេះចំណុចសំខាន់ ថាក្រុមដែលសំខាន់។ ក្រុមដែលសំខាន់នោះដែលវាធ្វើឲ្យប៉ះពាល់ទៅដល់ការរស់រានមានជីវិត។ នៅសាលដីកា ស្រ៊ិប្រេនីសា *(Srebrenica)* រឿងក្រេស្ទីក នៅក្នុងតុលាការកំពូល គេឲ្យមើលកត្តាចំនួនបីដែលមានពាក់ព័ន្ធទៅនឹងការកាប់សម្លាប់ គឺចំនួនភាគរយអ្នកដែលត្រូវបានគេសម្លាប់ ឬក៏ចំនួនអ្នកដែលត្រូវបានគេសម្លាប់ ហើយសំខាន់ដែលយើងត្រូវមើលទៅលើប្រភពនៃក្រុមដែលគេយកទៅសម្លាប់ចោល។ នៅក្នុងកថាខណ្ឌ១២ នៃសាលដីកានេះ អង្គជំនុំជម្រះលើកឡើងថា៖

"ប្រសិនបើក្រុមជាក់លាក់ណាមួយគឺជាតំណាង គឺជានិមិត្តរូបនៃក្រុមរួម ហើយវាជាសំខាន់សម្រាប់ការរស់រានមានជីវិតរបស់ពួកគេ ចំណុចនេះ គឺបានបំពេញផ្នែកមួយដែលសំខន់នៃក្រុម"។ ក្នុងកថាខណ្ឌ៨២នៃសាលក្រមរបស់នៅស្រ៊ុប្រេនីសា ហើយនិងកថាខណ្ឌ៦៥ សំណើសុំឲ្យច្រានចោលលើកលែងការចោទ -- ដោះលែងឲ្យរួចខ្លួននោះ គឺបានទទួលស្គាល់ថា ការគោលដៅទៅលើថ្នាក់ដឹកនាំ ដែលយ៉ាងហោចណាស់ត្រូវតែបង្ហាញថាអ្នកទាំងអស់នេះ ចង់បំផ្លាញផ្នែកណាមួយនៃ -- នៅក្នុងក្រុមដ៏សំខាន់នោះ។ យើងត្រូវធ្វើការបែងចែកចេតនាចេញពីមូលហេតុ ចេតនានោះគឺត្រូវបំផ្លាញក្រុម។ មូលហេតុនោះមិនមែនថា មិនមែនយើងត្រូវផ្តោតទៅលើមូលហេតុដែលថាគេចង់រក្សាអំណាចនោះទេ យើងត្រូវផ្តោតទៅលើចេតនាក្នុងការបំផ្លាញ។

[១១:០១:៣៨]

នៅក្នុងកថាខណ្ឌ៤៤ រឿងក្តី ជេឡូស៊ីក ហេតុផលបុគ្គលរបស់ចារីទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អាចគឺដោយសារទាញប្រយោជន៍ផ្នែកនយោបាយ។ ចំណុចនេះអាចបង្ហាញថាវាមានអំពើប្រល័យពូជាសាសន៍កើតឡើង។ ដូច្នេះ ប្រសិនបើជនជាតិចាមនិងវៀតណាមត្រូវបានគេកំណត់គោល-ដៅដូចក្នុងករណីរឿងក្តីនេះ ដោយសារជនជាប់ចោទនិងមេដឹកនាំដទៃទៀតនៅក្នុងរបបខ្មែរក្រហមចាត់ទុកថា ពួកគេជាខ្មាំង ចំណុចនេះគឺថាមិនអាចបង្ហាញថា វាជាអំពើប្រល័យពូជសាសន៍នោះទេ។ យើងត្រូវបង្ហាញអំពីចេតនាក្នុងការបំផ្លាញក្រុមនោះមួយផ្នែក ឬក៏ទាំងស្រុង។ សាក្សី TCW-641 បានលើកឡើងថា៖ "ខ្ញុំត្រូវបានគេប្រាប់ថា ចាមគឺជាពូជសាសន៍មួយផ្សេង ត្រូវតែកម្ទេចចោល។ ប្រសិនបើយើងទុកពួកគេ ពួកគេនឹងប្រឆាំងយើងនៅពេលណាមួយ"។ សាក្សីមួយទៀត TCW-813 លើកឡើងថា៖ "យើងមិនត្រូវបានគេអនុញ្ញាតឲ្យគោរពសាសនាចាមនោះទេ ហើយនិយាយភាសាចាមឡើយ។ ស្ត្រីត្រូវបានគេតម្រូវឲ្យកាត់សក់ខ្លី ហើយយើងត្រូវបានគេបង្ខំឲ្យហូបរួម ហើយនិងហូបសាច់ជ្រូក"។ គ្មានការពន្យល់ពីខ្មែរក្រហមឲ្យយើងយល់ពីបញ្ហានោះទេ។ ហើយអ្នកដែលបដិសេធមិនធ្វើតាមគេត្រូវបានគេយកទៅសម្លាប់ចោល"។

ដូច្នេះ មិនមែនជាចំណុចសំខាន់ដែលថាចេតនាត្រូវតែសម្លាប់គ្រប់សមាជិកនៅក្នុងក្រុមនោះទេ។ ដរាបណាគេមានចេតនាបំផ្លាញក្រុមដ៏សំខាន់ដើម្បីរស់រានមានជីវិតនោះ គឺគ្រប់គ្រាន់ក្នុងការបង្ហាញអំពើប្រល័យពូជាសាសន៍។ នៅក្នុងសៀវភៅរបស់ ឃៀរនិន ,ឯកសារ E3/1593, តារាងទី៤, បានសន្និដ្ឋានថា មានមួយភាគបួន ជនជាតិចាមមានមួយភាគបួននៅដើមដំបូងនៃរបបនោះ ហើយមាន៩០.០០០នាក់

ជនជាតិចាម ៩០.០០០នាក់ ត្រូវបានស្លាប់។ អ៊ីសា ឧស្មាន, E3/1833, ក៏បានធ្វើការសន្និតថា "នៅដំបូងជនជាតិចាមមាន ៧០០.០០០នាក់ ក្រោយមកប្រហែលជា ២០០.០០០នាក់ ត្រូវបានសម្លាប់ចោល"។ ដូច្នេះ វាគិតជាភាគរយប្រហែលជា ៧០ជាងភាគរយ។

[១១:០៥:០០]

សាក្សីចុងក្រោយដូចដែលខ្ញុំបានលើកឡើង ទោះបីជាចេតនាមិនមានបំណងបំផ្លាញ កម្ទេចក្រុមគ្រប់សមាជិកម្នាក់ៗនៅក្នុងក្រុមក៏ដោយ ក៏ប៉ុន្តែចេតនាគឺបំផ្លាញក្រុម។ ទី១ ចេតនានោះគឺ តាមរយៈភស្តុតាង គឺគេត្រូវកំណត់គោលដៅកន្លែងដែលជនជាតិចាមរស់នៅតាមទន្លេមេគង្គ។ មួយនៅទីតាំងមួយគឺថានៅភូមិភាគខាងកើត គឺនៅក្រូចឆ្មារនិងកងមាស។ ទាំងតាំងទាំងពីរនេះ គឺគេបានទៅដើម្បីកម្ទេចជនជាតិចាម ហើយទីតាំងទាំងពីរនោះហើយដែលជាកន្លែងជនជាតិចាមរស់នៅ។

សាក្សីចុងក្រោយដូចដែលខ្ញុំបានអាននោះ ដូចដែលខ្ញុំបានយកមកដកស្រង់នោះ ក៏បានបង្ហាញថាអ្នកដែលត្រូវបានគេសម្លាប់ចោល គឺគាត់ចង់ -- ពួកគាត់ចង់រក្សាការអនុវត្តរបស់ពួកគេ និងការគោរពសាសនា ហើយពួកគេ អ្នកទាំងអស់នោះ គឺចង់និយាយភាសារបស់ពួកគេ។ ដូច្នេះហើយទើបត្រូវបានគេយកទៅសម្លាប់ចោល។ អ្នកទាំងអស់នោះចង់រក្សាអត្តសញ្ញាណរបស់ពួកគេ។ ដូច្នេះ ប្រសិនបើយើងសម្លាប់ដើម្បីកម្ទេចអត្តសញ្ញាណ បានន័យថាយើងចង់បំផ្លាញក្រុមរបស់ពួកគេ។ បានន័យថា អ្នកទាំងអស់នោះមិនអាចរក្សាអត្តសញ្ញាណ មិនមានសិទ្ធិប្រើប្រាស់ភាសារបស់ពួកគាត់។ ដូច្នេះ ក្នុងករណីនេះក្រុមរបស់ពួកគាត់ត្រូវបានបំផ្លាញចោល។ យើងមើលតារាងទី១ ដែលនៅក្នុងសៀវភៅរបស់ ឃៀរនិនតារាងទី១ គឺបានបង្ហាញថា តើមេដឹកនាំសាសនាចាមនោះក៏ត្រូវបានគេកំណត់គោលដៅផងដែរ។ មេដឹកនាំសហគមន៍ ហា កែម គឺយើងឃើញថាមាន ៨០ជាងភាគរយត្រូវបានសម្លាប់ចោល ហើយចំពោះអ្នកដែលជារងរបស់ពួកគេនោះគឺថា គឺត្រូវបានគេសម្លាប់ចោល ៩០ភាគរយ ហើយ ហាជី នេះគឺថាប្រហែលជា ៩៧ភាគរយត្រូវបានសម្លាប់ចោល។ អ្នកទាំងអស់នេះ គឺជាក្រុមមួយចុងក្រោយ វាក្រុមដ៏សំខាន់។ ហាជី គឺជាក្រុមមួយសំខាន់នៅក្នុងសហគមន៍។ បានន័យអ្នកទាំងអស់នេះ កាលពីឆ្នាំ១៩៧៥មានជាង១០០០នាក់ ហើយនៅឆ្នាំ១៩៧៩ មានតែប្រហែល៣០នាក់ ប្រហែល៣០នាក់ប៉ុណ្ណោះត្រូវបានសម្លាប់ -- នៅរស់រានមានជីវិត។ ដូច្នេះប្រហែលជា ៩៧ភាគរយត្រូវបានសម្លាប់ចោលក្រោយពីរបបនោះ។

[១១:០៦:៣១]

ចំពោះអំពើប្រល័យពូជសាសន៍លើវៀតណាមមានលក្ខណៈខុសពីនេះ។ ភស្តុតាងគេបានបង្ហាញអំពីគោលនយោបាយលើជនជាតិវៀតណាម ហើយមានការវិវត្តន៍នៅក្នុងរបបនោះ។ គឺនៅដើមដំបូងនៃរបបនោះ គឺគោលបំណងនៃរបបនោះគឺធ្វើការផ្លាស់ប្តូរទីលំនៅរបស់វៀតណាម បន្ទាប់មកបណ្តេញចេញពួកគេចេញពីប្រទេស។ ឆ្នាំក្រោយៗមកទៀត ឆ្នាំ៧៧, ៧៨ យើងឃើញគោលនយោបាយនៃរបបនោះបានកែប្រែនិងផ្លាស់ប្តូរ គឺគេបានចាប់ផ្តើមសម្លាប់ជនជាតិវៀតណាមនៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ។ ចំណុចនេះហើយដែលថា អ្នកដែលជាកងទ័ពនោះ គឺថាត្រូវបានកំណត់អត្តសញ្ញាណជនជាតិវៀតណាមដើម្បីសម្លាប់ចោល។ ឯកសារ E3742 គឺជាទង់ទស្សនាវដ្តីទង់បដិវត្តខែមេសា ឆ្នាំ១៩៧៧ នៅក្នុងនោះគឺមានចំណុចដកស្រង់មួយ "គឺ សេ.អ៊ី.អា ហើយនិងភ្នាក់ងាររបស់ពួកគេ ខេ.ជី.ប៊ី គឺពួកដែលយួនជាអ្នកលេបទឹកដី"។ អ្នកទាំងអស់នេះ គឺជាអ្នកចង់បំផ្លាញកងទ័ពប្រជាជនរបស់យើង។ ដូច្នេះយើងត្រូវតែបោសសម្អាតពួកគេ ហើយធ្វើយ៉ាងណាឲ្យបោសសម្អាតពួកគេឲ្យបានស្អាត។ ដូច្នេះបានន័យថា "បោសសម្អាតនិងធ្វើឲ្យស្អាត" នោះមានន័យថា "សម្លាប់ពួកគេចោល"។

ប្រសិនបើយើងមើលរបាយការណ៍មួយទៀត ផ្ញើមកពីភូមិភាគពាយ័ព្យទៅមេដឹកនាំទីក្រុងថ្ងៃទី ១៧ ខែឧសភា ឆ្នាំ៧៨ គេបានសួរចោទសួរសំណួរទៅមេដឹកនាំជាន់ខ្ពស់។ "យួនដែលមានប្តី ឬប្រពន្ធខ្មែរ ហើយជាកូនកាត់ខ្មែរយួននោះ កិច្ចប្រជុំចង់សួរអង្គការ៨៧0 ថាតើធ្វើយ៉ាងម៉េចចំពោះពួកគេ? សូមឲ្យអង្គការសម្រេចនិងផ្តល់ការណែនាំ"។ អង្គការ៨៧0នេះ ជាថ្នាក់ដឹកនាំមួយជាន់ខ្ពស់នៃរបបខ្មែរក្រហមថាតើគោលនយោបាយនោះអនុវត្តដោយរបៀបណា។ យើងនឹងស្តាប់សាក្សី TCW-820 លើកឡើងថា៖ "ជនជាតិវៀតណាមត្រូវបានគេចាប់ខ្លួនសម្លាប់ចោល" កម្មាភិបាលបានប្រកាសថា៖ "ប្រសិនបើឪពុកជាយួន ជាវៀតណាម គឺគេយកតែឪពុកទៅសម្លាប់ចោលតែប៉ុណ្ណោះ ប៉ុន្តែប្រសិនបើម្តាយជាជនជាតិវៀតណាម គេនឹងយកម្តាយទាំងកូនសម្លាប់ទាំងអស់ ដោយសារកូននោះជញ្ជក់ទឹកដោះពីម្តាយ"។

[១១:០៩:០៨]

ដូចគ្នាដែរ TCW-95 បានលើកឡើងថា៖ "គ្មាននរណាម្នាក់នៅរស់នោះទេ ប្រសិនបើជាប់ពាក់ព័ន្ធនឹងយួន។ ប្រសិនបើប្តីជាប់ពាក់ព័ន្ធនឹងយួន គឺគេយកប្តីទៅ ប្រសិនបើប្រពន្ធជាប់ពាក់ព័ន្ធនឹងយួនគឺយកទាំងប្រពន្ធនិងកូនចេញទៅ"។ TCW-949លើកឡើងនៅក្នុងឆ្នាំ១៩៧៨ថា៖"គាត់ឮសំឡេងមនុស្សស្រែកហើយខ្ញុំឃើញខ្មែរក្រហមយកដំបងពីងពង់ឫស្សីប្រហែលមួយម៉ែត្រយកទៅវ៉ៃសម្លាប់ចោល។ អ្នកដែលទាំងអស់នោះសួរថា៖ អ្នកឯងជាយួន តើមែនដែរឬទេ? បន្ទាប់មកខ្មែរក្រហមបានស្រែក ហើយពួកគេ

ត្រូវបានសម្លាប់អ្នកទាំងអស់នោះចោល"។

TCW-868 បានលើកឡើងថា "តាមខ្ញុំសន្និដ្ឋានប្រហែលជា ៦០០ទៅ៧០០ ជនជាតិវៀតណាម ៦០០ ទៅ៧០០នាក់ ត្រូវបានគេសម្លាប់ចោលនៅក្នុងពេលនោះ។ ពួកគេសម្លាប់គ្រួសារទាំងមូល បុរស ស្ត្រី និង កូន។ ខ្ញុំនៅចាំនារីក្មេងស្រីម្នាក់ដែលស្ថិតនៅក្នុងកងចល័ត ហើយពួកគេបានធ្វើការរះពោះកុមារីនោះទាំងរស់"។ យៀរនិន បានលើកឡើងអំពីបញ្ហានៃក្រុមនេះនៅក្នុងរបបនោះ។ យៀរនិន បានលើកឡើងសន្និតថា៖ "មានវៀតណាម ១០.០០០នាក់នៅទីក្រុង ហើយ១០.០០០នាក់ នៅតាមជនបទក្នុងឆ្នាំ ១៩៧៥"។ ដូច្នេះបានន័យថា សរុបទៅ២០.០០០ គឺក្រោយពីរបបនោះគ្មាននរណានៅរស់នោះទេ។ ភស្តុតាងនេះបានបង្ហាញដោយបក្សកុម្មុយនីស្តកម្ពុជាខ្លួនឯង ប្រសិនបើយើងមើលទង់បដិវត្ត ខែមេសា ឆ្នាំ ១៩៧៨ "យួនហ្នឹងគឺយ៉ាងម៉េចដែរ? គ្មានយួនទេ នៅលើទឹកដីកម្ពុជា។ ពីមុនមានយួនហ្នឹងជិត១លាននាក់ ហើយនៅពេលនេះ សូម្បីគ្រាប់មួយគ្រាប់ក៏យើងរកមិនឃើញដែរ ចំពោះយួនហ្នឹង"។

[១១:១១:១២]

លោក លោកស្រី ចៅក្រម ជាទីគោរព! ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មផ្សេងទៀតដែលសហព្រះរាជអាជ្ញាជាតិបានរៀបរាប់ ឧក្រិដ្ឋកម្មទាំងអស់នេះកើតចេញពីលទ្ធផលនៃគោលនយោបាយមួយ។ ឧក្រិដ្ឋកម្មទាំងអស់នេះ ធ្វើឡើងដោយជាលក្ខណៈប្រព័ន្ធ មិនមែនដោយចោះៗតែប៉ុណ្ណោះនោះទេ មិនមែនកើតចេញពីបុគ្គលម្នាក់ៗនោះឡើយ។ ឧក្រិដ្ឋកម្មទាំងអស់នេះ វាអាចថាមិនមែនមែនជាគោលដៅរបស់ខ្មែរក្រហមចង់បានទេ ប៉ុន្តែឧក្រិដ្ឋកម្មទាំងអស់នេះ គោលដៅចុងក្រោយគឺចង់សម្រេចមនោគមវិជ្ជា។ បានន័យថា ចង់ឲ្យមានបដិវត្តកសិករឲ្យបានលឿន ហើយនិងដើម្បីរក្សាអំណាចរបស់ខ្លួន បានន័យថា រក្សាអំណាចរបស់ថ្នាក់ដឹកនាំខ្មែរក្រហម។ ដើម្បីធ្វើសម្រេចឲ្យការងារទាំងអស់នេះ ពួកគាត់បានប្រព្រឹត្តឧក្រិដ្ឋកម្ម និង យកមធ្យោបាយទាំងអស់នេះ យកមកធ្វើជាហេតុផលសម្រេចគោលដៅចុងក្រោយរបស់ពួកគេ។ ថាតើគោលនយោបាយនេះបញ្ជូនទៅកម្មាភិបាលថ្នាក់ក្រោមដោយរបៀបណា ទៅតាមភូមិដោយរបៀបណា។ យើងមិនមែននិយាយថា ការសម្លាប់គ្រប់ទាំងអស់បានបញ្ជាដោយ នួន ជា និង មេដឹកនាំដទៃទៀតនោះទេ ក៏ប៉ុន្តែគោលនយោបាយនេះបានបញ្ជូនទៅថ្នាក់ក្រោម។ បានន័យថា ទៅឲ្យថ្នាក់ក្រោមធ្វើការសម្លាប់បោសសម្អាត។

ដូច្នេះយើងដឹងហើយថា បុគ្គលដែលត្រូវបានចោទប្រកាន់នៅទីនេះ នួន ជា ជាអ្នកធ្វើការឃោសនាអប់រំ។ បុគ្គលរូបនេះ មានតួនាទីជាសាធារណៈនៅក្នុងរបបខ្មែរក្រហម នៅឆាក -- នៅក្នុងប្រទេសកម្ពុជា

ក៏ប៉ុន្តែនៅលើឆាកអន្តរជាតិគឺ ខៀវ សំផន ជាអ្នកតំណាង។ ឧក្រិដ្ឋកម្មទាំងអស់នេះ បានកើតឡើងចេញពីគោលនយោបាយ ដូច្នេះដើម្បីសម្រេចទស្សនវិស័យពួកគេនៅក្នុងប្រទេសកម្ពុជា ពួកគេស្ម័គ្រចិត្តលះបង់ធ្វើអ្វីគ្រប់យ៉ាង លះបង់បុគ្គលគ្រប់រូប ហើយប្រព្រឹត្តឧក្រិដ្ឋកម្មគ្រប់បែបយ៉ាងប្រឆាំងបុគ្គលទាំងអស់នោះដែលជាជនរងគ្រោះ។ បុគ្គលទាំងអស់នោះ គឺមិនខ្វល់ទេ ដូចដែល នួន ជា បានលើកឡើងអ៊ីចឹង នរណាក៏ត្រូវតែធ្វើឡើងដែរ។

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

"(នួន ជា៖) បើទុកពួកហ្នឹង អាហ្នឹងសម្លាប់ជាតិ ផ្ទាល់ខ្លួនណ៎ះ! វាតែងតែមានមនោសញ្ចេតនាអីខ្លះ ក៏ប៉ុន្តែខ្ញុំបែងចែកផ្ទាល់ខ្លួន ហើយនិងរួមច្បាស់។ បើរួម យើងយកផ្ទាល់ខ្លួនជាមនោសញ្ចេតនាផ្តាប់រាប់អានគ្នា ផ្តាប់អីគ្នា ហើយអានេះជាតិទាំងមូល តើយកពីណា? ខ្ញុំយកជាតិហើយ។ ហើយផ្ទាល់ខ្លួនទុកដោយឡែកសិន។ ដោះស្រាយសិនទៅ។ សៈ អ៊ីចឹងអ៊ំមានការសោកស្តាយចំពោះពេលនោះទេបាទ? (នួន ជា៖) ខ្ញុំដូចគ្មានការសោកស្តាយទេ"។

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:១៤:២០]

គោលនយោបាយលះបង់ និង សម្លាប់ចោលប្រជាពលរដ្ឋកម្ពុជា កើតឡើងសូម្បីមុនពេលខ្មែរក្រហមកាន់កាប់អំណាច បានន័យថា ដើម្បីរក្សាអំណាចពួកគេ។ ដូច្នេះវាបង្ហាញយ៉ាងច្បាស់ថាតើបុគ្គលនីមួយៗនោះលះបង់យ៉ាងម៉េចនៅពេលដែលចាប់បានទីក្រុងភ្នំពេញ ហើយធ្វើការជម្លៀសក្រុងភ្នំពេញកើតឡើងនៅពេលនោះ។ វាបង្ហាញថា សិទ្ធិរបស់បុគ្គលនៅក្នុងពេលនោះត្រូវបានបាត់បង់ លែងមានទៀត ហើយចំពោះប្រជាពលរដ្ឋកម្ពុជាទាំងអស់។ បានន័យថា ប្រជាពលរដ្ឋកម្ពុជាត្រូវបានគេបំបាត់សិទ្ធិ។ អ្វីដែលសំខាន់បំផុតនោះចំពោះខ្មែរក្រហម គឺគេចង់ធ្វើការគ្រប់គ្រងទាំងស្រុងទៅលើសង្គម។ បានន័យថាពួកគេនឹងបំផ្លាញតម្លៃ ប្រពៃណីខ្មែរ រួមមាន សាសនា ព្រះមហាក្សត្រ និង គ្រួសារ។ តើ នួន ជា និង ខៀវ សំផន ចង់ឲ្យចៅក្រមនៅក្នុងតុលាការនេះ និង អ្នកដែលកំពុងមើលនេះ ជឿថាព្រះសង្ឃនៅពេញប្រទេសកម្ពុជា គាត់លាចាកសិក្ខាបទដោយខ្លួនឯង ហើយភូមិកម្ពុជាត្រូវបានដុតវត្តនោះដោយខ្លួនឯង ឬក៏យ៉ាងណា។ ប្រសិនបើយើងមើលឯកសារ E3/99 ថ្ងៃ២២ ខែកញ្ញា ឆ្នាំ៧៥ បក្សបានធ្វើការអបអរសាទរខ្លួនឯង។ ព្រះសង្ឃភាគច្រើន ប្រហែលជាពី ៩០ ទៅ ៩៥ភាគរយ លះបង់ -- លាចាកសិក្ខាបទ។ វត្តដែលជាមូលដ្ឋានសំខាន់នោះ ត្រូវបានបោះបង់ចោល ហើយប្រជាជនលែងទៅវត្ត ហើយលែងធ្វើការ

ផ្តល់តិយទានទៀតហើយ។ ដូច្នេះ យើងសន្មតថា ៩០ ទៅ ៩៥ភាគរយនៃព្រះសង្ឃ និង ការគោរពសាសនាព្រះពុទ្ធលែងមានទៀតហើយ។ ដូច្នេះ កម្រិតសំខាន់នេះ បានន័យថា វណ្ណៈសំខាន់នេះលែងមានទៀតហើយ យើងលែងខ្វល់ លែងព្រួយបារម្ភទៀតហើយ។

[១១:១៦:៤៥]

ជាច្រើនឆ្នាំរហូតដល់ពេលមានឧក្រិដ្ឋកម្មនោះ ខៀវ សំផន និង នួន ជា បានអនុវត្តគោលនយោបាយ និងមានតួនាទីនៅក្នុងឧក្រិដ្ឋកម្មដែលបានកើតឡើងចំពោះប្រជាពលរដ្ឋកម្ពុជា។ យើងដឹងហើយថា មានការលើកឡើង លេស និង ការសោកស្តាយមួយចំនួនទៅលើបញ្ហាទាំងអស់នេះ។ ខៀវ សំផន បានលើកឡើងថា៖ "ខ្ញុំមិនមានអំណាច"។ គាត់បានប្រាប់កិច្ចសម្ភាសន៍ជាមួយវីអូអេ នៅក្នុងឆ្នាំ ២០០៧ថា៖ "ខ្ញុំមិនមែនជាមេដឹកនាំខ្មែរក្រហមនោះទេ"។ វាគឺជាការលើកឡើងយកលេសតែប៉ុណ្ណោះ។ ដែលថាគាត់ជាប្រមុខរដ្ឋនៃរបបខ្មែរក្រហម ហើយគាត់បានចូលរួមជាមួយខ្មែរក្រហមជាសមាជិកគណៈកម្មាធិការនៅក្នុងឆ្នាំ១៩៧៦ រហូតទៅដល់ឆ្នាំ១៩៧៨។ គាត់បានលើកឡើងថា គាត់មិនមានអំណាច ក៏ប៉ុន្តែនៅពេលមួយនោះ គាត់សម្ភាសជាមួយនឹង "ការប្រឈមអំពើប្រល័យពូជសាសន៍" គាត់បានទទួលស្គាល់អំពីតួនាទីសំខាន់របស់គាត់។ "រូបភាពរបស់ខ្ញុំ ឈ្មោះរបស់ខ្ញុំតំណាងប្រទេសកម្ពុជា។ ដូច្នេះហើយក្នុងនាមជាប្រធាន ខ្ញុំជឿថាខ្ញុំតំណាងខ្មែរ"។ ហើយ ប៉ុល ពត ព្យាយាមលាក់អត្តសញ្ញាណព្យាយាមមិនចេញមុខ។ ដូច្នេះ ខៀវ សំផន គឺជាបុគ្គលម្នាក់តំណាងខ្មែរក្រហមទាំងថ្នាក់ជាតិ និង អន្តរជាតិ។ គាត់បានប្រាប់វីអូអេ ក្នុងឆ្នាំ២០០៧ថា៖ "ជាប្រធាន ខ្ញុំជឿថា ខ្ញុំតំណាងខ្មែរទាំងមូល ហើយខ្ញុំបំពេញភារកិច្ចនេះជូនជាតិ"។ ក្នុងនាមជាសមាជិកគណៈកម្មាធិការ គឺគាត់បានលើកឡើងអំពីបញ្ហាទាំងអស់នេះ នៅក្នុងចំណោមកំណត់ហេតុប្រជុំចំនួន១៩ គឺ ខៀវ សំផន បានចូលរួមប្រជុំ ១៦ដង។ ប្រហែលជា ៨៤ភាគរយ។ ដូច្នេះ យើងឃើញថា ខៀវ សំផន បានចូលរួមប្រជុំ ១៦លើក ឬ ៨៤ភាគរយនៅក្នុងកំណត់ហេតុ។ ខៀវ សំផន ក៏បានអួតអាងអំពីការចូលរួមចំណែកដែលគាត់បំផ្លាញខាងរបបលន់នល់ផងដែរ ដែលគាត់បានចូលរួមបដិវត្ត ចូលរួមចំណែកក្នុងការធ្វើឱ្យរបបមុននោះបរាជ័យ។ ដូច្នេះថា តើគាត់មិនអាច -- គាត់អាចនិយាយយ៉ាងម៉េចថាគាត់មិនបានចូលរួមចំណែកនៅមុនឆ្នាំ១៩៧៥ នោះ? ហើយគាត់មិនមានអំណាច ហើយក្រោយមកគឺគាត់មិនបានចូលរួមចំណែក។ តើគាត់លើកចំណុចនេះយ៉ាងម៉េច? ក្រោយពេលខ្មែរក្រហមមានអំណាចគឺ ខៀវ សំផន មានអំណាចនៅក្នុងក្រុម។ ក្នុងឆ្នាំ ១៩៧៦ គាត់ជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម។ ឆ្នាំ១៩៧៦ គាត់បានជំនួស នរោត្តម សីហនុ

ជាប្រមុខរដ្ឋ។ បានន័យថា ជាគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។ យើងដឹងថា នៅក្នុងឆ្នាំ ១៩៧៧ ក្រោយចាប់ ឌឿន, ខៀវ សំផន បានក្លាយជាសមាជិកតែម្នាក់គត់នៅក្នុងមន្ទីរ៨៧០ ដែលជាមន្ទីរនេះជាសរសៃសស្នូងរបស់បក្ស ហើយជាមន្ទីរសម្របសម្រួលក្នុងការចាប់ខ្លួន ចុងក្រោយត្រូវនឹងសម្លាប់ចោល។

[១១:២០:១៥]

របាយការណ៍បានបង្ហាញ កំណត់ហេតុបានបង្ហាញថា ខៀវ សំផន ធ្វើបទឧទ្ទេសនាមទៅកម្មាភិបាល គាត់បានជួបជាមួយនឹងអគ្គរាជទូតនិងរដ្ឋទូត គាត់តំណាងកម្ពុជានៅបរទេស។ តើគាត់ធ្វើការងារអ្វីនៅធ្វើជាសាធារណៈនេះ នៅពេលដែលគាត់ឧទ្ទេសនាម ថ្លែងសន្ទរកថា ក្នុងនាមជាប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ តើអ្វីដែលគាត់ធ្វើនោះ គឺគាត់ភូតភរនិងលាក់បាំងឧក្រិដ្ឋកម្មនៃរបបនោះ។ ប្រសិនបើយើងមើលសុន្ទរកថា ថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៨ ឯកសារនោះបានឃើញមានអ្នកចូលរួម ២០.០០០នាក់ នៅក្នុងនោះគាត់បានលើកឡើងថា៖ "យើងបានសម្រេចនូវផែនការបង្កបង្កើនផល"។ គាត់បានលើកឡើងថា៖ "ថ្នាំសង្កូវរបស់យើងបានបំពេញនូវភាពចាំបាច់របស់ប្រជាពលរដ្ឋ"។ ហើយតើគាត់និយាយយ៉ាងម៉េចចំពោះប្រជាជនដែលស្លាប់ដោយសារខ្វះថ្នាំសង្កូវ និងការថែទាំវេជ្ជសាស្ត្រនោះ? "ប្រជាជនរបស់យើងគឺរីករាយជាមួយនឹងការវិវត្តន៍របបសម្ភហភាពនេះ" គាត់បានលើកឡើងដូច្នេះ។ ក្នុងពេលដែលប្រជាជនជាច្រើនរងនូវទាសភាព ហើយកំពុងតែព្យាយាមដើម្បីរស់នោះ តើគាត់ធ្វើយ៉ាងម៉េច ថ្លែងយ៉ាងម៉េចទៅកាន់អន្តរជាតិ? គឺការលះបង់ -- លាក់បាំងរបស់គាត់។

ដូច្នេះយើងឃើញថា យើងដឹងហើយថា ខៀវ សំផន បានលើកឡើងថា អំពីចំណុចទាំងអស់នេះ។ សហព្រះរាជអាជ្ញាបានព្យាយាមលើកឡើងចំណុចដូចដែលបានបញ្ជាក់។ ខៀវ សំផន បានសរសេរនៅក្នុងលិខិតថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ ជូនជនរួមជាតិ។ គាត់បានទទួលស្គាល់ថាក្នុងនាមគាត់ជាប្រធានរដ្ឋ ចលនានោះប្រព្រឹត្តនូវអំពើហិង្សាជាងរបបផ្សេងទៀត។ ក៏ប៉ុន្តែនៅពេលមួយទៀត នៅក្នុងឆ្នាំ២០០៧ កិច្ចសម្ភាសន៍ស្ដីអំពី "ការប្រឈមនឹងអំពើប្រល័យកពូជសាសន៍" គាត់និយាយថាគាត់មិនដែលឮ អំពីការសម្លាប់រង្គាលសម័យខ្មែរក្រហម រហូតដល់ឆ្នាំ(១៩)៩៨ ទើបឮ។ ឆ្នាំ៩៨ នេះហើយគឺពេលដែលចលនាខ្មែរក្រហមនេះដួលរលំទាំងស្រុង។ នេះគឺជាប្រធានបទមួយធ្ងន់ធ្ងរ។

ខៀវ សំផន អ្នកទាំងពីរនេះ គឺជាអ្នកដែលឆ្លាតវៃណាស់។ ជាបញ្ញាជន។ ខៀវ សំផន អ្នកដែលមានបណ្ឌិត និយាយភាសាបរទេស ហើយនិងសរសេរនិក្ខេបបទជាបញ្ញាជន ហើយគាត់លើកឡើងថា

គាត់ចង់ឲ្យយើងជឿថា នៅប្រទេសកម្ពុជាគាត់មិនដឹងការសម្លាប់រង្គាលរហូតដល់ឆ្នាំ១៩៧៨ គាត់មិនថាមានអ្វីដែលកើតឡើងនៅក្នុងប្រទេសគាត់ឬយ៉ាងម៉េច?

[១១:២៣:១៧]

ក្នុងរបបនោះ ខៀវ សំផន បានរស់នៅជាមួយនឹងមេដឹកនាំដទៃទៀត នួន ជា ហើយគាត់បានជួបជាមួយនឹង ប៉ុល ពត។ នួន ជា បានលើកឡើងថា គាត់ជួបទៀងទាត់ជាមួយនឹង ប៉ុល ពត ហើយ ខៀវ សំផន ក៏បានជួបជាមួយនឹង ប៉ុល ពត ផងដែរ។ ខៀវ សំផន ធ្វើដំណើរទៅបរទេស ជួបជាមួយនឹងអគ្គរាជទូតនិងរដ្ឋទូត ហើយគាត់បានទៅដឹងថា ព្រះមហាក្សត្រ សីហនុ ត្រូវបានគេឃុំផងដែរ។ ក៏ប៉ុន្តែក្រោយមក ខៀវ សំផន លើកឡើងថាគាត់មិនដឹងអ្វីទាល់តែសោះអំពីឧក្រិដ្ឋកម្មនេះ រហូតដល់ឆ្នាំ៩៨ទើបដឹង។ គាត់បានប្រាប់វីអូអេឆ្នាំ២០០៧ ថា ការកាប់សម្លាប់ទាំងអស់នោះគឺជាគំនិតរបស់ ប៉ុល ពត។ ថាតើធ្វើម៉េច ខៀវ សំផន ដឹងថាការកាប់សម្លាប់ទាំងអស់នោះ គឺជាគំនិតរបស់ ប៉ុល ពត ទៅ? គាត់ថាគាត់មិនដឹងអំពីការកាប់សម្លាប់ផង តើធ្វើម៉េចគាត់ដឹងថាការបញ្ជានេះចេញមកពី ប៉ុល ពត។ គាត់ដឹងដោយសារ ប៉ុល ពត និងគាត់និយាយអំពីបញ្ហានេះ។ ពួកគេបានពិភាក្សាអំពីការចេញបញ្ជា និងការកាប់សម្លាប់ ហូបអាហារជាមួយគ្នា ចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ជាមួយគ្នា ដូច្នេះហើយទើបគាត់ដឹងថា ប៉ុល ពត ជាអ្នកបញ្ជាឲ្យកាប់សម្លាប់។ គាត់បានប្រាប់ចៅក្រមស៊ើបអង្កេតនៅក្នុងតុលាការនេះខ្ញុំដកស្រង់ "ខ្ញុំសង្កេតឃើញថាសមាជិកមួយចំនួននៃគណៈមជ្ឈិម បានបាត់ខ្លួនពីម្នាក់ម្តងៗ"។ ពាក់ព័ន្ធទៅនឹងការបាត់ខ្លួន សមាជិក គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ម្នាក់ៗហាក់ដូចជាបង្ហាញ ហាក់ដូចជាឯកភាព ប៉ុន្តែខ្ញុំមិនដឹងអំពីវិសាលភាព និងការចាប់ខ្លួននោះទេ។

នៅពេលដែលយើងគិតអំពីការលើកឡើងរបស់គាត់នេះ គាត់និយាយថា គាត់ដឹងសមាជិកមេដឹកជាន់ខ្ពស់នៅក្នុងគណៈអចិន្ត្រៃយ៍និងគណៈមជ្ឈិមត្រូវបានគេដកចេញ ហើយគ្រប់ៗគ្នា –អ្នកដែលនៅសេសសល់នោះ– គឺឯកភាពការដកទាំងអស់នោះ។ ចំណុចនេះបង្កប់ន័យថា ខៀវ សំផន ខ្លួនឯងគឺដឹងហើយក៏មិនជំទាស់ចំពោះការចាប់ខ្លួននោះផងដែរ។ គាត់ជាបុគ្គលម្នាក់ដែលឯកភាពជាមួយនឹងការចាប់ខ្លួននោះផងដែរ។ ទោះបីជាបុគ្គលិកក្រោមបង្គាប់របស់ ខៀវ សំផន នៅ៨៧០ ត្រូវបានគេចាប់ខ្លួនហើយធ្វើទារុណកម្មដោយស-២១ក៏ដោយ បុគ្គលរូបនោះបានឆ្លើយដាក់ ខៀវ សំផន, នួន ជា។ គឺ នួន ជា បានព្រមាន ឌុច កុំឲ្យប្រមូល ឬក៏កត់ត្រាព័ត៌មានទាំងឡាយដែលឆ្លើយដាក់ ខៀវ សំផន។ ជាការពិតណាស់ នួន ជា ដែលជួបជាមួយ បានន័យថា ហូបជាមួយនឹង នួន ជា, ជួបជាមួយនឹង នួន ជា

ហើយក៏បានដឹងដែរថា ខ្លួនឯង ខៀវ សំផន ខ្លួនឯង ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព គឺគាត់បានដឹង។

[១១:២៦:២៤]

មានយុត្តិសាស្ត្រមួយទៀតដែល ខៀវ សំផន និង នួន ជា បានប្រើប្រាស់។ មិនមែនជាលើកទី១ ដែលខ្ញុំជាសហព្រះរាជអាជ្ញាបានឃើញតែជាលើកទី១នោះទេ ខ្ញុំធ្លាប់ឃើញចំណុចទាំងអស់នេះ។ បានន័យថា ពួកគេទាំងពីរនេះតែងតែទម្លាក់កំហុសទៅលើអ្នកដែលស្លាប់។ ខៀវ សំផន និង នួន ជា ចង់ទម្លាក់កំហុសទាំងអស់ទៅលើ ប៉ុល ពត។ គាត់និយាយថា ពួកគាត់និយាយថា គាត់មិនដឹងៗ មិនដឹង មិនដឹងអ្វីទាំងអស់ គឺ ប៉ុល ពត ជាអ្នកធ្វើ។ ក៏ប៉ុន្តែ ប៉ុល ពត មិនអាចសម្លាប់មនុស្សប្រហែល២លាននាក់ដោយខ្លួនឯងផ្ទាល់តែប៉ុណ្ណោះនោះទេ។ ប៉ុល ពត មិនអាចដឹកនាំអង្គការរដ្ឋមួយតែម្នាក់នោះទេ ដឹកនាំកងទ័ពតែម្នាក់ឯងនោះទេ។ គាត់អាចធ្វើឡើងដោយមានការជួយជ្រោមជ្រែងពីអង្គការនិងថ្នាក់ដឹកនាំផ្សេងទៀត។ បើសិនបើមិនមានការជួយជ្រោមជ្រែងដូច្នេះ គឺ ប៉ុល ពត មិនអាចធ្វើបាននោះទេ។ មិនអាចធ្វើបានដោយមិនមានការជ្រោមជ្រែងពីគណៈមជ្ឈិមនិងគណៈអចិន្ត្រៃយ៍នោះឡើយ។ ប្រសិនបើ ខៀវ សំផន និង នួន ជា ជឿជាក់ថា ប៉ុល ពត, ពួកគាត់បាននិយាយថា ប៉ុល ពត ជាអ្នកសម្លាប់ប្រឆាំងផ្ទុយនឹងគោលបំណងរបស់អ្នកទាំងពីរនោះ ហេតុអ្វីបានជា នួន ជា និង ខៀវ សំផន ស្មោះស្ម័គ្រជាមួយនឹង ប៉ុល ពត ពីរទសវត្សរ៍? នៅជាមួយ ប៉ុល ពត, គាំទ្រ ប៉ុល ពត ធ្វើអ្វី? ការពិតនោះគឺថា អ្នកទាំងពីរគឺជាជំនិតរបស់ ប៉ុល ពត ជាអ្នកគាំទ្រពេញ ខ្លាំងក្លាលើ ប៉ុល ពត។ ហើយគាត់ –ខៀវ សំផន– បានផ្តល់កិច្ចសម្ភាសន៍ថា "ប៉ុល ពត ជាអ្នកពូកែវិភាគស្ថានភាព ហើយខ្ញុំគោរពគាត់ខ្លាំងណាស់"។ ក៏ប៉ុន្តែក្រោយមកពួកគេបានធ្វើការទម្លាក់កំហុស ប៉ុល ពត ហើយចោទប្រកាន់ ប៉ុល ពត ថាជាជនផ្តាច់ការប្រើប្រាស់ពាក្យប្រល័យពូជសាសន៍ មិន -- ហើយវាមិនជាការពិត។ ដូច្នេះខ្ញុំឃើញថា ក្រោយនៅក្នុងកិច្ចសម្ភាសន៍នោះ ពួកគេបានលើកឡើងថា ប៉ុល ពត ជាមេដឹកនាំមួយដ៏អស្ចារ្យផងដែរ។ ខ្ញុំសូមបង្ហាញនូវខ្សែវីដេអូមួយដែល ខៀវ សំផន បានត្រូវបានគេសួរអំពី ប៉ុល ពត នៅក្នុងឆ្នាំ២០០៧។

[១១:២៨:៥០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

"(ខៀវ សំផន៖) ខ្ញុំមានរូបភាពគាត់នៅក្នុងចិត្តរបស់ខ្ញុំជានិច្ច។ ស៖ ចុះលោកមិននឹក ប៉ុល ពត ទេ? (ខៀវ សំផន៖) បាទខ្ញុំនឹក ពីព្រោះថាគាត់ជាមនុស្សមានខួរក្បាលកម្រណាស់ គាត់ពូកែណាស់

សម្រាប់ពួកយើង"។ *(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:២៩:៣៨]

ដូច្នេះ វាបង្ហាញច្បាស់ថា ខៀវ សំផន នៅតែស្មោះត្រង់ជាមួយ ប៉ុល ពត ហោចណាស់រហូតដល់ឆ្នាំ២០០៧។ ប៉ុន្តែ ក្នុងពេលជាមួយគ្នា គាត់បែរជាព្យាយាមមិនទទួលយកការទទួលខុសត្រូវ ហើយគាត់បន្ទោស ដាក់កំហុសទាំងអស់ទៅលើ ប៉ុល ពត តែម្នាក់ឯង។ ប៉ុន្តែខ្លួនគាត់ផ្ទាល់ គាត់បានទទួលស្គាល់ថាវាមិនអាចទៅទេ។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយវីអូអេ ខៀវ សំផន បាននិយាយថា៖ "ប៉ុល ពត ទទួលខុសត្រូវលើការសម្លាប់និងការបង្អត់អាហារទាំងស្រុង គឺប៉ុល ពត តែម្នាក់ឯង"។ គាត់ក៏បាននិយាយផងដែរថា -- គឺ ខៀវ សំផន បាននិយាយថា ប៉ុល ពត ជាអ្នកធ្វើឱ្យមាន អ្នកបញ្ជាឱ្យចាប់ខ្លួន គណៈអចិន្ត្រៃយ៍ ហើយគាត់មិនដឹងអ្វីទាំងអស់។ នួន ជា –ដែលកាន់តែស្និទ្ធស្នាលជាមួយ ប៉ុល ពត ថែមទៀតនោះ ហើយជាអនុប្រធានរបស់ ប៉ុល ពត– គាត់នៅតែសម្តែងការកោតសរសើរចំពោះ ប៉ុល ពត។ គឺថាគាត់ចាត់ទុក ប៉ុល ពត ជាអ្នកដែលមានទំនុកចិត្តបំផុត។ គាត់បាននិយាយថា ប៉ុល ពត តែងតែពិភាក្សាជាមួយគាត់នៅពេលដែលមានការសម្រេច។ ហើយ នួន ជា ឆ្លើយថា គឺថាគាត់ពិភាក្សានៅលើបញ្ហាធំៗ គឺបញ្ហាដែលមាន "នៅពេលដែលមានបញ្ហាកើតឡើងគឺគាត់តែងតែពិភាក្សាជាមួយខ្ញុំ"។ គាត់បាននិយាយផងដែរថា គឺជាការសម្ភាសជាមួយ ថេត សម្បត្តិ, "ស៖ តើលោក ហើយនិង ប៉ុល ពត ធ្លាប់ឈ្លោះជាមួយគ្នាដែរឬទេ នៅពេលដែលលោកដឹកនាំ?" ហើយគាត់ឆ្លើយថា "ទេ យើងមិនដែលមានបញ្ហាអ្វីទាំងអស់។ គឺចន្លោះពីឆ្នាំ៧៥ ដល់ ៧៩ គឺអត់មានអ្វីទាំងអស់។ ខ្ញុំរកនឹកមិនឃើញថា យើងធ្លាប់មានការឈ្លោះគ្នាអ្វីនោះទេ"។ ដូច្នេះ យើងបានឮរួចមកហើយថា ពួកគាត់បានពិភាក្សាអំពីការសម្លាប់នៅក្នុងគណៈអចិន្ត្រៃយ៍ ហើយ ខៀវ សំផន ក៏នៅទីនោះដែរ។ ហើយ នួន ជា ក៏បាននិយាយថា គាត់មិនដែលមានការឈ្លោះទាស់ទែង ឬក៏ការខ្វែងយោបល់គ្នាជាមួយ ប៉ុល ពត នោះទេ។

[១១:៣១:៥៣]

គេបានសាកសួរ នួន ជា គឺ ថេត សម្បត្តិ បានសាកសួរ នួន ជា។ "ស៖ ថាតើលោកគិតយ៉ាងម៉េចអំពីការចាប់ខ្លួននិងសម្លាប់? ឆ៖ គឺថា នៅពេលដែលខ្ញុំពិភាក្សាគឺយើងចង់ឱ្យមានបញ្ហាដោះស្រាយនេះគឺជាដំណោះស្រាយដ៏ល្អ"។ ហើយជាថ្មីម្តងទៀត វាមិនមែនជារឿងរបស់យើងដែលថា អ្នកដែលត្រូវបានគេសម្លាប់ មិនត្រូវបានគេយកមកជម្រាបដល់ពួកគាត់ទាំងពីរនោះទេ គឺថា ប៉ុន្តែអ្នកទាំងអស់គ្នានោះគឺត្រូវបានសម្លាប់ដោយសារគោលនយោបាយ ដោយសារតែការញុះញង់របស់មជ្ឈិមបក្ស។ វាគឺជាផ្នែក

ជាមូលដ្ឋានរបស់លទ្ធិខ្មែរក្រហម។ សូម្បីតែភ្លេងជាតិក៏និយាយអំពីឈាមដែរ។ ហើយ ខៀវ សំផន នៅក្នុងខួបលើកទី២ នៃថ្ងៃជ័យជម្នះ១៧មេសា គាត់បាននិយាយថា៖ "យើងត្រូវតែបោសសម្អាតខ្មាំងក្នុងនាមយើងជាម្ចាស់ស្ថានភាព"។ ហើយក្នុងឆ្នាំក្រោយមកទៀត គាត់បាននិយាយទៅកាន់មនុស្សប្រហែលជា ២០.០០០នាក់ នៅទីក្រុងភ្នំពេញ។ គាត់បាននិយាយថា ដោយការអនុវត្តមាគ៌ាបក្ស ទើបយើងអាចការពារប្រទេសរបស់យើង ប្រឆាំងជាមួយនឹងខ្មាំងផ្ទៃក្នុងនិងខ្មាំងខាងក្រៅ។ ហើយគាត់បានប្រាប់មនុស្សរាប់ម៉ឺននាក់ដែលមានវត្តមានថា "យើងត្រូវតែទុកផលប្រយោជន៍បុគ្គល និងផលប្រយោជន៍គ្រួសារនៅមួយកន្លែងសិន ហើយគិតអំពីបដិវត្តន៍វិញ។ យើងត្រូវបោសសម្អាតខ្មាំងនៅគ្រប់កន្លែងទាំងអស់"។ ហើយគាត់បានប្រាប់ពួកគេបន្ថែមទៀតថា៖ "ត្រូវពិនិត្យមើល ហើយនិងបោសសម្អាតគ្រប់សមាសភាពខ្មាំងនៅក្នុងជួររបស់យើង"។ ប្រសិនបើយើងពិនិត្យមើលទៅលើឯកសារសំខាន់មួយនេះ គឺជាឯកសាររបស់បក្សគណៈកម្មាធិការកណ្តាលរបស់បក្សកុម្មុយនីស្តកម្ពុជានៅខែមីនា ឆ្នាំ៧៦ គឺបាននិយាយអំពីសិទ្ធិក្នុងការសម្រេចកម្ទេច។ ពាក្យថា "កម្ទេច" គឺមានន័យថា "សម្លាប់"។ ចំណុចទី១ គឺអំពីការសម្រេចកម្ទេចនៅក្នុងជួរនិងក្រៅជួរ គឺក្នុងជួរនិងក្រៅជួរបក្ស។ ហើយគេបានផ្តល់នូវសិទ្ធិដូចតទៅនេះ៖ គឺជាសិទ្ធិសម្រេច ហើយមានក្របខ័ណ្ឌ គឺថាក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍សម្រេច, ប្រសិនបើមជ្ឈិមបក្ស ត្រូវមន្ទីរមជ្ឈិមសម្រេច, បើសិនឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេចជាដើម។ ដូច្នេះ អានេះគឺជាអ្វី? អានេះគឺជាលក្ខណៈមួយដែលយើងពិនិត្យមើល ប្រសិនបើជាមជ្ឈិមបក្ស គឺមជ្ឈិមបក្សជំរុញឲ្យភូមិភាគ ឲ្យកងទ័ព ហើយនិងតំបន់ធ្វើការអនុវត្តនូវមាគ៌ា នូវគោលនយោបាយរបស់ពួកគេក្នុងការបោសសម្អាតនិងកម្ទេចខ្មាំង ដើម្បីធានាថាការអនុវត្តបដិវត្តន៍សម្រេចបានដោយជោគជ័យ។

[១១:៣៥:០៤]

ដូច្នេះ វាច្បាស់លាស់ហើយថា នេះពួកគាត់មិនមែនជាអ្នកសម្លាប់ដោយផ្ទាល់នោះទេ មិនមែនជាឃាតករដោយផ្ទាល់នោះទេ ប៉ុន្តែចំពោះការកម្ទេច ឬក៏ការសម្លាប់ជាទ្រង់ទ្រាយធំដូចជា តាម៉ុក ជាដើម ប្រហែលជាអស់លោក លោកស្រីធ្លាប់ឮច្រើនអំពីគាត់ ព្រមទាំងទាហានរបស់គាត់។ គាត់មិនត្រឹមតែជាប្រធានភូមិភាគនោះទេ ប៉ុន្តែគាត់ត្រូវបានខាងមជ្ឈិមបញ្ជូនទៅកាន់ភូមិភាគផ្សេងៗ ដើម្បីបោសសម្អាតនិងធ្វើការកម្ទេចទៅលើប្រជាជន ក៏ដូចជាកងទ័ព។ ប៉ុន្តែតើ តាម៉ុក ធ្លាប់ទទួលការដាក់ទណ្ឌកម្មដោយមជ្ឈិមដែរឬទេ? អត់ទេ មិនដែលសោះ។ នៅពេលដែលពេលវេលាកន្លងផុតទៅមុខ គឺ តាម៉ុក នៅតែមានឋានៈខ្ពង់ខ្ពស់ ឋានៈធំដដែលនៅក្នុងបក្ស។ តើ ខៀវ សំផន ហើយនិង នួន ជា ដែលជាមេដឹកនាំ

មជ្ឈិម តើគេខ្វល់អំពីប្រជាជនទូទៅដែលត្រូវបានគេសម្លាប់? តើគេខ្វល់អំពីប្រជាជនដែលរើសចេក រើសផ្លែឈើជ្រុះលើដីហូបដែរឬទេ? គឺអត់ទេ។

[១១:៣៦:២១]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

"(នួន ជា៖) គឺ *(ឮមិនច្បាស់)* តិចៗទៅណ៎ះ! បានយើងដឹងប្រវត្តិនោះ បានយើងងាកមករកវិញ មក វាយ៉ាងម៉េច។ អានេះដូចយើងស្រវាម្កុលក្នុងសមុទ្រអ៊ីចឹង យើងមិនមែនចេះតែចាប់ៗឯណា ដឹងអ៊ីចឹងណ៎ា រកមកពីដើមគាត់យ៉ាងម៉េច អីយ៉ាងម៉េច។ ប្រជាជនមិនដឹងមែន។ អានេះ ប៉ុល ពត ក៏មិនសូវដឹង ខ្ញុំក៏មិនដឹង នរណាទៀតក៏មិនដឹងដែរ។ កាលហ្នឹង ពួកនេះវាទៅច្រើនណាស់ ដែលវាមក នេះ ខ្ញុំនិយាយតិច។ សះ ដែលឮដំណឹងថាមានការស្លាប់ មានទេ? គាត់ មានការសម្លាប់ទៅលើប្រជា ពលរដ្ឋអីនោះ តើដែលដឹងនោះចាប់ផ្ដើមពីពេលណាដែរបាទ? (នួន ជា៖) ហ៊ឺ ពីពេលនោះ ពិបាកនិយាយ ណាស់ ពីព្រោះវាភ្លេចទៅហើយ ពេលវេលាណ៎ា។ អ៊ីចេះ ការងារចេះតែធ្វើទៅ យើងមិនបានកត់មិន បានអី"។

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:៣៧:១៣]

ខ្ញុំគ្រាន់តែបន្តការងាររបស់ខ្ញុំតែប៉ុណ្ណោះ នេះគឺជាអ្វីដែលគាត់និយាយ។ គាត់គ្រាន់តែបន្តការងារ របស់គាត់ ព្រោះថាការសម្លាប់នៅក្នុងភូមិ គឺការសម្លាប់ប្រជាជនធម្មតា ហើយវាជាលទ្ធផលនៃគោល នយោបាយដែលគាត់អ្នកដាក់ចេញ គឺគាត់ និង ប៉ុល ពត, ខៀវ សំផន ហើយនិងមេដឹកនាំជាន់ខ្ពស់ខ្មែរ ក្រហមជាអ្នកដាក់ចេញ។ ហើយមានហេតុផល ឬក៏លេសមួយទៀតដែល នួន ជា និងអ្នកដទៃទៀត បានប្រើប្រាស់ដើម្បីគេចពីការទទួលខុសត្រូវ គាត់បាននិយាយថា៖ "ការសម្លាប់ទាំងអស់នៅក្នុងភូមិគឺថា ការសម្លាប់នៅតាមភូមិ ត្រូវបានធ្វើឡើងដោយខ្មាំងតែប៉ុណ្ណោះ។ អ្នកដែលត្រូវបានគេសម្លាប់ គឺសម្លាប់ ដោយវៀតណាម និង សេ.អ៊ី.អា ទេ"។ ក្នុងលក្ខណៈមួយគឺថា នួន ជា គាត់ទទួលស្គាល់ថាសម្លាប់ មនុស្ស គឺសម្លាប់ភ្នាក់ងារវៀតណាម និង សេ.អ៊ី.អា នោះគឺថាពួកគាត់និយាយថា អ្នកដែលគេសម្លាប់ នោះគឺសម្លាប់ពួកក្បត់ជាភ្នាក់ងារវៀតណាម, សេ.អ៊ី.អា ប៉ុន្តែក្នុងពេលជាមួយនឹងគាត់បែរបន្ទោស ឬក៏ ដាក់ទម្លាក់កំហុសទៅលើវៀតណាម, សេ.អ៊ី.អា វិញ។ នេះគឺជាការកុហកដែលមិនគួរឲ្យជឿទាល់តែ សោះតែម្ដង។

ដោយមិនទទួលខុសត្រូវ នួន ជា បានពន្យល់ថាអ្វីៗទាំងអស់ដែលកើតឡើងមិនត្រឹមត្រូវដែលខុសនោះ។ ឧទាហរណ៍ដូចជាការសម្លាប់ ការអត់ឃ្លាន ឬការដាក់ឲ្យទៅជាទាសករ ដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមហ្នឹង គឺជាការធ្វើឡើងដោយគិញ ហើយនិងជនក្បត់ដែលជាការធ្វើវិទ្ធង្សនាទៅលើបក្ស។ ដូចដែលអ្វីដែលមជ្ឈិមព្យាយាមធ្វើដើម្បីកុហកខ្លួនឯង គឺគេចង់ធ្វើឲ្យការ ជឿជាក់ថាអ្វីៗទាំងអស់នៅទូទាំងប្រទេស គឺមានគិញ មានភ្នាក់ងារបរទេស មានចារកម្មអីផ្សេងៗ មានគ្រប់ទីកន្លែងទាំងអស់ហ្នឹង។ ប៉ុន្តែប្រសិនបើគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ប្រហែលពាក់កណ្ដាល គឺជាភ្នាក់ងារ គឺជាគិញរបស់សេ.អ៊ី.អា ឬរបស់យួនហ្នឹង តើខ្មែរក្រហមធ្វើយ៉ាងម៉េចដើម្បីឈ្នះ ប្រយុទ្ធឈ្នះនៅឆ្នាំ១៩៧៥នោះ។

[១១:៣៩:២៥]

មេធាវីការពារក្ដីបានព្យាយាមប្រើប្រាស់អង្គហេតុដែលថា ប្រជាជនដែលប្រឆាំងទៅនឹងរបបគឺរបបដែលអាក្រក់បែបនេះ គឺថាត្រូវបានសម្លាប់ -- ពួកគេត្រូវបានសម្លាប់ដោយសារប្រជាជនទាំងនោះចង់ផ្ដួលរលំរបប។ ថាតើហេតុអ្វីបានជាមនុស្សមិនល្អបែរជាចង់ប្រឆាំង ចំណែកមនុស្សល្អមិនគាំទ្រទៅវិញ។ តើប្រជាជនធម្មតាយ៉ាងដូចម្ដេចដែរ? គឺប្រជាជនធម្មតាដែលខ្មែរក្រហមផ្ដោតគោលដៅក្នុងការសម្លាប់ ការដាក់ឲ្យទៅជាទាសករ ការបង្អត់អាហារជាដើមនោះ។ ឥឡូវនេះ គេប្រើប្រាស់នូវហេតុផលដែលមិនត្រឹមត្រូវដើម្បីគាំទ្រទៅលើអ្វីដែលគេបានធ្វើ ហើយវាជាគំនិតចម្លែកបំផុតដែលគេប្រើប្រាស់ សេ.អ៊ី.អា ហើយនិងវៀតណាម ហើយវៀតណាម, សេ.អ៊ី.អា មកធ្វើការជាមួយគ្នា វាមិនត្រឹមត្រូវ វាមិនសមស្របទាល់តែសោះ ប្រសិនបើយើងមើលទៅអាមេរិក ហើយនិងវៀតណាមទើបតែបញ្ចប់សង្គ្រាមរយៈពេលយូរជាមួយគ្នា។ ហើយអាមេរិក គឺប្រឆាំងដាច់ខាតជាមួយកុម្មុយនីស្តវៀតណាម។ ដូច្នេះវាមិនអាចនោះទេ។ ដូច្នេះហើយទោះបីថានៅឆ្នាំ៧៥ក៏ដោយ ក៏រដ្ឋាភិបាលអាមេរិករហូតមកដល់ពេលនេះ នៅតែគាំទ្រថាឲ្យខ្មែរក្រហមទទួលអាសនៈនៅអង្គការសហប្រជាជាតិ។ ដូច្នេះវាជារឿងចម្លែកមួយដែលថា សេ.អ៊ី.អា ហើយនិងវៀតណាម គាត់សហការជាមួយគ្នា ហើយធ្វើការជាមួយគ្នាដើម្បីបំផ្លាញកម្ពុជា។ ដូច្នេះហើយវាជាការមិនត្រូវត្រឹមត្រូវ។

[១១:៤១:១៦]

ហើយជាចុងក្រោយ នួន ជា ចង់និយាយថា អ្វីដែលធ្វើឡើង គឺយើងធ្វើឡើងដើម្បីការពារកម្ពុជា ហើយការសម្លាប់នេះមិនមែនជាការសម្លាប់នៅក្នុងសមរភូមិទេ។ អ្នកដែលត្រូវបានចាប់ខ្លួន ហើយត្រូវបានសម្លាប់នោះ គឺមួយចំនួនជាទាហានរបស់ខ្មែរក្រហម ហើយអ្នកខ្លះគឺជាទាហានដ៏ល្អ ជាកងទ័ពដ៏ល្អ

ទៀតផង។ គេបង្អត់អាហារ ធ្វើទារុណកម្ម ហើយសម្លាប់ប្រជាជនកម្ពុជារាប់លាននាក់ ប៉ុន្តែសួរថាតើការសម្លាប់នោះធ្វើយ៉ាងណាដើម្បីការពារកម្ពុជាបាន។ នួន ជា ចង់ឲ្យយើងជឿជាក់ថាអ្នកដែលគេផ្តោតគោលដៅហ្នឹង គឺជាខ្មាំង។ អ្នកដែលសម្លាប់នៅស-២១ ប្រហែលជា ១២.០០០ ទៅ១៦.០០០ គឺជាខ្មាំង។ ឥឡូវយើងមើលរូបថតនេះ! ថាតើពួកគាត់ហ្នឹងជានរណាដែរ? គឺជាអ្នកដែល នួន ជា សម្លាប់នៅស-២១ ហ្នឹង គឺជាអ្នកណាដែរ? តើសម្លាប់ក្មេងហ្នឹងអាចជួយការពារប្រទេសដោយរបៀបណាទៅ? តើវាមានការពិតប៉ុនណានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏របបខ្មែរក្រហម គឺជាអ្វីដែលគេធ្វើចំពោះប្រជាជនកម្ពុជា គឺគេព្យាយាមកាត់បន្ថយប្រជាជនរហូតទៅដល់មួយភាគបួន។ គឺបន្ថយប្រជាជនដល់ទៅ២៥ភាគរយ។ គេបំផ្លាញសេដ្ឋកិច្ច គេសម្លាប់អ្នកចេះដឹងនិងអ្នកដែលក្លាហាន ហើយខ្មែរក្រហមបានត្រឹមតែបំផ្លិចបំផ្លាញកម្ពុជា ហើយរហូតមកដល់ពេលឥឡូវនេះ កម្ពុជានៅតែព្យាយាមងើបចេញពីហេតុការណ៍ទាំងអស់នេះ។ ដូច្នេះតើអ្នកណាដែលគេសម្លាប់ ដែលគេគិតថា សម្លាប់ដើម្បីការពារប្រទេសនោះ។

[១១:៤៣:១៨]

នៅក្នុងចម្លើយមួយដែល នួន ជា បានសរសេរជាមួយគឺនៅថ្ងៃ -- នៅខែកក្កដា ឆ្នាំ៧៣ គាត់បាននិយាយថា ថ្នាក់ដឹកនាំត្រូវតែការពារតាមគ្រប់មធ្យោបាយ។ ដូច្នេះ គឺយើងមិនអាចធ្វើការប្រៀបធៀបការបាត់បង់កម្មាភិបាលដឹកនាំពីរបីនាក់ ធៀបជាមួយនឹងការបាត់បង់សមាជិក ២០០ - ៣០០នាក់នោះឡើយ។ ដូច្នេះ តើការពារខ្លួនដោយរបៀបណា? គេថាគេការពារត្រឹមតែថ្នាក់ដឹកនាំពីរបីនាក់ប៉ុណ្ណោះ គេមិនខ្វល់ពីប៉ុន្មានរយសិបនាក់ដែលស្លាប់នោះទេ។ ឧទាហរណ៍ នៅក្នុងពេលដែលវៀតណាមចូលមកភ្នំពេញនៅឆ្នាំ៧៩ គឺ -- តើ នួន ជា ហើយ ខៀវ សំផន មានបានទាញអាវុធយកទៅប្រយុទ្ធដែរឬទេ? អត់ទេ។ ការពិតទៅនៅពេលនោះ គឺ នួន ជា បានត្រឹមតែបង្គាប់ឲ្យ ឌុច បញ្ជាសម្លាប់អ្នកទោសទាំងអស់នៅស-២១ តែប៉ុណ្ណោះ។ ដូច្នេះ តាមពិតទៅ នួន ជា, ខៀវ សំផន មិនមែនជាអ្នកស្នេហាជាតិ។ ហើយមនុស្សជាច្រើនដែលខ្ញុំស្គាល់នៅក្នុងប្រទេសកម្ពុជា ហើយបានឮអំពីការសុំទោស។ ហើយខ្ញុំគិតថាពួកគាត់បានឮអំពីការសូមទោស ការលើកលែងទាំងអស់ ប៉ុន្តែយើងនឹងព្យាយាមបង្ហាញតាមភស្តុតាង បង្ហាញការពិតដែលថាបុគ្គលទាំងពីរនាក់ គឺ នួន ជា និង ខៀវ សំផន គឺជាបុគ្គលដែលមានអំណាច មានឥទ្ធិពលបំផុតនៅក្នុងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមដែលបានបង្កឲ្យមានការឈឺចាប់ក្នុងរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ទៅលើប្រជាជនកម្ពុជា។ ពួកគាត់ទទួលខុសត្រូវផ្ទាល់ចំពោះការស្លាប់ប្រជាជនប្រហែលជា ២លាននាក់ គឺប្រជាជនស្លូតត្រង់។

[១១:៤៥:០៧]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមស្របនឹងសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយ សាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាងក្រោម ហើយនិងបង្គាប់ឱ្យនាំខ្លួនគាត់ត្រលប់មកវិញនៅរសៀលនេះឱ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤៥ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ។

អង្គជំនុំជម្រះប្រកាសបន្ត កិច្ចដំណើរការនីតិវិធីសវនាការ។

កាលពីព្រឹកមិញនេះសហព្រះរាជអាជ្ញាបានធ្វើក្តីសន្និដ្ឋានបើកដោយសង្ខេបបានបញ្ចប់រួចហើយ។ ហើយជាបន្តទៅនេះ អង្គជម្រះសូមផ្តល់វេទិកាជូនទៅដល់ជនជាប់ចោទទាំងពីររូប និង មេធាវីរបស់ខ្លួនដើម្បីឆ្លើយតបដោយសង្ខេបទៅនឹងក្តីសន្និដ្ឋានបើករបស់សហព្រះរាជអាជ្ញា។ ជាដំបូងនេះ អង្គជម្រះផ្តល់វេទិកាជូនទៅជនជាប់ចោទ នួន ជា និង មេធាវីការពារក្តីរបស់លោក នួន ជា។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីឃុំឃាំងនាំខ្លួនលោក នួន ជា មកអង្គុយនៅមុខឈើរាងវង់ក្រចកសេះនៅចំពោះមុខអង្គជំនុំជម្រះនេះ។

បាទ មេធាវី និង លោក នួន ជា តើឱ្យអ្នកណានិយាយមុន?

**លោក សុន អរុណ៖**

ខ្ញុំបាទ សុន អរុណ មេធាវីរបស់លោក នួន ជា សុំជូនលោក នួន ជា នឹងបើកមុន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញ លោក នួន ជា!

**លោក នួន ជា៖**

ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ! សូមគោរពជនរួមជាតិកម្ពុជាជាទីស្រឡាញ់រាប់អាន និងជនស្នេហាសច្ចភាព និង យុត្តិធម៌ទាំងអស់ជាទីគោរព។ គោរពតុលាការ។ ខ្ញុំ! នួន ជា ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ថ្ងៃនេះ ដោយហេតុថាតុលាការនេះ បានចាប់ផ្ដើមបើកសវនាការជាលើកទី២ ប្រឆាំងនឹងខ្ញុំ។ ខ្ញុំសូមយកឱកាសនេះ និយាយទៅកាន់ជនរួមជាតិខ្ញុំជាថ្មីម្ដងទៀត។ កាលពីពីរខែមុន ចៅក្រមនៅក្នុងបន្ទប់នេះបានចេញសាលក្រមលើកទី១ ប្រឆាំងនឹងរូបខ្ញុំ។ លោកចៅក្រមបានដាក់ទោសខ្ញុំ អំពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីភ្នំពេញ និងការសម្លាប់ទាហាន និងមន្ត្រីនៃរបបលន់ នល់ នៅទួលពោធិ៍ជ្រៃ ហើយក៏បានផ្ដន្ទាទោសខ្ញុំ ដោយដាក់គុកអស់មួយជីវិត។

លោកចៅក្រមបាននិយាយថា បក្សកុម្មុយនីស្តកម្ពុជាមានឋានានុក្រមជាសម្ងាត់ ដែលបានគ្រប់គ្រងដ៏មានប្រសិទ្ធភាពពីមជ្ឈិមបក្ស។ លោកចៅក្រមបាននិយាយផងដែរថា គ្រប់កិច្ចការរបស់មជ្ឈិមបក្សទាំងអស់ គឺ ប៉ុល ពត និង ខ្ញុំ ជាអ្នកគ្រប់គ្រង។ យោងទៅតាមអ្វីដែលលោកចៅក្រមបាននិយាយនេះថាយើងខ្ញុំទាំងពីរនាក់បានអនុវត្តអំណាចនៃការធ្វើសេចក្ដីសម្រេចចុងក្រោយរបស់បក្ស ដែលវាអាចបង្កើតនិងអនុវត្តរាល់គោលនយោបាយ និងសេចក្ដីសម្រេចរបស់បក្ស និងគ្រប់គ្រងរាល់កម្មាភិបាលរបស់ខ្មែរក្រហម ចាប់តាំងពីកូនទាហានថ្នាក់ទាប រហូតដល់គ្រប់សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងគណៈកម្មាធិការអចិន្ត្រៃយ៍។

[១៣:៣៤:២៥]

នៅពេលដែលលោកចៅក្រមធ្វើសេចក្ដីសម្រេចនោះ លោកចៅក្រមបានបំភ្លេចចោលទាំងស្រុងនូវភស្តុតាងច្បាស់លាស់និងជាក់លាក់ ដែលបក្សបានបែងចែកអំណាចផ្ទៃក្នុងយ៉ាងច្បាស់លាស់ ហើយភូមិភាគនីមួយៗ តាមពិតអាចនឹងបានធ្វើសកម្មភាពដោយស្វ័យត។ ផ្ទុយទៅនឹងអ្វីដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំ លោកចៅក្រមមិនបានយកចិត្តទុកដាក់លើភស្តុតាងដែលសមាជិកអចិន្ត្រៃយ៍ និងសមាជិកមជ្ឈិមបក្សដូចជា សោ ភឹម, រស់ ញឹម, វន វេត, កុយ ធួន, និងអ្នកដទៃទៀត ពិតជាមេដឹកនាំនៃក្រុមបះបោរប្រឆាំងនៅក្នុងបក្ស ដែលគាំទ្រដោយវៀតណាម។ ក្រុមនេះបានធ្វើសកម្មភាពតាមទំនើងចិត្តចាប់តាំងពីពេលចាប់ផ្ដើមដំបូងមកម្លេះ ក្រុមនេះមានបំណងបំផ្លិចបំផ្លាញយ៉ាងខ្លាំងដល់គោលបំណង

របស់បក្ស ហើយក្រុមនេះបានបំពេញបំណងអាក្រក់របស់ខ្លួនបានទាំងស្រុង។

លោកចៅក្រមក៏មិនបានយកចិត្តទុកដាក់ផងដែរ ទៅលើភស្តុតាងដែលខ្ញុំ និងមេធាវីរបស់ខ្ញុំបានលើកឡើងចាប់តាំងពីពេលចាប់ផ្តើមនៃសវនាការលើកដំបូង ដែលថាព្រឹត្តិការណ៍ជាច្រើនបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចជាការឈ្លានពានលើទឹកដីមកលើទឹកដីកម្ពុជាពីសំណាក់ប្រទេសជិតខាង ជាពិសេសប្រទេសវៀតណាម គឺមានតាំងពីយូរណាស់មកហើយ។

លោកចៅក្រមមិនបានយកចិត្តទុកដាក់ ទៅលើភស្តុតាងដែលវៀតណាមបានជួយគាំទ្រដល់ក្រុម សោ ភឹម ហើយក្រោយមកតាមរយៈជំនួយនេះ ធ្វើឲ្យក្រុមនេះបានសម្រេចនូវបំណងរបស់ខ្លួន។

[១៣:៣៦:៥១]

នៅក្នុងសាលក្រមរបស់លោកចៅក្រមជាភាសាខ្មែរ ដែលមានកម្រាស់ជិត ១០០០ទំព័រ លោកចៅក្រមមិនបានបញ្ជាក់ដោយផ្ទាល់ទៅលើភស្តុតាងទាំងនេះនៅក្នុងទំព័រណាមួយឡើយ។ ជំនួសមកវិញ លោកចៅក្រមបានច្រានចោលការឈ្លានពានរបស់ប្រទេសវៀតណាមមកលើប្រទេសកម្ពុជា ហើយគិតថានេះជាគំនិតឆ្កួតលីលាមួយ។ លើសពីនេះទៀត លោកចៅក្រមមិនបានលើកឡើងពីអត្ថិភាពនៃក្រុមផ្សេងៗទៀតទាល់តែសោះ។

ខ្ញុំសូមនិយាយឲ្យបានច្បាស់ថា នេះមិនមែនជាគំនិតឆ្កួតលីលានោះទេ។ បញ្ជាក់ម្តងទៀត! ខ្ញុំសូមនិយាយឲ្យបានថា នេះមិនមែនជាគំនិតឆ្កួតលីលានោះទេ។ ដូចដែលខ្ញុំនិងមេធាវីរបស់ខ្ញុំ បានធ្វើអំណះអំណាងនៅក្នុងសវនាការលើកទី១ និងធ្វើអំណះអំណាងជាថ្មីម្តងទៀតនៅលើកទី២នេះថា ពិតជាមានក្រុមជាច្រើននៅក្នុងផ្ទៃក្នុងបក្ស។ វាពិតជាមានក្រុមស៊ីរូងផ្ទៃក្នុងមួយដែលគាំទ្រដោយវៀតណាម និងដឹកនាំដោយ សា ភឹម និង រស់ ញឹម។ ខ្ញុំមិនចង់បង្រៀនឲ្យចៅក្រមយល់ដឹងថាវៀតណាមមានមហិច្ឆិតាចង់លេបទឹកដីប្រទេសកម្ពុជាតាំងពីយូរយាណាស់មកហើយនោះទេ តែចំណុចនេះត្រូវបានប្រជាពលរដ្ឋកម្ពុជាគ្រប់រូបដឹងច្បាស់អស់ហើយ។ ខ្ញុំនិយាយពីបញ្ហានេះបន្ថែមទៀតនៅពេលក្រោយ។

ឥឡូវនេះ ខ្ញុំសូមលើកឡើងនូវអ្វីដែលចៅក្រមបានបំភ្លេចចោលចំពោះបញ្ហាទាំងអស់នេះ។ ជំនួសមកវិញ លោកចៅក្រមបែរជាបង្ហាញនូវរឿងមួយដ៏សាមញ្ញ តែរឿងនោះវាដូចជារឿងព្រេងនិទានអញ្ចឹង! តើរឿងនេះកើតឡើងដោយរបៀបណា? ជាការពិតណាស់ ហេតុផលមួយនោះគឺថា បើទោះជាមានការខិតខំប្រឹងប្រែងដោយយកចិត្តទុកដាក់របស់មេធាវីរបស់ខ្ញុំយ៉ាងណាក្តី ក៏ចៅក្រមជាតិនៃសាលាដំបូងបានបដិសេធមិនកោះហៅ លោក ហេង សំរិន ឲ្យធ្វើជាសាក្សីទេ។ បើទោះជាសាក្សីរូបនេះពិតជាមានសារៈ

សំខាន់នៅក្នុងសវនាការនេះយ៉ាងណាក៏ដោយ ហើយបើទោះជាសាក្សីរូបនេះអាចផ្តល់សក្ខីកម្មអំពីកិច្ចប្រជុំរបស់បក្ស ដែលអាចសន្មតបានថាកិច្ចប្រជុំនោះបានសម្រេចនូវគោលនយោបាយរបស់បក្សយ៉ាងណាក៏ដោយ។ បើទោះជាសាក្សីរូបនេះអាចបញ្ជាក់ពីជំហររបស់ខ្ញុំថា ខ្ញុំមិនដែលបានបញ្ជាឲ្យសម្លាប់ទាហាននិងមន្ត្រីរបស់របបលន់នល់ និងជនស្លូតត្រង់នៅពេលធ្វើការជម្លៀស ហើយបើទោះជាគាត់អាចពន្យល់អំពីអត្តចរិតរបស់ខ្ញុំដោយលម្អិត ចាប់តាំងពីយើងបានស្គាល់គ្នាជាង៦០ឆ្នាំមកក៏ដោយ។ តែផ្ទុយទៅវិញ លោកចៅក្រមបានគិតថា មេធាវីរបស់ខ្ញុំបានព្យាយាមសុំឲ្យតុលាការកោះហៅលោក ហេង សំរិន នោះ គឺជាល្បិចកលទៅវិញ។ នៅថ្ងៃនេះ ខ្ញុំចង់ជម្រាបលោកចៅក្រមពីចិត្តរបស់ខ្ញុំថា ខ្ញុំមានការឈឺចាប់ណាស់។ តុលាការនេះត្រូវតែបានបង្កើតឡើងដើម្បីស្វែងរកការពិត យុត្តិធម៌ និងបម្រើផលប្រយោជន៍សង្គម។ ប៉ុន្តែនៅក្នុងសាលក្រមលើកទី១ របស់លោកចៅក្រម ដែលបានកាត់ទោសខ្ញុំកាលពីពីរខែកន្លងទៅនេះ លោកចៅក្រមពិតជាបរាជ័យក្នុងការបំពេញកិច្ចការនេះជាប្រាកដ។ លោកចៅក្រមពិតជាមិនបានរកឃើញការពិត ហើយបានបន្ទាបតម្លៃយុត្តិធម៌ទៅវិញ។ ក្រោយពេលលោកចៅក្រមចេញសាលក្រមលើកទី១ ដាក់ទោសខ្ញុំភ្លាម ខ្ញុំបានប្រាប់ឲ្យមេធាវីរបស់ខ្ញុំដាក់ពាក្យប្តឹងជំទាស់ដើម្បីដកលោកចៅក្រម និល ណុន, យ៉ា សុខន, យូរ ឧត្តរា និងចៅក្រម ឡាវែន៍ ពីការជំនុំជម្រះក្តីមកលើរូបខ្ញុំនាពេលខាងមុខតទៅទៀត។ តាមរយៈសាលក្រមរបស់លោកចៅក្រមលើកទី១នេះ វាបង្ហាញថា លោកចៅក្រមមិនមានលក្ខណៈសម្បត្តិដើម្បីសម្រេចសេចក្តីលើរឿងក្តីរបស់ខ្ញុំទៀតឡើយ។ មេធាវីរបស់ខ្ញុំបានដាក់ពាក្យប្តឹងជំទាស់នេះប្រហែលជាពីរ ឬបីសប្តាហ៍កន្លងទៅ។ ហើយយើងកំពុងរង់ចាំលទ្ធផលនៃការសម្រេចលើបណ្តឹងនេះ។

[១៣:៤៣:០១]

មេធាវីរបស់ខ្ញុំបានផ្តល់អំណះអំណាងថា សាលក្រមលើកទី១ របស់តុលាការបានបង្ហាញថា លោកចៅក្រមគ្មានឯករាជ្យភាពនិងលម្អៀង។ នេះដោយសារតែដូចជាចៅក្រមជាតិទាំងអស់ លោកធ្វើការនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាលនិងមានភាពភ័យខ្លាច។ លោកចៅក្រមបានបង្ហាញឲ្យឃើញការបាត់បង់ឯករាជ្យភាព នៅស្ទើរតែគ្រប់សេចក្តីសម្រេចរបស់ខ្លួន ក្នុងការសម្រេចមិនបានកោះហៅលោក ហេង សំរិន ជាដើម។ លោក ហេង សំរិន មិនត្រឹមតែជាសាក្សីដ៏សំខាន់នៅក្នុងសាលសវនាការនេះទេ តែគាត់ជាសាក្សីអត្តចរិតរបស់ខ្ញុំ។ គាត់ជាមនុស្សសំខាន់ទី៣នៃអំណាចរដ្ឋនៅក្នុងប្រទេសកម្ពុជា ហើយជាប្រធានកិត្តិយសនៃគណបក្សប្រជាជនកម្ពុជាផងដែរ។ ចំពោះចៅក្រមបារាំង ឡាវែន៍ វិញ

លោកកាន់តែអាក្រក់ទៅទៀត បើទោះជាលោកបានយល់ស្របជាមួយយើងខ្ញុំថា លោក ហេង សំរិន គួរត្រូវមកផ្តល់សក្ខីកម្មពីព្រោះគាត់អាចផ្តល់ភស្តុតាងដ៏សំខាន់ដែលសាក្សីផ្សេងទៀតមិនអាចផ្តល់បាន។ តែទោះជាយ៉ាងណាក្តី លោកចៅក្រមនៅតែធ្វើសេចក្តីសន្និដ្ឋានដោយគ្មានមន្ទិលសង្ស័យថា ខ្ញុំមានទោស ហើយមិនបាច់មានសាក្សីរបស់លោក ហេង សំរិន។ ហើយលោកចៅក្រមមិនមានឆន្ទៈ សូម្បីតែប្រកាសថា ការបដិសេធមិនកោះហៅលោក ហេង សំរិន មកផ្តល់សក្ខីកម្ម គឺជាការរំលោភសិទ្ធិរបស់ខ្ញុំក្នុងការទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌។ វាគ្មានន័យអ្វីឡើយក្នុងការធ្វើសេចក្តីសម្រេចនោះទេ ប្រសិនបើលោកចៅក្រមមិនមានសេចក្តីក្លាហានគ្រប់គ្រាន់ដើម្បីរក្សានូវជំហររបស់ខ្លួននោះ។ នៅក្នុងសវនាការលើកទី២នេះ លោក ហេង សំរិន នៅតែជាសាក្សីដ៏មានសារសំខាន់បំផុត។ តាមពិតបច្ចុប្បន្ននេះ គាត់រឹតតែមានសារៈសំខាន់ ពីព្រោះវាកាន់តែមានសារៈសំខាន់ដើម្បីឲ្យយល់កាន់តែច្បាស់នូវតួនាទីរបស់វៀតណាមក្នុងការឈ្លានពាន វាតទី លេបទឹកដី បំបាត់ពូជសាសន៍កម្ពុជា។

[១៣:៤៦:០០]

ជាអកុសលនៅក្នុងសាលក្រមទី១ របស់លោកចៅក្រមបានបង្ហាញថា លោកចៅក្រមមិនយល់ស្របទៅនឹងចំណុចនេះទេ។ ហេតុនេះ បន្ថែមទៅលើបណ្តឹងជិតចិត្តចៅក្រមទាំងបួន ក្នុងចំណោមលោកចៅក្រមទាំងអស់ និងក្រោយពីខ្ញុំបានទទួលសាលក្រមទី១ ដាក់ទោសខ្ញុំភ្លាម ខ្ញុំបានណែនាំឲ្យមេធាវីរបស់ខ្ញុំដាក់ពាក្យបណ្តឹងសាទុក្ខជាបន្ទាន់។

នៅក្នុងបណ្តឹងសាទុក្ខនោះ បានរៀបរាប់ពីកំហុសនានា ដែលលោកចៅក្រមបានសម្រេចទាំងអង្គហេតុនិងអង្គច្បាប់។ នៅក្នុងសាលក្រមនោះមានចំនួនច្រើនជាង ២០០ចំណុច។ ការប្តឹងសាទុក្ខទៅនឹងសាលក្រមនោះ មិនមានន័យថា ខ្ញុំចង់បដិសេធចំពោះការឈឺចាប់របស់ជនរួមជាតិខ្ញុំនោះទេ។ តាមពិតទៅជំហររបស់ខ្ញុំគឺផ្ទុយស្រឡះពីនេះ។ ដូចខ្ញុំបានពន្យល់ជាច្រើនដងរួចមកហើយនៅក្នុងតុលាការនេះថា ខ្ញុំបានទទួលស្គាល់ថាមានជនរួមជាតិជាច្រើន មានការឈឺចាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបង្កឡើងដោយពួកបំផ្លាញស៊ីរូងផ្ទៃក្នុង។ ខ្ញុំសោកស្តាយជាពន់ចំពោះទុក្ខលំបាកនោះ ហើយខ្ញុំសូមទទួលខុសត្រូវផ្នែកសីលធម៌ចំពោះអំពើនេះ ដោយសារខ្ញុំជាមេដឹកនាំជាន់ខ្ពស់ម្នាក់ នៃបក្សកុម្មុយនីស្តកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ដូចខ្ញុំបានពន្យល់ពីខាងដើមរួចមកហើយ នៅក្នុងតុលាការនេះ ខ្ញុំមិនមានចេតនាធ្វើឲ្យជនរួមជាតិខ្ញុំរងទុក្ខបែបនេះឡើយ។ អ្វីៗដែលវាមិនមែនជាការរវើរវាយ និងជារឿងសម្ងាត់អ្វីនោះទេ ដែលថាវៀតណាមបានព្យាយាមលេបទឹកដីកម្ពុជាក្នុងរយៈពេលរាប់រយឆ្នាំមកហើយ

នោះ។ នៅក្នុងសម័យទំនើបចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៣០មក វៀតណាមនិយាយអំពីការបង្កើតសហព័ន្ធឥណ្ឌូចិន។ សហព័ន្ធឥណ្ឌូចិននេះ មានកម្ពុជា វៀតណាម និងឡាវ រួមគ្នាជារដ្ឋមួយនៅក្រោមការត្រួតត្រារបស់វៀតណាម។ នៅថ្ងៃ០៧ មករា ឆ្នាំ១៩៧៩ វៀតណាមសម្រេចបាននូវមហិច្ឆិតានេះមួយផ្នែក នៅពេលវៀតណាមឈ្លានពានប្រទេសកម្ពុជា។

[១៣:៤៩:២០]

ឆ្លើយតបទៅនឹងការឈ្លានពាននេះភ្លាមៗ សម្ដេចព្រះ នរោត្តម សីហនុ បានយាងទៅអង្គការសហប្រជាជាតិ ហើយមានព្រះរាជបន្ទូលនៅចំពោះមុខស្ថានប័នសំខាន់ៗរបស់អង្គការសហប្រជាជាតិ ជាពិសេសក្រុមប្រឹក្សាសន្តិសុខអំពីការឈ្លានពានរបស់វៀតណាមនេះ និងសុំឲ្យអង្គការសហប្រជាជាតិជួយអន្តរាគមន៍ដល់ប្រទេសកម្ពុជា។ ខ្ញុំសូមធ្វើការដកស្រង់បន្ទូលរបស់សម្ដេចព្រះ នរោត្តម សីហនុ ដែលមានព្រះរាជបន្ទូលប្រាប់ក្រុមប្រឹក្សាសន្តិសុខថា "វៀតណាមបានសម្រេចចិត្តធ្វើប្រតិបត្តិការពិសេស ដែលមានគោលបំណងតែមួយគត់ គឺគ្មានអ្វីក្រៅពីលេបយកទឹកដីកម្ពុជា ដូចជាពស់ថ្លាន់មួយស្រេកឃ្លានអាហារ បង្កប់ខ្លួននៅក្នុងចំណោមសត្វស្លូតទាំងឡាយ ដោយរង់ចាំឱកាសស៊ីសត្វទាំងនោះ"។ តាមពិតនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសន្តិសុខ អ្នកការទូតជាច្រើនបានយល់ស្របថាវៀតណាមបានឈ្លានពានប្រទេសកម្ពុជាដោយខុសច្បាប់ រួមទាំងតំណាងរបស់សហរដ្ឋអាមេរិក ចិន និងអូស្ត្រាលី។ នេះមិនមែនជាការរវើរវាយទេ ទាំងអស់នេះបានកត់ត្រានៅក្នុងឯកសាររបស់អង្គការសហប្រជាជាតិជាសាធារណៈ។ ពស់ថ្លាន់វៀតណាមបានបញ្ជូនទាហានឈ្លានពានប្រទេសកម្ពុជាដើម្បីបំពេញសេចក្ដីស្រេកឃ្លានមិនចេះឆ្អែតឆ្អន់ក្នុងការពង្រីកទឹកដី និងគ្រប់គ្រងប្រទេស ប្រជាជនឲ្យបានកាន់តែច្រើនទៅៗ។ សំខាន់បំផុតនោះវៀតណាមបានលួចគាំទ្រកម្មាភិបាលក្បត់មួយចំនួននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ដើម្បីបម្រើគោលបំណងរបស់ពួកគេ។ ការយល់ដឹងពីតួនាទីរបស់វៀតណាម គឺមានសារៈសំខាន់ដើម្បីស្វែងរកការពិតនៃអំពើជាច្រើននៃសវនាការលើកទី២នេះ។

[១៣:៥១:២៤]

អំពើជាច្រើននៃសវនាការនេះរួមមាន៖ ប្រល័យពូជសាសន៍ជនជាតិវៀតណាម ជនជាតិចាម បទល្មើសនៅក្នុងមន្ទីរសន្តិសុខស-២១ និងការបោសសម្អាតផ្ទៃក្នុងនៅភូមិភាគបូព៌ា។ ខ្ញុំសូមបញ្ជាក់ថា បទឧក្រិដ្ឋដែលបានចោទប្រកាន់មកលើរូបខ្ញុំនៅក្នុងសវនាការលើកទី២នេះ គឺតាមពិតបានប្រព្រឹត្តដោយ សោ ភឹម, រស់ ញឹម និងជនក្បត់មួយចំនួនតូចទៀត។ ហើយអំពើទាំងនេះបានប្រព្រឹត្តនៅក្រោមការគ្រប់

គ្រង និងការយល់ដឹងអស់របស់អ្នកដឹកនាំដូចជារូបខ្ញុំជាដើម។ ប្រសិនបើលោក លោកស្រីចៅក្រមកោះហៅលោក ហេង សំរិន មកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការលើកទី២នេះ ខ្ញុំជឿជាក់ថា គាត់នឹងអាចបញ្ជាក់ការពិតពីព្រឹត្តិការណ៍ទាំងនេះ។ នៅក្នុងពាក្យប្តឹងជិតជិតលោកចៅក្រមពីអង្គជំនុំជម្រះសាលាដំបូងរបស់មេធាវីរបស់ខ្ញុំ លោកមេធាវីបានលើកឡើងថា សវនាការលើកទី២នេះមិនអាចបន្តទៀតទេប្រសិនបើចៅក្រមកម្ពុជាបីនាក់ និងចៅក្រមបារាំងម្នាក់ក្នុងចំណោមចៅក្រមទាំងអស់ នៅតែជំនុំជម្រះក្តីរបស់ខ្ញុំទៀតនោះ។

[១៣:៥៣:០៤]

តាមការណែនាំរបស់ខ្ញុំ មេធាវីរបស់ខ្ញុំបានបង្ហាញហេតុផលជាច្រើនចំពោះបញ្ហានេះ ប៉ុន្តែហេតុផលមួយក្នុងចំណោមហេតុផលដ៏សំខាន់ទាំងនេះគឺថា លោកចៅក្រមទាំងបួននាក់បានសម្រេចសេចក្តីនៅក្នុងសាលក្រម នៅក្នុងសវនាការលើកទី១រួចហើយ។ លោកចៅក្រមបានរកឃើញថា ខ្ញុំមានទោស លោកចៅក្រមរកឃើញថា ខ្ញុំពិតជាមានអំណាចនៅក្នុងបក្ស ហើយបក្សបានបង្កើតគោលនយោបាយសំខាន់ៗជាច្រើន។ លោកចៅក្រមបានបង្ហាញថា លោកចៅក្រមមិនអាចបើកចិត្តឲ្យទូលាយដើម្បីទទួលយកអំណះអំណាងដែលខ្ញុំនិងមេធាវីរបស់ខ្ញុំចង់លើកឡើងនោះទេ។ ជាទូទៅ លោកចៅក្រមបានបង្ហាញឲ្យឃើញថា លោកចៅក្រមមិនជឿលើខាងយើងខ្ញុំទេ ហើយលោកចៅក្រមមិនជឿនូវអ្វីៗដែលខ្ញុំបាននិយាយដោយសារតែវាមិនសមទៅនឹងរឿងនិទាន ដែលលោកចៅក្រមបានសរសេរនោះទេ។ លោកចៅក្រមបានដាក់ទោសខ្ញុំនៅក្នុងសាលក្រមលើកទី១ ខ្ញុំជឿជាក់ថា លោកចៅក្រមពិតជាលម្អៀងប្រឆាំងមកលើរូបខ្ញុំនៅក្នុងសវនាការលើកទី២នេះ។

នៅក្រោមកាលៈទេសៈទីនេះ ខ្ញុំមិនយល់ថា ហេតុអ្វីបានលោកចៅក្រមនៅតែអាចបន្តចូលរួមសវនាការទី២នេះទៀតដោយរបៀបណានោះទេ។ ជាការងាយណាស់ ខ្ញុំមិនអាចមើលឃើញថាខ្ញុំអាចទទួលបានសិទ្ធិជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ដើម្បីសន្និតថាខ្ញុំគ្មានទោស រហូតដល់មានការរកឃើញថាមានភស្តុតាងគ្រប់គ្រាន់ដាក់ទោសដោយរបៀបណា។ ប្រសិនបើលោកចៅក្រមនឹងបន្តជំនុំជម្រះរឿងក្តីនេះទៀត វាមិនអាចធ្វើទៅកើតនោះទេ។ ម្យ៉ាងទៀត តុលាការមិនទាន់បានសម្រេចលើបណ្តឹងជិតចិត្តរបស់ខ្ញុំប្រឆាំងនឹងលោកចៅក្រមទាំងបួននាក់នៅឡើយផង។ ខ្ញុំយល់ថា វានឹងចំណាយពេលជាច្រើនខែដើម្បីចេញសេចក្តីសម្រេចនេះ។ នៅក្រោមច្បាប់កម្ពុជា នៅពេលភាគីណាម្នាក់មួយក្នុងពេលភាគីណាមួយដាក់បណ្តឹងជិតចិត្តចំពោះចៅក្រមណាម្នាក់ ចៅក្រមនោះត្រូវបញ្ឈប់កិច្ចការរបស់ខ្លួនភ្លាម ដោយរង់

ចាំការសម្រេចលើបណ្តឹងជិតចិត្តសិន។ តាមពិតមេធាវីរបស់ខ្ញុំប្រាប់ខ្ញុំថា នេះជាការអនុវត្តជាទូទៅក្នុងតុលាការ។ ទោះជាយ៉ាងនេះក្តី ជំនួសដោយការធ្វើបែបនេះលោកចៅក្រមនៅតែបន្តការជំនុំជម្រះក្តីលើកទី២ទៀត។

[១៣:៥៦:៥៦]

លោកចៅក្រមបានបញ្ជាឲ្យខ្ញុំមកបង្ហាញខ្លួននៅក្នុងសវនាការលើកទី២នេះ ហើយលោកចៅក្រមសម្រេចបើកសវនាការលើកទី២នេះ បើទោះជាយើងខ្ញុំកំពុងរង់ចាំសេចក្តីសម្រេចពីបណ្តឹងជិតចិត្តក៏ដោយ។ ការចេញបទបញ្ជាបែបនេះ និងការបើកការជំនុំជម្រះថ្ងៃនេះ លោក លោកស្រី ចៅក្រម ពិតជាបានបង្ហាញនូវការមិនគោរពនីតិវិធីច្បាប់នៃប្រទេសកម្ពុជា។ នេះស្របទៅនឹងឥរិយាបថដែលលោកចៅក្រមបានអនុវត្តនៅក្នុងសវនាការលើកទី១ ដែលមេធាវីរបស់ខ្ញុំបានលើកអំណះអំណាងផងដែរនៅក្នុងបណ្តឹងជិតចិត្ត។ តាមរយៈការជំនុំជម្រះលើកទី១នេះ លោកចៅក្រមបានបង្ហាញពីការមិនគោរពនីតិវិធីឲ្យបានត្រឹមត្រូវ។ ដើម្បីបម្រើគោលបំណងរបស់ខ្លួន លោកចៅក្រមបានកំណត់ និងអនុវត្តនីតិវិធីជាច្រើនដែលមិនស៊ីសង្វាក់គ្នានៅក្នុងអំឡុងពេលសវនាការ។ ជារឿយៗ លោកចៅក្រមបានរំលោភសិទ្ធិរបស់ខ្ញុំក្នុងការទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌ ដូចដែលមេធាវីរបស់ខ្ញុំនឹងលើកឡើងយ៉ាងលម្អិតនៅក្នុងបណ្តឹងសាទុក្ខរបស់ពួកគាត់ចំពោះសាលក្រមលើកទី១។ ខ្លួនខ្ញុំផ្ទាល់ ខ្ញុំចង់ឆ្លៀតឱកាសនេះស្នើសុំលោកចៅក្រមទាំងអស់លើកលែងតែចៅក្រមថ្មី ពិចារណាលើសេចក្តីសម្រេចរបស់ខ្លួនក្នុងការចូលរួមបន្តសវនាការនេះ។ ខ្ញុំស្នើសុំឲ្យលោកចៅក្រមបញ្ឈប់សវនាការឥឡូវនេះ ដោយរង់ចាំរហូតដល់តុលាការចេញសេចក្តីសម្រេចថា តើលោកចៅក្រមមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់សវនាការលើកទី២នេះឬទេ។ ខ្ញុំយល់ថា វាអាចចំណាយពេលប្រហែលជាបីខែសម្រាប់សម្រេចលើបណ្តឹងជិតចិត្ត។ ឥឡូវនេះខ្ញុំដឹងថា លោកចៅក្រមចង់ឲ្យសវនាការលើកទី២នេះ ប្រព្រឹត្តទៅឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ ខ្ញុំក៏មានបំណងបែបនេះដែរ ដើម្បីមានឱកាសជម្រាបជនរួមជាតិខ្ញុំគ្រប់រូប នូវអ្វីដែលបានកើតឡើង។ ប៉ុន្តែយើងបានរង់ចាំអស់រយៈពេលប្រាំពីរឆ្នាំ មួយខែមកហើយ។ ការរង់ចាំបីខែទៀតសម្រាប់ការសម្រេចលើបណ្តឹងជិតចិត្តនោះក៏មិនជាអ្វីដែរ។ ប្រសិនបើលោកចៅក្រមមិនផ្អាកសវនាការក្នុងខណៈពេលបណ្តឹងជិតចិត្ត កំពុងពិនិត្យសេចក្តី -- កំពុងពិនិត្យ និង សម្រេចនោះ លោកចៅក្រមធ្វើឲ្យខ្ញុំគ្មានជម្រើសផ្សេងទេ។ ខ្ញុំសូមណែនាំ និងស្នើសុំមេធាវីរបស់ខ្ញុំឲ្យចេញពីបន្ទប់សវនាការបន្ទាប់ពីលោកខៀវ សំផន ប្រកាសពីជំហររបស់គាត់ ហើយនិងពហិកា មិនចូលរួមរាល់សវនាការនាពេលខាងមុខនៃ

សវនាការលើកទី២នេះ រហូតដល់បណ្ដឹងឧិតចិត្តត្រូវបានសម្រេច។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ អនុរក្សមន្ទីរឃុំឃាំងនាំគាត់ទៅកាន់កន្លែងដែលគាត់អង្គុយនៅក្រោយមេធាវីរបស់គាត់វិញចុះ។

បាទ ជាបន្តអង្គជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន អ៎! លោក នួន ជា ដើម្បីមានឱកាសក្នុងការធ្វើសេចក្ដីថ្លែងសន្និដ្ឋានតបទៅនឹងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា។

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការសាជាថ្មី។ ក្រោយពីលោក នួន ជា បានធ្វើសេចក្ដីសន្និដ្ឋានរួចហើយ ខ្ញុំមេធាវីទាំងពីរមិនមានសេចក្ដីសន្និដ្ឋានបន្តទេ ទុកភារៈជូនខាងក្រុមមេធាវីលោក ខៀវ សំផន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយជាបន្តទៅនេះ អង្គជម្រះផ្ដល់វេទិកាជូនទៅដល់ជនជាប់ចោទ ខៀវ សំផន និងមេធាវីការពារក្ដីរបស់គាត់។ អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់ ទៅអង្គុយនៅមុខឈើរាងវង់ក្រចកសេះដែលនៅពីមុខអង្គជំនុំជម្រះនេះ។

សូមអញ្ជើញលោក ខៀវ សំផន!

[១៤:០៥:១០]

**លោក ខៀវ សំផន៖**

សូមគោរពលោកប្រធាន អស់លោក លោកស្រី ចៅក្រម។ អស់លោកទាំងអស់ ដែលមានមុខនៅទីនេះ។ ព្រះសង្ឃគ្រប់ព្រះអង្គនៅតាមក្នុងវត្តអារាមនានាទូទាំងប្រទេសជាទីសក្ការៈ។ បងប្អូនរួមជាតិជាទីគោរពស្នេហា។ ជាដំបូង ខ្ញុំសូមអរគុណលោកប្រធាន ដែលបានអនុញ្ញាតឲ្យខ្ញុំឡើងនិយាយ។ កាលពីថ្ងៃ០៧ សីហា មុននេះ អង្គជំនុំជម្រះសាលាដំបូងបានកាត់ទោសខ្ញុំដាក់គុកមួយជីវិត ក្នុងការកាត់ក្ដីសំណុំរឿង០០២/០១។

អស់លោក បានកាត់ទោសខ្ញុំ ដោយផ្អែកលើទម្រង់ភស្ដុតាង និងការស្មាននានាដែលខ្ញុំជំទាស់ ហើយដោយប្រើមធ្យោបាយ ដែលខ្ញុំយល់ឃើញថាជាការរំលោភលើសិទ្ធិរបស់ខ្ញុំ ដែលខ្ញុំត្រូវមាន ត្រូវបានទទួលការកាត់ក្ដីដោយយុត្តិធម៌។ ហេតុនេះហើយបានជាខ្ញុំបានជម្រាបមេធាវីខ្ញុំ ឲ្យប្ដឹងឧទ្ធរណ៍ដែល

ក្នុងតុលាការនេះ គេហៅថា"បណ្ដឹងសាទុក្ខ"។ តាំងពីថ្ងៃកាត់ទោសនេះមក ការងារខ្ញុំ និងក្រុមការពារក្ដីរបស់ខ្ញុំ ប្រមូលផ្ដុំលើការងាររៀបចំបណ្ដឹងឧទ្ធរណ៍។ ការងារនេះរឹតតែមានសារៈសំខាន់ខ្លាំងណាស់ទៅទៀត ពីព្រោះសេចក្ដីសំអាងហេតុនិងសេចក្ដីសន្និដ្ឋានរបស់អស់លោក នៅក្នុងការកាត់ក្ដីនេះបង្ហាញច្បាស់ជារួចស្រេចទៅហើយ។ អស់លោកនឹងសម្រេចយ៉ាងណានៅក្នុងការកាត់ក្ដីសំណុំរឿង០០២/០២ ខាងមុខនេះ គ្មានអ្វីគួរឲ្យខ្ញុំស្រពិចស្រពិលទេ។ បើអស់លោកនៅតែប្រើរបៀបគិតគូរ ដែលខ្ញុំជំទាស់នៅចំពោះមុខតុលាការកំពូល ទាក់ទងនឹងការចោទប្រកាន់ថាខ្ញុំបានចូលរួមប្រព្រឹត្ត សហឧក្រិដ្ឋកម្មរួម។ ខ្ញុំដឹងជាមុនស្រេចទៅហើយថា អស់លោកប្រាកដជានឹងផ្ដន្ទាទោសខ្ញុំទៀត ក្នុងការកាត់ក្ដី ដែលអស់លោកកំពុងតែបើកនៅថ្ងៃនេះ។ យើងខ្ញុំបានធ្វើពាក្យប្ដឹងដកសេចក្ដីទុកចិត្តពីអស់លោក ដែលក្នុងតុលាការនេះ គេហៅថា "បណ្ដឹងដិតចិត្ត"។ រហូតមកដល់ពេលនេះ នៅមិនទាន់មានការសម្រេចយ៉ាងណានៅឡើយ។

[១៤:០៨:១៤]

ក្នុងសភាពរង់ចាំសេចក្ដីសម្រេចចិត្តលើពាក្យបណ្ដឹងយើងខ្ញុំនេះ អស់លោក មិនត្រូវចាត់ការអ្វីតទៅទៀតទេ តែមិនដូច្នេះ អស់លោកនៅតែទទូចបើកសវនាការវគ្គទី២ ដែលខ្ញុំទើបនិយាយអម្បាញ់នេះថា ខ្ញុំដឹងមុនស្រេចទៅហើយ តើនៅទីបញ្ចប់នេះ អស់លោកនឹងកាត់ក្ដីយ៉ាងណានោះ។

ដូច្នេះ ទោះបីយ៉ាងណាក៏ដោយ ដើម្បីការពារខ្លួនខ្ញុំ ខ្ញុំគ្មានលទ្ធភាពអ្វីផ្សេងក្រៅពីធ្វើយ៉ាងណាឲ្យបណ្ដឹងឧទ្ធរណ៍របស់ខ្ញុំនៅតុលាការកំពូល ត្រូវបានតុលាការកំពូលទទួលយល់ស្របតាម ហើយបដិសេធការកាត់ទោសរបស់អស់លោកកាលពីថ្ងៃទី០៧ ខែសីហា នោះទេ។ ទោះបីមេធាវីខ្ញុំ បានខិតខំពន្យល់យ៉ាងច្បាស់ណាស់ ក្នុងសំណើសុំពន្យារពេលហើយ យ៉ាងណាក៏ដោយ ថាគាត់មិនអាចរៀបចំសារណាបណ្ដឹងឧទ្ធរណ៍បានហ្មត់ចត់ទេ បើរវល់តែងាកមកចូលរួមសវនាការនៃកាត់ក្ដីសំណុំរឿង០០២/០២ ផងនោះ។ អស់លោកនៅតែទទូចបើកសវនាការមុនថ្ងៃដែលខ្ញុំ និង មេធាវីខ្ញុំត្រូវដាក់សារណាបណ្ដឹងឧទ្ធរណ៍ទៀត។ មេធាវីខ្ញុំបានប្រាប់ខ្ញុំថា គាត់មិនអាចចំណាយពេលមកចូលរួមសវនាការផង ហើយរៀបចំសារណាបណ្ដឹងឧទ្ធរណ៍ដ៏សំខាន់នេះឲ្យបានហ្មត់ចត់ផងទេ។ ដូច្នេះ ការសម្រេចរបស់ខ្ញុំ តើត្រូវធ្វើយ៉ាងណានៅចំពោះសភាពការណ៍បែបនេះ? ជាការសម្រេចមួយដ៏លំបាកបំផុតដែលអង្គជំនុំជម្រះបានបង្ខំឲ្យខ្ញុំធ្វើ ហើយខ្ញុំយល់ថាមិនយុត្តិធម៌ទេ ដែលអស់លោករុញច្រានឲ្យខ្ញុំធ្លាក់ក្នុងសភាពការណ៍បែបនេះ។ តែបើគ្មានផ្លូវណាជ្រើសរើសទេនោះ ខ្ញុំត្រូវបង្ខំចិត្តជម្រាបមេធាវីខ្ញុំឲ្យធ្វើយ៉ាងណាដើម្បីសារណាបណ្ដឹង

ឧទ្ធរណ៍របស់ខ្ញុំមានលទ្ធភាពអតិបរិមា ត្រូវបានតុលាការកំពូលទទួលបាន គឺថាឲ្យចំណាយពេលវេលាដែលគេផ្តល់ឲ្យក្នុងក្របខ័ណ្ឌនៃការការពារក្តីខ្ញុំ ដើម្បីរៀបចំសារណាបណ្តឹងឧទ្ធរណ៍របស់ខ្ញុំឲ្យបានល្អចុះ។ មានន័យថា គាត់ពុំអាចមកចូលរួមសវនាការក្នុងការកាត់ក្តីសំណុំរឿង០០២/០២បានទេ។ ទោះបីជាការកាត់ក្តី ជាកិច្ចការពារក្តីខ្ញុំក្នុងសំណុំរឿង០០២/០២នេះ មានសារៈសំខាន់យ៉ាងណាក៏ដោយ ព្រោះបើគាត់មកចូលរួម ក៏គាត់មិនអាចរៀបចំកិច្ចការពារក្តីខ្ញុំបានល្អដែរ ហើយក៏គ្មានពេលរៀបចំសារណាបណ្តឹងឧទ្ធរណ៍បានល្អផងទៀតនោះទេ។ សរុបមក បើមេធាវីខ្ញុំងាកមកចូលរួមសវនាការក្នុងការកាត់ក្តីសំណុំរឿង០០២/០២ បើនិយាយតាមពាក្យបុរាណខ្មែរ “ទន្សាយក៏រួច ត្រីរ៉ស់ក៏រួច”។ ដូច្នេះ ខ្ញុំយកវិធីណាក៏ដៀសមិនផុតពីត្រូវប៉ះពាល់ដល់កិច្ចការពារក្តីរបស់ខ្ញុំ។ ក្រោយពីបានគិតពិចារណា ហើយពិគ្រោះពិភាក្សាជាមួយមេធាវីខ្ញុំទៅ ខ្ញុំសម្រេចជ្រើសរើសយកវិធីដែលប៉ះពាល់ដល់កិច្ចការពារក្តីខ្ញុំ មិនសូវធ្ងន់ធ្ងរពេក។ ចំណែកឯខ្លួនខ្ញុំវិញ ចាប់ពីថ្ងៃបើកសវនាការកាត់ក្តីខ្ញុំមក ខ្ញុំបានខិតខំធ្វើការលើសំណុំរឿងរបស់ខ្ញុំគ្មានឈប់ឈរទេ។ ថ្មីៗនេះ ខ្ញុំហត់នឿយពេកទៅ ទៅជាធ្លាក់ខ្លួនឈឺ ហើយត្រូវទៅសម្រាកពេទ្យដោយខ្ញុំធ្វើការហួសកម្លាំង។ តាមច្បាប់នៅក្នុងតុលាការ ខ្ញុំត្រូវមានលទ្ធភាពពេញលេញដើម្បីរួមធ្វើការជាមួយក្រុមការពារក្តីខ្ញុំបាទ ដរាបណាបណ្តឹងឧទ្ធរណ៍របស់ខ្ញុំមិនទាន់ចប់សព្វគ្រប់ដើម្បីយកទៅដាក់ឲ្យទាន់ពេលវេលា។ ប៉ុន្តែ ខ្ញុំដឹងថា ខ្ញុំមិនសេរីភាពដូចមេធាវីខ្ញុំទេ ដើម្បីខ្ញុំមិនបាច់មកចូលរួមសវនាការនេះ ហើយបន្តធ្វើការតទៅទៀតនៅក្នុងបន្ទប់ឃុំឃាំង។

[១៤:១៥:០០]

ដូច្នេះ ថ្ងៃនេះ ខ្ញុំសូមប្រកាសជាឱឡារិកថា ដើម្បីខ្ញុំអាចចំណាយពេលធ្វើការតទៅទៀតក្នុងការពារក្តីលើបណ្តឹងឧទ្ធរណ៍របស់ខ្ញុំ ខ្ញុំមិនមានបំណងមកចូលរួមសវនាការទេ បើតុលាការបង្ខំឲ្យខ្ញុំចូលរួមសវនាការ ជាការពិតហើយ ខ្ញុំមិនអាចប្រឆាំងបានទេ។ ប៉ុន្តែខ្ញុំត្រូវការឲ្យមានការកត់ត្រាក្នុងកំណត់ឲ្យច្បាស់លាស់ថា រាល់ថ្ងៃដែលខ្ញុំត្រូវមកមានមុខនៅទីនេះ គឺដោយមានការបង្ខិតបង្ខំ។ ហើយនេះជាការរំលោភលើសិទ្ធិរបស់ខ្ញុំ ដែលខ្ញុំត្រូវមាន ដើម្បីខ្ញុំអាចចូលរួមធ្វើការក្នុងការរៀបចំសារណាបណ្តឹងឧទ្ធរណ៍របស់ខ្ញុំរហូតដល់បានត្រូវយកទៅដាក់នោះ។ ខ្ញុំសូមជម្រាបអង្គជំនុំជម្រះដោយឱឡារិកយ៉ាងនេះដើម្បីជ្រាប។

សូមអរគុណ។ ខ្ញុំសូមបន្ថែមបន្តិច។ ចំពោះសំណួរលោកប្រធាន ដែលបានលើកឡើងចំពោះខ្ញុំពីព្រឹកមិញ ខ្ញុំសូមជម្រាបលោកប្រធាននៅពេលណាដែលមេធាវីខ្ញុំ និងខ្ញុំរៀបចំសារណាឧទ្ធរណ៍បានចប់

សព្វគ្រប់ ហើយយកទៅដាក់បានទាន់ពេលវេលា ព្រមទាំងនៅពេលណាដែលមេធាវីទាំងអស់គ្នា ខ្ញុំទាំងអស់គ្នា ក៏ត្រឡប់មកចូលរួមសវនាការនេះវិញ។ បាទ សូមជម្រាបប៉ុណ្ណឹងបាទ។ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ខៀវ សំផន។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនគាត់ត្រឡប់ទៅទីកន្លែងដែលគាត់នៅអង្គុយក្រោយ កៅអីក្រោយមេធាវីរបស់គាត់ចុះ!

បាទ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

[១៤:១៨:២៤]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ លោក លោកស្រី ចៅក្រម ជាទីគោរព ចម្លើយកូនក្តីរបស់ខ្ញុំច្បាស់លាស់ហើយ។ ខាងការពារក្តីរបស់យើងនេះយល់ឃើញថា យើងមិនចាំបាច់និយាយឡើងវិញអ្វីដែលគាត់បានលើកឡើងទេ គឺថាការប្តឹងឧទ្ធរណ៍នេះគឺជាការសំខាន់ណាស់ ហើយនៅក្នុងពេលឥឡូវនេះ នីតិវិធី -- សំខាន់ជាងគេបំផុតចំពោះគាត់នោះ គឺប្តឹងឧទ្ធរណ៍នេះហើយ ពីព្រោះការងារនេះវាអាចជះឥទ្ធិពលទៅលើរូបគាត់។

ប្រហែលជាសមហេតុសមផលជាងក្នុងអាច -- ប្រសិនជាធ្វើ គាត់អាចឆ្លើយបានព្រឹកមិញនោះវាជាការប្រសើរជាង ក៏ប៉ុន្តែដោយសារលោកប្រធានកាត់មីក្រូ អ៊ីចឹងមិនអាចឆ្លើយបាន។ អ៊ីចឹងហើយបានលោក ខៀវ សំផន បាននិយាយតែពេលអម្បាញ់មិញនេះទេ។ យើង ទោះបីជាកូនក្តីរបស់យើងបានបញ្ជាយើងកាលពីព្រឹកមិញនេះមកថា មិនឲ្យនៅទីនេះក៏ដោយ ក៏យើងនៅតែនៅក្នុងសាលសវនាការនេះទៀត ដោយសារយើងការពារផលប្រយោជន៍របស់គាត់ ហើយយើងក៏ត្រូវពន្យល់ពីផលប្រយោជន៍របស់គាត់ផងដែរ។ ចំពោះយើង យើងយល់ឃើញថា មិនអាចៗនៅទីនេះបានទេដោយមិនពន្យល់ពីមូលហេតុទាំងឡាយប្រាប់ទៅអស់លោក លោកស្រី ចៅក្រម អំពីមូលហេតុដែលយើងមិនចង់ស្ថិតនៅទីនេះ។ នៅពេលដែលយើងនៅទីនេះ ខ្ញុំគិតថាគេទាំងអស់គ្នាគិតថា យើងកំពុងតែនិយាយរករឿងគេ ឬក៏ចំអកជាដើម ព្រោះគេតែងតែគិតថា ការដែលយើងតវ៉ានេះជាការចំអក។ យើងខាងមេធាវីការពារក្តីគេតែងតែនិយាយមកប្រាប់យើងថា អ្នកឯងមកទីនេះនិយាយអី បើទោះបីយ៉ាងណាកូនក្តីរបស់អ្នកឯងគេកាត់ទោសទៅហើយ មិនអាចរួចខ្លួនទេ ទោះបីជាខំប្រឹងប្រែងនិយាយយ៉ាងម៉េចក៏ដោយ។ ក៏ប៉ុន្តែ

ត្រង់ចំណុចនេះហើយ អស់លោក លោកស្រីចៅក្រម ជាទីគោរព! នេះហើយដែលថាតួនាទីរបស់មេធាវីការពារក្តី ធ្វើយ៉ាងណាឲ្យកាត់ក្តីឲ្យបានយុត្តិធម៌ ហើយយើងពន្យល់ពីមូលហេតុរបស់យើង ទោះបីតុលាការចេញសេចក្តីសម្រេចផ្ទុយពីអ្វីដែលយើងចង់បានក៏ដោយ ក៏យើងត្រូវតែបង្ហាញពីមូលហេតុរបស់យើងដែរ។ គោលជំហររបស់លោក ខៀវ សំផន មានន័យណាស់នៅពេលដែលយើងបានស្តាប់ពីអ្វីដែលខាងសហព្រះរាជអាជ្ញាបានរៀបរាប់កាលពីព្រឹកមិញនេះ ដូចជាលោកស្រី ជា លាង បាននិយាយព្រឹកមិញថា យើង -- បើនិយាយទៅគាត់សុំឲ្យអស់លោក លោកស្រី ចៅក្រមហ្នឹងកាត់ទោសលោក ខៀវ សំផន ឲ្យជាប់ទោសមួយជីវិតមួយជាន់ទៀតទៅហើយ តាមការរៀបរាប់កាលពីព្រឹកមិញនេះ។

[១៤:២១:៣៣]

អ៊ីចឹងបានន័យថា បណ្តឹងឧទ្ធរណ៍យើងដែលយើងកំពុងតាក់តែងនេះ មានសារៈសំខាន់ណាស់ យើងត្រូវតែធ្វើការងារនេះឲ្យបានល្អ។ អ៊ីចឹង យើងមិនមែនចង់ឲ្យអូសបន្លាយពេលវេលាអីទេ យើងចង់ការពារគាត់ឲ្យបានពេញលេញ។ តើយើង -- បើយើងថា យើងធ្វើអ្វីដែលយើងធ្វើទាំងអស់នេះ គឺថាធ្វើយ៉ាងណាកុំឲ្យរឿងដែលកើតឡើងនៅក្នុងសំណុំរឿង០០២/០១ នេះតទៅទៀតនៅក្នុងរឿង០០២/០២។ អ៊ីចឹងព្រោះថា ការ -- រឿងរ៉ាវទាំងអស់ហ្នឹងកើតឡើងតាំងពីយូរណាស់មកហើយ ៗទើបតែកាត់ទោសឥឡូវនេះ ហើយលោក ខៀវ សំផន គាត់អាយុប៉ុណ្ណឹងហើយ តើគាត់ប្រញាប់ទៅណាទៀត បើកាត់ទោសឲ្យគាត់ជាប់ទោសមួយជីវិតទៅហើយនោះ។ អ៊ីចឹង ត្រូវតែចំណាយពេលបន្តិចទៀត ចាំបន្តិចទៀតមិនខាតអីនោះទេ យើងដើម្បីធ្វើតាក់តែងបណ្តឹងឧទ្ធរណ៍នេះឲ្យបានល្អ លម្អិតឲ្យបានល្អដើម្បីឲ្យតុលាការកំពូលគាត់ពិចារណា។

តើ -- បើយើងមិនមានមធ្យោបាយគ្រប់គ្រាន់ទេ យើងធ្វើការយ៉ាងម៉េចទៅ មកចូលរួមសវនាការផង ទៅតាក់តែងបណ្តឹងឧទ្ធរណ៍ផង។ ខ្ញុំគិតថាពេលដែលគេ -- នៅពេលនិយាយថាពេលវេលាតែប៉ុណ្ណោះជាការគ្រប់គ្រាន់ទៅហើយ។ មិនមានន័យទេការនិយាយដូច្នេះ។ ខ្ញុំគិតថា យើងឥឡូវនេះ យើងកំពុងតែកាត់សេចក្តីជាមួយចៅក្រមដដែលៗ ហើយនិងមានភស្តុតាងដដែលៗ កាត់ក្តីមានន័យអ្វីអីទៅ។ យើងមិនអាចជំទាស់ហេតុផលនេះទេឬ? ដូច្នេះយើងត្រូវតែដាក់បណ្តឹងសាទុក្ខ។ ខ្ញុំមិនយល់ពីអនុស្សរណៈមួយរបស់សាលាដំបូងទេ គឺ E318 មាននៅកថាខណ្ឌមួយដែលខ្ញុំមិនយល់ទាល់តែសោះ អង្គជំនុំជម្រះដែលចែងថា "អង្គជំនុំជម្រះមិនជាប់កាតព្វកិច្ចទេ" គឺថាមិនជាប់កាតព្វកិច្ចទៅលើសេចក្តីសន្និដ្ឋានមួយទេ ទោះបីជាខ្លួន -- ឥឡូវនេះគេកំពុងតែនិយាយប្រាប់ថា ខ្ញុំត្រូវតែធ្វើហាក់ដូចជាគ្មានរឿងអ្វីកើតឡើង

អ៊ីចឹង គឺថាក្រុមការពាររបស់លោក ខៀវ សំផន គិតថាដូចជាគ្មានអ្វីរឿងអ្វីកើតឡើង ហើយ ខៀវ សំផន នោះខ្លួនឯងក៏ត្រូវគិតដូច្នេះដែរ ហាក់ដូចជាយើងហ្នឹងអាចគិតថា អស់លោក លោកស្រី ចៅក្រម បានធ្វើសេចក្តីសម្រេចក្នុងរយៈពេលប្រាំបីខែ ចេញជា៧០០ទំព័រ ៨០០ទំព័រជាង ហើយរយៈពេលប៉ុន្មានក្រោយមកចេញសេចក្តីសម្រេច សេចក្តីសន្និដ្ឋានមួយខុសពីហ្នឹងទៅទៀត។ ខ្ញុំមិនល្ងង់ដល់ថ្នាក់ហ្នឹងទេ មិនឆោតដល់ថ្នាក់ហ្នឹងទេ ព្រោះថាបើតាមមើលឃើញមកហ្នឹងគឺលទ្ធផលនៅតែជាដដែលៗទេ។ តាមភស្តុតាងដែលអស់លោក លោកស្រី ចៅក្រម ប្រើហ្នឹង គឺថាអស់លោក លោកស្រី ចៅក្រម នឹងប្រើភស្តុតាងដដែលដើម្បីកាត់ទោសគាត់។ បើសិនជាផ្អែកសំអាងហេតុវាដដែលនេះ វាជាការពិតណាស់ដែលលោក ខៀវ សំផន ហ្នឹងត្រូវតែធ្វើយ៉ាងណារកតុលាការជាន់ខ្ពស់លើសពីហ្នឹង ដើម្បីឲ្យកាត់សេចក្តីឲ្យគាត់។ បើមិនដូច្នោះទេ នៅក្នុងការជម្រះសេចក្តី ០០២/០២ នេះអ្វី -- ការសំណួរសួរផ្លាញ់ សួរផ្ទាញ់ ឬក៏អ្វីដែលយើងចង់តតាំងអ្វីនោះ គឺថានឹងទទួលលទ្ធផលដដែលជាដដែលទេ។ គឺថា ក្នុងន័យថាការកាត់ទោសគាត់ហ្នឹងវាធ្វើហើយជាមុនស្រេចទៅហើយ។ អ៊ីចឹងយើងមិនអាចគិតថា ដូចជាគ្មានអ្វីរឿងអ្វីកើតឡើងនោះទេ ព្រោះវាមានហេតុផលមួយច្បាស់លាស់សម្រាប់គោលជំហររបស់យើង។

[១៤:២៦:១៧]

ដូច្នេះយើងនឹងសុំសំណើទៅតុលាការកំពូល សុំឲ្យផ្តល់ទំព័រច្រើនជាងមុន ពេលវេលាច្រើនជាងមុន ពីព្រោះមានសារៈសំខាន់សម្រាប់លោក ខៀវ សំផន។ យើងមិនអាចធ្វើ មកចូលរួមសវនាការនេះផង ហើយទៅសរសេរបណ្តឹងសាទុក្ខបានទេ។ ដូច្នេះ តើយើងត្រូវជ្រើសរើសយកមួយណា? យើងត្រូវសរសេរបណ្តឹងសាទុក្ខឲ្យបានល្អ ឬក៏មកចូលរួមសវនាការនេះ? អ៊ីចឹងនេះគឺជា វាហាក់ដូចជាគេសួរថា ចង់កើតគ្រុនឈាម -- យកគ្រុនឈាម ឬក៏យកអាសន្នរោគ? បើគិតទៅវាវិបាកដូចតែគ្នាទេ។ អ៊ីចឹងជាជម្រើសមួយពិបាក។ អាកទួរ វែកគេន សហការីរបស់ខ្ញុំបាននៅប៉ារីស គាត់ទៅជួបជាមួយខ្ញុំ។ យើងបានពិភាក្សាគ្នា ហើយយើងបានសម្រេចថាយើងជ្រើសរើសយកបណ្តឹងឧទ្ធរណ៍។ ហើយអស់លោក លោកស្រី ចៅក្រម មានលទ្ធភាពបិទមាត់យើង ហើយនាំឲ្យលោក ខៀវ សំផន មកចូលរួមសវនាការសំណុំរឿង០០២ ហើយឥឡូវនេះគាត់បានជម្រាបហើយ។ គាត់ថា គាត់បានជម្រាបជូនអម្បាញ់មិញហើយ គាត់ថាគាត់ជ្រើសរើសយកបណ្តឹងសាទុក្ខ។ អស់លោក លោកស្រី ចៅក្រម អាចមិនស្តាប់ពីហេតុផលរបស់យើងបាន ក៏ប៉ុន្តែយើងមានកាតព្វកិច្ចក្នុងការជ្រើសរើសការពារផលប្រយោជន៍កូនក្តីរបស់យើង ហើយការពារផលប្រយោជន៍របស់គាត់នេះ គឺបានន័យថា ធ្វើតាក់តែងបណ្តឹងសាទុក្ខឲ្យបានល្អ

ហើយលើកពីកំហុសនីតិវិធី ពីកំហុសច្បាប់ជាដើមរបស់អង្គជំនុំជម្រះសាលាដំបូងនេះ។ ពីព្រោះថា ដូចអស់លោក លោកស្រី ចៅក្រម សង្កេតឃើញខ្លួនឯងហើយ គឺថា សេចក្តីសម្រេចរបស់តុលាការកំពូលនឹងអាចជះឥទ្ធិពលទៅលើសំណុំរឿង០០២/០២ នេះ។ ដូច្នេះយើង -- អស់លោក លោកស្រីចៅក្រម ដឹងខ្លួនឯងហើយថា យើងមិនត្រូវកាត់ក្តីដើម្បីបំពេញចិត្តអ្នកផ្តល់ជំនួយនោះទេ។ ដូច្នេះ ឥឡូវនេះអង្គជំនុំជម្រះនេះកំពុងតែធ្វើការងារ ឬក៏ថាដើរតាមនីតិវិធីមួយដែលមិនសមស្រប។ ឥឡូវនេះខ្ញុំសូមផ្តល់វេទិកាទៅឲ្យសហភាតារបស់ខ្ញុំលោក គង់ សំអុន។

[១៤:២៨:៥៨]

សូមជ្រាបផងដែរថា យើងមិនមែនកំពុងតែរត់ចោលជួរទេ។ នេះគឺជាជម្រើស ជាយុត្តិសាស្ត្រការពារក្តីដែលធ្វើតាមតែលទ្ធភាពដែលយើងមាន ដែលជម្រើសតិចមួយដែលយើងមាន មធ្យោបាយដ៏តិចតួចរបស់យើងក្នុងការធ្វើជម្រើសនេះ។ ហើយជាការជ្រើសរើសមួយដែលត្រឹមត្រូវដែលខ្ញុំសង្ឃឹមថានឹងអាចជៀសវាងកុំឲ្យមានការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់គាត់។

ដូច្នេះ យើងនឹងលើកឡើង បើសិនជាមានករណីរំលោភសិទ្ធរបស់គាត់។ ក៏ប៉ុន្តែឥឡូវនេះខ្ញុំសូមជម្រាបជូនថា ដើម្បីប្រយោជន៍របស់កូនក្តីរបស់យើងនៅក្នុងដំណាក់កាលនេះ គឺមានតែត្រៀមលក្ខណៈចំណាយពេលវេលាសព្វបែបយ៉ាងដើម្បីតាក់តែងនូវសារណាបណ្តឹងសាទុក្ខនេះឲ្យបានល្អទេ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

សុំទោស។ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញារង និង សហភាតាទាំងអស់។ សូមគោរពសាធារណជនដែលមានវត្តមាននៅទីនេះក៏ដូចជាកំពុងទស្សនានូវការជំនុំជម្រះនេះផ្ទាល់ផងដែរ។ ដូចលោក លោកស្រី បានជ្រាបអម្បាញ់មិញហើយនូវសេចក្តីថ្លែងការដែលជាជំហររបស់លោក ខៀវ សំផន ទាក់ទងទៅនឹងជម្រើសលោក ខៀវ សំផន ក្នុងការរៀបចំធ្វើបណ្តឹងសាទុក្ខ និងការចូលរួមក្នុងសវនាការក្នុងសំណុំរឿង០០២/០២ នេះ។

ជម្រើសរបស់លោក ខៀវ សំផន មិនមែនជាជម្រើសល្អឥតខ្ចោះសម្រាប់លោកទេ។ ក៏ប៉ុន្តែ វាអាចបញ្ចៀសនូវចំណុចអាក្រក់ខ្លាំងដល់រូបលោកតែប៉ុណ្ណោះ។ ដូច្នេះ ក្នុងនាមយើងខ្ញុំជាសហមេធាវី

ការពារ យើងត្រូវធ្វើការទៅតាមការណែនាំរបស់កូនក្តីរបស់ខ្លួនស្របទៅតាមច្បាប់ លក្ខន្តិកៈមេធាវី ក៏ដូចជាក្រមសីលធម៌មេធាវីដែរ។

ខ្ញុំសូមជម្រាបជូនថា ក្នុងនាមជាមេធាវី យើងមិនអាចបដិសេធទាំងស្រុងចំពោះសំណើរបស់កូនក្តីខ្លួនទេ ឬការណែនាំរបស់កូនក្តីខ្លួនទេ លើកលែងតែក្នុងករណីយើងត្រូវចាកចេញពីកូនក្តី។ អ៊ីចឹងក្នុងលក្ខខណ្ឌនេះ យើងអាចមានជម្រើសថា យើងនៅការពារបន្តដោយព្រមតាមការណែនាំរបស់កូនក្តី ឬមួយក៏ត្រូវការពារលោក ខៀវ សំផន។ នេះជាជម្រើសរបស់យើងជាមេធាវី។ ប៉ុន្តែ ក្នុងអ្វីដែលជាការសម្រេចចិត្តរបស់យើងខ្ញុំជាសហមេធាវីនេះ គឺយើងបន្តការពារលោក ខៀវ សំផន ក៏ប៉ុន្តែយើងទទួលយកការងារក្នុងការធ្វើបណ្តឹងសាទុក្ខ ដោយមិនបានចូលរួមនៅក្នុងនីតិវិធីសវនាការនៃសំណុំរឿង០០២ របស់អង្គជំនុំជម្រះសាលាដំបូងនេះទេ។

[១៤:៣២:៥១]

បញ្ហានេះ វាអាចធ្វើឱ្យយើងជួបនូវការលំបាកជាច្រើន ដោយសារការមិនបានតាមដាននៅក្នុងសវនាការ ក៏វាជាផលប៉ះពាល់ដល់លោក ខៀវ សំផន ក្នុងការរៀបចំការពារលោក ខៀវ សំផន។ ហើយបើយើងបោះបង់ចោលពេលវេលាក្នុងការរៀបចំធ្វើបណ្តឹងសាទុក្ខ វាធ្វើឱ្យផលប្រយោជន៍នៃការពិនិត្យទៅលើគុណភាពទៅលើបណ្តឹងសាទុក្ខរបស់យើងអាចមានជាចំណោទដែរ។ ដូចលោក ខៀវ សំផន គាត់បានលើកថា អាចធ្វើឱ្យគាត់ណ៎ះ! ក្នុងស្ថានភាពមួយដែលត្រីរ័ស់ក៏រួច ទន្សាយក៏រួច បាទ។

ខ្ញុំអាចមើលឃើញពីភាពចាំបាច់របស់តុលាការដែលតម្រូវឱ្យពន្លឿននីតិវិធីជំនុំជម្រះនេះ ដោយសារបញ្ហាប្រឈមផ្សេងៗ។ ឧទាហរណ៍ វ័យចាស់ជរារបស់ជនជាប់ចោទ និងការត្រូវចំណាយថវិកាច្រើនរបស់អង្គជំនុំជម្រះនេះជាដើម។ ក៏ប៉ុន្តែ ខ្ញុំសូមអង្គជំនុំជម្រះមេត្តាពិនិត្យថា បញ្ហាប្រឈមទាំងអស់នេះមិនអាចយកមកធ្វើជាមូលដ្ឋានដើម្បីបំពានសិទ្ធិការពាររបស់លោក ខៀវ សំផន ដែលជាជនជាប់ចោទនៅក្នុងតុលាការរបស់លោកនៅទីនេះទេ។ ទោះយ៉ាងណាក៏ដោយ ការសម្រេចមិនចូលរួមក្នុងនីតិវិធីសវនាការនៅក្នុងសំណុំរឿង០០២/០២នេះ យើងខ្ញុំគ្មានចេតនាក្នុងការធ្វេសប្រហែស ឬមូលហេតុមិនសមហេតុផលណាមួយដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌នោះទេ។

ដូចលោក លោកស្រីបានជ្រាបស្រាប់ហើយថាលោក ខៀវ សំផន គ្មានបំណងលះបង់ការចូលរួមសវនាការក្នុងសំណុំរឿង០០២ នេះទេ។ តែបើគ្មានពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើឱ្យការងារទាំងពីរដើរក្នុងពេលតែមួយបាន លោកសម្រេចជ្រើសរើសយកការងារមួយដែលសំខាន់ជាង ដោយទុកការងារ

មួយទៀតមួយអន្លើសិន ដើម្បីកុំឲ្យវាខូចការងារទាំងពីរនេះ។ ម្យ៉ាងទៀត ខ្ញុំជឿថាអង្គជំនុំជម្រះសាលាដំបូងក៏គ្មានបំណងដាក់ឲ្យ លោក ខៀវ សំផន ស្ថិតក្នុងស្ថានភាពជាប់គាំង មិនអាចដកឃ្លារួចដោយសារជាប់រវល់នឹងការរៀបចំសរសេរបណ្តឹងសាទុក្ខផង និងត្រូវចូលរួមសវនាការផងក្នុងពេលតែមួយ ដើម្បីធ្វើឲ្យលោក ខៀវ សំផន បរាជ័យក្នុងកិច្ចការទាំងពីរនោះឡើយ។

[១៤:៣៥:៥៤]

ខ្ញុំសូមរំឭកថា នេះមិនមែនជាករណីព្រួញមួយបាញ់បានសត្វពីរទេ តែវាជាករណីដែលយើងមិនអាចចាប់ត្រីពីរដោយដៃតែម្ខាងបាន ពីព្រោះវានឹងធ្វើឲ្យត្រីទាំងពីររួចទាំងអស់។ ខ្ញុំអាចមានឃើញនូវការលំបាករបស់តុលាការនេះ ក៏ប៉ុន្តែតុលាការត្រូវតែយល់អំពីផលប្រយោជន៍ និងការអនុវត្តច្បាប់ជាពិសេសពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិស្របច្បាប់របស់លោក ខៀវ សំផន ផងដែរ។

ហេតុនេះខ្ញុំសូមអង្គជំនុំជម្រះ អាចលើកសវនាការ ឬក៏លោកអាចបន្តសវនាការដោយគ្មានការចូលរួមពីមេធាវីការពាររបស់លោក ខៀវ សំផន។ បើមិនដូច្នោះទេ យើងក៏គ្មានអ្វីនឹងស្នើសុំទាមទារទៀតដែរ ដោយហេតុថា អង្គជំនុំជម្រះបានសម្រេចកាលពីម្សិលមិញ រួចហើយក្នុងការបដិសេធឲ្យសំណើជាបន្ទាប់របស់យើងដើម្បីលើកពេលវេលាសវនាការនេះ។ ហេតុដូច្នេះ ជាចុងក្រោយសូមជម្រាបលាអង្គជំនុំជម្រះចាប់ពីពេលនេះទៅ ហើយយើងខ្ញុំអាចសូមចាកចេញពីបន្ទប់នេះដើម្បីទៅរៀបចំបណ្តឹងសាទុក្ខ សូមអរគុណ។

*(មេធាវីការពារក្តីចាកចេញពីបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា តើមានមតិយោបល់អ្វីដែរទេ?

[១៤:៣៨:១២]

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម ខ្ញុំគ្រាន់តែចង់បង្ហាញថា ទោះបីជាខ្ញុំមានការគោរពចំពោះមេធាវីការពារក្តីទាំងអស់នៅក្នុងរឿងក្តីនេះក៏ដោយ ប៉ុន្តែមិនមែនជាសិទ្ធិរបស់កូនក្តីគាត់ដែលដំណើរការសវនាការនេះទេ ហើយក៏មិនមានជាសិទ្ធិរបស់មេធាវីការពារក្តីក្នុងការសម្រេចថា ត្រូវមានដំណើរការនេះក៏អត់នោះឡើយ គឺអាស្រ័យទៅលើ លោក លោកស្រីចៅក្រម ដើម្បីធ្វើការបញ្ជាក់ថានូវការស្នើសិទ្ធិនៃការពារសិទ្ធិរបស់ជនជាប់ចោទ ហើយត្រូវឲ្យមានតុល្យភាពនៃសិទ្ធិនេះដើម្បីឲ្យធានានូវសវនាការដែលប្រព្រឹត្តទៅ

ដោយឆាប់រហ័សនិងយុត្តិធម៌។ នៅពេលដែលមេធាវីការពារក្តីនិយាយថាមានការលំបាកក្នុងពេលដំណើរការផង ប្តឹងសាទុក្ខផង ខ្ញុំសូមបញ្ជាក់ថាយើងក៏ប្រឈមបញ្ហាដូចគ្នានេះដែរ ហើយយើងបានធ្វើផែនការហើយយើងរំពឹងថាយើងនឹងធ្វើការងារនេះបានដោយល្អ។ ដូច្នេះខ្ញុំគិតថា លោក លោកស្រីចៅក្រម អាចកាត់បន្ថយកាលវិភាគសវនាការ ដើម្បីកុំឲ្យធ្ងន់ធ្ងរពេករហូតដល់ពេលសារណាបណ្តឹងសាទុក្ខទាំងអស់ត្រូវបានធ្វើ។ ដូច្នេះយើងអាចកាត់បន្ថយមកសល់ត្រឹមបីថ្ងៃក្នុងមួយសប្តាហ៍។ ដូច្នេះ ខ្ញុំស្នើសុំដល់លោក លោកស្រីចៅក្រម មេត្តាពិចារណា ហើយបង្គាប់ដល់មេធាវីការពារក្តីឲ្យមកបង្ហាញខ្លួន គឺមិនមែនជាការសម្រេច មិនមែនជាសិទ្ធិសម្រេចរបស់មេធាវីការពារក្តីក្នុងការដើរចេញពីសវនាការនោះឡើយ។ វាគឺថាមេធាវីការពារក្តីគាត់មានតួនាទីមួយដើម្បីការពារកូនក្តីរបស់គាត់។ ដូច្នេះ វាមិនមែនផ្អែកទៅលើកូនក្តីរបស់ពួកគាត់ធ្វើការសម្រេចនោះឡើយ គឺដូចដែលខ្ញុំបញ្ជាក់អ៊ីចឹង គឺថាលោក លោកស្រីចៅក្រម ជាអ្នកសម្រេចកាលវិភាគនៃសវនាការនេះ។ ខ្ញុំមិនចង់ឲ្យទាំងអស់គ្នាមិនចាប់អារម្មណ៍អ្វីទាំងអស់នេះឡើយ ប៉ុន្តែខ្ញុំគិតថា លោក លោកស្រីចៅក្រម អាចបង្គាប់ឲ្យមេធាវីការពារក្តីបង្ហាញខ្លួននៅក្នុងសវនាការនេះ ហើយគឺជាការសម្រេចរបស់តុលាការ ថាតើត្រូវគ្រប់គ្រងសវនាការនេះដោយរបៀបណា។ ហើយមេធាវីការពារក្តី និង មន្ត្រីទាំងអស់ គឺមានកាតព្វកិច្ចគោរពទៅតាមការបង្គាប់បញ្ជារបស់តុលាការ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ!

[១៤:៤០:៥០]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ប្រធានបទសំខាន់នេះ ខ្ញុំគិតថាវាជាការមានប្រយោជន៍ណាស់។ ខ្ញុំមិនយល់ -- សោកស្តាយណាស់ដែលថាមេធាវីការពារក្តីចេញទៅដោយមិនទាន់បានស្តាប់មតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រោះថាសិទ្ធិ -- គឺថាយើងត្រូវគោរពសិទ្ធិទាំងសងខាង ទាំងការពារក្តីផងទាំងខាងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ យើងធ្វើយ៉ាងណាឲ្យសិទ្ធិរបស់ជនជាប់ចោទ ឬខាងការពារក្តីត្រូវបានគោរព ហើយទាំងសងខាង ធ្វើយ៉ាងដើម្បីឲ្យមានយុត្តិធម៌ទាំងអស់គ្នា។ នៅពេលដែលលោក នួន ជា និងលោក ខៀវ សំផន ហើយនិងលោក នួន ជា និយាយអំពីការពិតពីយុត្តិធម៌នោះ ហើយយើងក៏ចង់បានដែរថា ខាងដើមបណ្តឹងរដ្ឋប្បវេណីក៏ចង់បានយុត្តិធម៌ដូចគ្នាដែរ។ អ៊ីចឹង បើសិនជានៅពេល ដរាបណាដែល ខៀវ សំផន ហើយនិង នួន ជា ចូលសវនាការនេះដោយសកម្មនោះ ខ្ញុំស្តាប់យល់

អម្បាញ់មិញនេះ គឺថាពួកគាត់ទាំងពីរគឺចង់ចូលរួមយ៉ាងសកម្ម ពន្យល់ ហើយនិងពន្យល់ហេតុផលនូវអំពីអ្វីដែលកើតមានឡើងនៅក្នុងរបបនោះរបស់ខ្មែរក្រហម ដែលយើងទាំងអស់ចាប់អារម្មណ៍។ ក៏ប៉ុន្តែសិទ្ធិរបស់ខាងការពារក្តី យើងត្រូវតែថ្លឹងថ្លែងដែរជាមួយនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី យើងមានគោលការណ៍ជាមូលដ្ឋានមួយចំនួនដើម្បីធ្វើឱ្យមានតុល្យភាព។ អ៊ីចឹង អស់លោក លោកស្រី ចៅក្រមត្រូវតែថ្លឹងថ្លែង ហើយយើងជាមេធាវី យើងគ្មានសិទ្ធិអំណាចអ្វីធ្វើយ៉ាងដូច្នេះទេ។ ខ្ញុំសង្កេតឃើញថាមេធាវីរបស់លោក នួន ជា ហើយនិង ខៀវ សំផន មិនប្រើអំណះអំណាងដូចគ្នាទេ។ ខាងក្រុម នួន ជា គាត់និយាយថា អ្វីដែលសំខាន់នោះគឺបណ្តឹងជិតចិត្តនោះទេ ហើយបើគាត់គិតយល់ឃើញថា នៅពេលដែលមិនទាន់មានចេញសេចក្តីសម្រេចទេនោះ តុលាការមិនមានសិទ្ធិបន្តសំណុំរឿង០០២/០២ នេះទេ។ ដូច្នេះ ក្នុងចំណុចនេះខាងដើមបណ្តឹងរដ្ឋប្បវេណីទុកចិត្ត ជឿជាក់លើសេចក្តីសម្រេចដែលត្រូវតែធ្វើ។ ក៏ប៉ុន្តែទាក់ទងក្រុម ខៀវ សំផន ដែលគេលើកឡើងថាបណ្តឹងសាទុក្ខឯណោះ។ អ៊ីចឹង កន្លែងត្រង់ចំណុចនេះនេះ ខ្ញុំដឹងថា លោក លោកស្រី ចៅក្រម បានគិតពីការកត់សម្គាល់របស់ក្រុមៗផ្សេងរួចហើយ។ នៅពេលដែលមិនទាន់ -- គឺថាវាពិបាកនឹងដឹកនាំសវនាការនៅពេលដែលគេកំពុងតែប្តឹងឧទ្ធរណ៍។ អ៊ីចឹង អ្វីដែលយើងធ្វើទាំងពីរនេះ យើងជាបញ្ហាមួយយើងត្រូវចេះសួរថា តើអាចធ្វើកើតឬមិនកើត? អ៊ីចឹង យើងគួរតែយកពេលមកពិចារណាទាំងអស់គ្នា។ ខាងការពារក្តីគួរតែមកទីនេះម្តងទៀត ហើយពិភាក្សាគ្នាជាមួយភាគីទាំងអស់ដើម្បីឱ្យដឹង មានគោលដៅរួមមួយ គឺថាដើម្បីរកការពិតឱ្យឃើញ ហើយនិងយុត្តិធម៌ ហើយពិភាក្សាគ្នាដោយចិត្តត្រជាក់ ដើម្បីរកផ្លូវកណ្តាលមួយ ដើម្បីដំណើរការតទៅមុខបាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ សូមអញ្ជើញ!

[១៤:៤៤:២៦]

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រី ចៅក្រម ខ្ញុំគិតថា ប្រហែលជាអាចជួយដល់តុលាការបាន។ ដោយពិចារណាទៅលើយុត្តិសាស្ត្ររបស់តុលាការសៀរ៉ាឡេអូនកន្លងមក នៅក្នុង សេម និងន័រមេនខេស -- រឿងក្តីសេម និង ន័រមេន *(Sam and Norman)* គឺ០៨ មិថុនា ២០០៤ ដែលតុលាការជួបប្រទះបញ្ហាប្រហាក់ប្រហែលគ្នានៅពាក់កណ្តាលកិច្ចដំណើរការនីតិវិធីដែលលោក ន័រមេន បានបង្គាប់ដល់មេធាវីរបស់គាត់មិនឱ្យតំណាងរបស់គាត់ ហើយគាត់ស្ម័គ្រចិត្តធ្វើជាមេធាវីតំណាងខ្លួនឯង។ ហើយនៅក្នុងរឿងក្តីដដែលនោះ

គឺថាមានការទទួលស្គាល់ថាសិទ្ធិធ្វើមេធាវីខ្លួនឯងហ្នឹង ត្រូវតែមានតុល្យភាព ដើម្បីឲ្យមានការធានាដល់ដំណើរការនីតិវិធីដោយយុត្តិធម៌និងត្រឹមត្រូវ។ ហើយនៅក្នុងរឿងក្ដីនោះ ដោយសារតែដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីកំពុងតែបន្ត ហើយវាអាចពន្យារពេលបង្កឡើងដោយលោក ន័រមេន ដែលព្យាយាមបង្កបញ្ហានៅក្នុងកិច្ចដំណើរការនីតិវិធី ព្រមទាំងការដែលគាត់អាច -- មិនអាចធ្វើជាមេធាវីតំណាងខ្លួនឯងហ្នឹង ហើយគេក៏ តុលាការក៏បង្គាប់មេធាវីត្រូវតែធ្វើជាមេធាវីតំណាងឲ្យលោក ន័រមេន។ ដូច្នេះ ខ្ញុំគិតថា លោក លោកស្រី ចៅក្រម អាចពិចារណាទៅលើយុត្តិសាស្ត្រកន្លងមកដែលកើតឡើងនៅតុលាការសៀរ៉ាឡេអូននេះ។ សូមអរគុណ។

[១៤:៤៥:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៥១:៤១]

**ប្រធានអង្គជំនុំ៖**

បន្តទៅនេះ អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់លើបញ្ហាមួយចំនួន។ ទី១ កត់សម្គាល់ពីការពហិការបស់ក្រុមមេធាវីទាំងពីរក្រុម គឺក្រុមមេធាវីការពារក្ដី នួន ជា និងក្រុមមេធាវីការពារក្ដី ខៀវ សំផន បានចាកចេញពីបន្ទប់ជំនុំជម្រះមុនពេលសហព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានតប។ ទី២ អង្គជំនុំជម្រះសង្ឃឹមថា គ្រប់ភាគីទាំងអស់ចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការដែលអង្គជំនុំជម្រះបានកំណត់រួចហើយថា ធ្វើនៅថ្ងៃអង្គារ ទី២១ ខែតុលា ឆ្នាំ២០១៤ នៅដើមសប្ដាហ៍ក្រោយនេះដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ៣) អង្គជំនុំជម្រះនឹងចេញសេចក្ដីសម្រេចលើការប្រព្រឹត្តរបស់ក្រុមមេធាវីការពារក្ដីទាំងពីរក្រុមដែលបានពហិកាចាកចេញពីបន្ទប់សវនាការនៅរសៀលនេះនៅពេលក្រោយ។

ដោយមេធាវីពហិកាចាកចេញពីបន្ទប់សវនាការ គឺអង្គជំនុំជម្រះមិនអាចដំណើរការតទៅទៀតបានទេ។ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកសវនាការថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកទៅបន្តនៅពេលក្រោយដែលអង្គជំនុំជម្រះនឹងជម្រាបជូនដំណឹងដល់ភាគី និងសាធារណជនបានជ្រាបនៅក្រោយពេលកិច្ចប្រជុំពិភាក្សារៀបចំសវនាការដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ អាទិត្យក្រោយនេះ។

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។

សម្រាកចុះ!៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:៥៣ នាទី)*